# ប្រារព្ធបុព្វកថា

ខ្ញុំព្រះករុណា ខ្ញុំបាទបានសរសេរសៀវភៅកំណាព្យធម៌ ភាគ ១ ភាគ ២ និង ភាគ ៣ រួចមកហើយ តែដោយការជ្រះថ្លាដ៏ខ្លាំងក្លារបស់ខ្ញុំព្រះករុណា ខ្ញុំបាទក្នុងថ្ងៃសាងព្រះផ្នួសរបស់ខ្ញុំព្រះករុណាខ្ញុំបាទ នៅថ្ងៃ ១៥ កើត ខែ ស្រាពណ៍ ព.ស ២៥៥៧ ត្រូវនឹងថ្ងៃពុធ ទី ២១ ខែ សីហា ឆ្នាំ ២០១៣ នៅពុទ្ធមណ្ឌលធម្មទូតកម្ពុជាស្ថិតនៅឃុំ ដីឥដ្ឋ ស្រុក កៀនស្វាយ ខេត្តកណ្ដាល ចំនួន ២១ថ្ងៃ ដើម្បីភ្ជាប់និស្ស័យ នឹងព្រះពុទ្ធសាសនា ហើយបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹករបស់ខ្ញុំព្រះករុណាខ្ញុំបាទផង និងដើម្បីជាការតបស្នង សងគុណមាតាបិតា និងគ្រូឧបជ្ឈាយាចារ្យរបស់ខ្ញុំផង ហើយលើសពីនេះទៅទៀតនោះគឺខ្ញុំព្រះករុណា ខ្ញុំបាទបានទិញត្រៃចីវរជូនដល់អ្នកម្ដាយរបស់ខ្ញុំព្រះករុណាខ្ញុំបាទ បានធ្វើជាកឋិនទានជាមួយលោកគ្រូអគ្គ បណ្ឌិត **ប៊ុត សាវង្ស** នៅថ្ងៃ ១៥ កើត ខែ អស្សុជ ព.ស ២៥៥៧ ត្រូវនឹងថ្ងៃសៅរ៍ទី ១៩ ខែ តុលា ឆ្នាំ ២០១៣ ហើយដង្ហែអង្គកឋិនទានចូលវត្តព្រះគន្ធកុដិនៅថ្ងៃ ១រោច ខែឆ្នាំដដែលនៅទីរួមខេត្តបាត់ដំបងដែលដឹកនាំដោយលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស**

ព្រមទាំងអ្នកម្ដាយរបស់ខ្ញុំព្រះករុណា និងម្ចាស់កឋិនទានផ្សេងៗទៀតជាច្រើនរាប់រយត្រៃជាកឋិនទាននៅថ្ងៃទី ១ ដ៏ធំអស្ចារ្យគួរឱ្យជ្រះថ្លាក្រៃលែងនូវមហាកុសលរបស់លោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** និងម្ចាស់កឋិនទានផ្សេងៗទៀតរួមទាំងអ្នកម្ដាយរបស់ខ្ញុំព្រះករុណា ខ្ញុំបាទផង ពេលនោះហើយដែលញ៉ាំងឱ្យខ្ញុំរលឹកនឹកគុណព្រះត្រៃរត្ន័មានព្រះពុទ្ធរតនៈ ១ ព្រះធម្មរតនៈ ១ និងព្រះសង្ឃរតនៈ១ ដែលជាមហារតនៈដ៏ប្រសើរឧត្ដម លើសរតនៈស្ដេចចក្រពត្តិក្នុងលោក និងទេវលោកទៅទៀត ដូច្នេះហើយបានជាខ្ញុំព្រះករុណា ខ្ញុំបាទមានសេចក្ដីព្យាយាមសរសេរកំណាព្យធមិភាគ ៤ នេះឡើងដើម្បីឧទ្ទិសបុញ្ញកម្មដែលកើតឡើងអំពីវិរិយៈក្នុងការសរសេរសៀវភៅធមិនេះ ជូនដល់មាតាបិតាខ្ញុំក្នុងបច្ចុប្បន្នកាលផង និងអតីតកាលផង ឧទ្ទិសថ្វាយចំពោះព្រះបរមរតនៈកោដ្ឋ **នរោត្តម សីហនុ** និងព្រះអង្គជ័យវរ្ម័ន៍ទី៧ផង និងឧទ្ទិសថ្វាយដល់ទេវតាឋានកណ្ដាល ទេវតាឋានលើទាំង ៦ ឋានផង រូបព្រហ្ម១៦ឋានផង អរូបព្រហ្ម ៤ឋានផង និងឧទ្ទិសជូនបុព្វវីរៈបុរសខ្មែរគ្រប់ជំនាន់ ដែលបានគោរពរាប់អានព្រះពុទ្ធសាសនាទាំងអស់ សូមទានមេត្តាត្រេកអរអនុមោទនានូវផលានិសង្សជាធម្មទាននេះដោយសេចក្ដីសោមនស្សរីករាយ ហើយ

សូមបានរួចរំដោះអស់ទុក្ខភ័យ មាននិស្ស័យនឹងព្រះត្រៃរត្ន័ ប្រាកដ **សីល** និង **ទាន ចាន សទ្ធា** ខ្លាំងក្លា មហាកុសលផ្ដល់ឱ្យសម្រេច មគ្គផលដល់និព្វានគ្រប់ៗគ្នាទៅហោង ។

នៅក្នុងសៀវភៅកំណាព្យធម៌ភាគ ៤ នេះគង់មានខុសពាក្យពេចន៏ខ្លះៗពុំខានឡើយ ហេតុនេះសូមព្រះករុណាជាម្ចាស់ និងបណ្ឌិត ព្រមទាំងសប្បុរសដែលបរិបូរណ៏ទៅដោយបញ្ញាទាំងអស់ មេត្តាជួយកែតម្រូវដោយកុសលចេតនា ហើយកាន់យកតែអត្ថន័យនៃព្រះធម៌ជាគ្រឿងពិចារណាដល់ហេតុផលផងចុះ ហើយខ្ញុំព្រះករុណា ខ្ញុំបាទសូមត្រេកអរអនុមោទនានូវកិរិយាប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា ទាំងអស់របស់អរិយជន សប្បុរសជន និងពុទ្ធបរិស័ទ ដោយសេចក្ដីជ្រះថ្លាជាទីបំផុតទាំងក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។

**សូមអរព្រះគុណ និង អរគុណ !**

ធ្វើនៅភ្នំពេញ ថ្ងៃ ៩កើត ខែ មិកសិរ ព.ស ២៥៥៧

ត្រូវនឹងថ្ងៃ ពុធ ទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣

ដោយខ្ញុំព្រះករុណាខ្ញុំបាទ

**អោក បូរ៉ា**

## ព្រះនាមអ្នកមានឧបការៈគុណក្នុងការឧបត្ថម្ភធម្មទាន

សៀវភៅកំណាព្យធម៌ភាគ ៤ នេះត្រូវបានលោកម្ចាស់ **ព្រះគ្រូព្រះមហាសន្ធរ ជោតិកៈ សុវណ្ណ ជោតោ ឆួង សុវណ្ណ** ជាអាចារ្យបង្រៀនព្រះវិន័យឧត្តមសិក្សានៅវត្ត និគ្រោធវ័ន ហៅគល់ទទឹង ព្រមទាំងភិក្ខុ **អគ្គវង្សោ ឆាយ ភន** និងភិក្ខុ **សតិបាលោ សុខ សុផៃ** ជួយកែអក្ខរាវិរុទ្ធ ដោយព្រះទ័យអនុគ្រោះ ។



**ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

# មាតិកាកំណាព្យធម៌ភាគ ៤


| ល.រ | ឈ្មោះកំណាព្យ | មេបទ | ទំព័រ |
|---|---|---|---|
| ១ | រឭកដល់ព្រះពុទ្ធគុណបានបុណ្យច្រើន | ព្រហ្មគីតិ | ១ |
| ២ | កាព្យខ្លីៗពី ✱១ ដល់ ✱៣២ | កាព្យរាយ | ១១ |
| ៣ | អ្នកខ្លៅស្អប់អ្នកប្រាជ្ញ | សុភាសិត | ១២ |
| ៤ | មន្តព្រះពុទ្ធស័ក្តិសិទ្ធិ | សុភាសិត | ១៣ |
| ៥ | ដង្ហែព្រះធម៌ថ្វាយព្រះពុទ្ធ | ពាក្យ៧ | ១៤ |
| ៦ | ព្រះអាទិត្យគិតប្រយោជន៍សត្វលោក | សុភាសិត | ២២ |
| ៧ | ព្រះសង្ឃជាមាសពេជ្រ | ពាក្យ៨ | ២៤ |
| ៨ | បុត្រខេមរាសច្ចាសុំ | សុភាសិត | ៣០ |
| ៩ | ធ្វើស្រូវត្រូវពិនិត្យស្រែ | កាព្យរាយ | ៣១ |
| ១០ | បុណ្យភ្ជុំបិណ្ឌ | ពាក្យ៨ | ៣៣ |
| ១១ | លៃបណ្ដុះពូជបុណ្យឱ្យទាន់រដូវ | សុភាសិត | ៤០ |
| ១២ | បុណ្យមិនទាន់ពេញយំកិញ្ចិបន្ថែម | សុភាសិត | ៤២ |
| ១៣ | បុណ្យបូជាព្រះចន្ទ | ពាក្យ៨ | ៤៣ |

| | | | |
|---|---|---|---|
| ១៤ | ពុទ្ធមណ្ឌលធម្មទូត | កាព្យថ្មី | ៤៥ |
| ១៥ | ព្រះធរណីមានគុណ | សុភាសិត | ៥១ |
| ១៦ | សូមពរពីព្រះពុទ្ធ | សារភញ្ញ | ៥៣ |
| ១៧ | រូបយើងសង្ឃឹមមិនបាន | សុភាសិត | ៥៥ |
| ១៨ | ផ្កាសិរីមង្គល | កាព្យថ្មី | ៥៦ |
| ១៩ | ម្លប់ព្រះពុទ្ធព្រះធម៌ | សុភាសិត | ៥៩ |
| ២០ | មាន់រងាវហើយកូន | ពាក្យ៧ | ៦១ |
| ២១ | ជិតដល់ពេលហើយ | សុភាសិត | ៦៣ |
| ២២ | ប្ដឹងមនុស្សមិនបានការទើបប្ដឹងទេវតាឱ្យជួយវិញ | សុភាសិត | ៦៥ |
| ២៣ | សុគតិសួគ៌ទេវលោក | កាព្យថ្មី | ៦៧ |
| ២៤ | ល្ងង់ល្ងិតបិទកុសលផ្ដល់តែបាប | សុភាសិត | ៧១ |
| ២៥ | ដួងព្រលឹងខ្មែរ | កាព្យថ្មី | ៧៥ |
| ២៦ | លេខបូកមានប្រយោជន៍ | ឧទាន | ៧៩ |
| ២៧ | បណ្ដាំបុព្វទេព | កាកគតិ | ៨០ |
| ២៨ | អត់ធ្មត់ណាកូនណា | ឧទាន | ៨៤ |

| | | | |
|---|---|---|---|
| ២៩ | កុំភ្លេចណាកូនណា | សុភាសិត | ៨៤ |
| ៣០ | ត្រៃលក្ខណ៍ធម៌ | ពាក្យ៨ | ៨៥ |
| ៣១ | គុណទឹកដោះម្តាយថ្លៃ | សុភាសិត | ៨៦ |
| ៣២ | ជំនួញក្នុងព្រះពុទ្ធសាសនា | ពាក្យ៨ | ៨៩ |
| ៣៣ | អាក្រក់ជួរជាតិ | សុភាសិត | ៩២ |
| ៣៤ | ជួយម្តាយផង | សារភញ្ញ | ៩៣ |
| ៣៥ | បុណ្យសាងព្រះផ្នួស | សារភញ្ញ | ៩៤ |
| ៣៦ | បណ្តាំពុកម៉ែ | កាកគតិ | ៩៥ |
| ៣៧ | អាងកុសលធម៌ | កាកគតិ | ៩៦ |
| ៣៨ | អាងអកុសលធម៌ | កាកគតិ | ៩៨ |
| ៣៩ | ទេពអប្សរនៅឆកាមា | កាកគតិ | ១០១ |
| ៤០ | ពរទេវតារក្សាឆ្នាំថ្មី | កាកគតិ | ១០៣ |
| ៤១ | ព្យញ្ជនៈ៣៣តួ | កាព្យថ្មី | ១០៥ |
| ៤២ | សម្លាប់បានបុណ្យ | កាកគតិ | ១១៤ |
| ៤៣ | ធ្វើទានមានទ្រព្យធន | ពាក្យ៨ | ១១៦ |
| ៤៤ | ធម៌សម្រាប់ភាវនាតាមឆ្នាំ | កំណើត | ១១៧ |
| ៤៥ | ព្រះគាថាទាំង ៨ | ភាវនា | ១២២ |




## សីល សមាធិ បញ្ញា

ជាគ្រឹះសំរាប់ជួយពង្រឹងគ្នាទៅវិញទៅមក នៃអង្គនីមួយៗ របស់អដ្ឋង្គិមគ្គ ឬ សម្មាមគ្គដែលជាផ្លូវប្រតិបត្តិត្រូវសំរាប់ធ្វើ ដំណើរទៅកាន់ព្រះនិព្វាន ។

# ពុទ្ធគុណ

## អរហំ សម្មាសម្ពុទ្ធោ ភគវា ពុទ្ធំ
## ភគវន្តំ អភិវាទេមិ

+ អាក់រ៉ាក់ហាំង សាំមាសាំពុតធោ ភាក់គាក់វ៉ា
ពុតធាំង ភាក់គាក់វ៉ាន់តាំង អាក់ភិវ៉ាទេមិ

(ក្រាបថ្វាយបង្គំ)

# រឭកដល់ព្រះពុទ្ធគុណបានបុណ្យច្រើន
## ( បទព្រហ្មគីតិ)

+ អរហំតាំងស្មារតី ជនប្រុសស្រីគ្រប់ៗប្រាណ
ពេលណាក៏នឹកបាន បុណ្យកល្យាណបានលើសលន់ ។
+ បង្អោនដល់ពុទ្ធកិច្ច សូមកុំភ្លេចនូវពុទ្ធគុណ
សាងល្អទុកធ្វើទុន ត្រូវអត់ធន់បុណ្យបានច្រើន ។
+ ដេកដើរ ឬធ្វើការ ទៅទីណានឹងចម្រើន
ឱ្យផលបានកើតកើន យសស័ក្តិថ្កើនក្រើនរឭក ។
+ នូវនាមព្រះសម្ពុទ្ធ វិសេសសុទ្ធច្រើនសន្ធឹក
ពេលល្ងាចនិងពេលព្រឹក សូមហាត់ហ្វឹកថ្វាយបង្គំ ។

\+ អរហំនាមដ៏ល្អ    ពិតបវរនៃព្រះបរម
ទាំងអស់ដ៏ឧត្តម    ឱនបង្គំបានមង្គល ។
\+ ព្រះនាមថាអរហំ    ឥតមានតាំងជាសកល
ព្រះពុទ្ធផ្តាច់ឫសគល់    គ្មានសេសសល់គឺកិលេស ។
\+ សម្មាសម្ពុទ្ធោ    ដឹងធម្មោយ៉ាងពិសេស
ទ្រង់បាននូវចំណេះ    យ៉ាងដូច្នេះដោយគ្មានគ្រូ ។
\+ ព្រះនាមទាំងនុះណា    វិជ្ជាថ្លាបរិបូរណ៍
ត្រាស់ដឹងនូវសព្វញ្ញូ    លោកវិទូវិជ្ជាប្រាំបី ។
\+ ព្រះនាមសុគតោ    ដំណើរឆ្ពោះព្រះជិនស្រី
ឆ្លងផុតភពទាំងបី    អមតថ្លៃព្រះនិព្វាន ។
\+ ព្រះនាមមិនទាន់អស់    សូមសប្បុរសនាំគ្នារៀន
សទ្ធាដែលយើងមាន    ប្រឹងធ្វើទានដោយមេត្តា ។
\+ ភាវនាសូមកុំភ្លេច    ត្រូវពន្លិចធមិមុសា
ទាញយកតែករុណា    មុទិតាធ្វើជាមិត្រ ។
\+ ពុទ្ធោ ភគវា    កិលេសមារត្រូវតែបិទ
សន្តំរក្សាចិត្ត    នោះយើងពិតបានសុខសាន្ត ។

(ចប់)

សូមអនុមោទនា

## អធិប្បាយ

**ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ**
**វិជ្ជាចរណ សម្បន្នោ សុគតោ លោកវិទូ**
**អនុត្តរោ បរិសទម្ម សារថិ សត្ថា**
**ទេវមនុស្សានំ ពុទ្ធោ ភគវាតិ**

ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា : **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ គឺកិលេសព្រមទាំងវាសនា គឺកាយបយោគ និង វចីបយោគ ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូរណ៍ដោយ វិជ្ជា៣ និងវិជ្ជា៨ និងចរណៈ១៥។ ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គ មានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺ អមតៈ មហានិព្វាន ។ ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ។ ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរសដែលមាន ឧបនិស្ស័យគួរនឹងទូន្មានបាន ។ ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃ

ទេវតានិងមនុស្សទាំងឡាយ ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញ៉ាំងអ្នកដទៃ ឱ្យត្រាស់ដឹងផង។ ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

## ប្រែក្នុងពុទ្ធគុណទាំង៥៦លម្អិតបន្តទៀត គឺយកតែ អក្ខរៈមួយៗ មកប្រែសេចក្តីខ្លីៗ តាមបទដែលចេញមកពីបាលីដែលខ្ញុំបាន បានដកស្រង់ចេញពីសៀវភៅឥតិបិសោរតនៈមាលា ។

**ឥ** គឺព្រះអង្គប្រាថ្នាប្រាជ្ញាសព្វញ្ញុតញ្ញាណ គ្មានធុញថប់ត្រឡប់ថយក្រោយ ពុំមានធ្លោយទាល់ តែក្ស័យអាសាវៈ ។

**តិ** គឺព្រះអង្គទ្រង់ឆ្លងនូវលោកទាំង ៣ អន្លង់ទាំង៣ ជាទីប្រជុំនូវកងទុក្ខរួចហើយ ព្រះអង្គប្រសើរឧត្តម ។

**បិ** គឺព្រះអង្គមានឥន្ទ្រិយ៍ស្មើត្រឹមជាទីស្រលាញ់ នៃទេវតាមនុស្សលោក សុបណ្ណគ្រុឌ ដ៏ឧត្តមលើសពពួកព្រហ្មទាំងឡាយ ។

**សោ** គឺព្រះអង្គជៀសវាងផុតចេញពីសេចក្តីសោក ហើយទ្រង់ល្អព្រមទាំងទេវលោក ហើយញ៉ាំងសត្វឱ្យរីករាយ ។

**ភ** គឺព្រះអង្គមានផស្សិរិយាទិធម៌ល្អ បំបាត់បង់នូវបាប ហើយសត្វភ័យស្លន់ស្លុតឱ្យស្រស់ស្រួលបួលទូលាយចិត្ត ។

**គ** គឺព្រះអង្គដល់នូវធម៌ស្អាតប្រពៃ ព្រមទាំងទេវលោកជាទីស្រណុកស្រណាន ហេតុដ្បិត អស់ទៅនូវកងទុក្ខ ។

**ខា** គឺព្រះអង្គចេញចាកពីតណ្ហា ហើយមានព្រះវាចាពីរោះឧត្តមអារម្មណ៍ តែងព្យាយាម ដើម្បីញុំាងសត្វឱ្យដល់និព្វានជាមិត្ត ។

**អ** គឺព្រះអង្គប្រកបដោយគុណជាអនន្ត ហើយប្រិតប្រៀនប្រដៅសត្វឱ្យមានដង្ហើមចេញចូលដោយធូរស្រួល ។

**វ** គឺព្រះអង្គត្រេកអរក្នុងព្រះនិព្វានហើយ ញុំាងសត្វឱ្យរួចពីទុក្ខ ហើយត្រេកអរក្នុងព្រះនិព្វានផង ។

**ឃាំ** គឺព្រះអង្គសម្លាប់បាបធម៌ជាសត្រូវខាងក្នុងហើយ ញុំាងសត្វឱ្យសម្លាប់បង់ផង ។

**ស** គឺព្រះអង្គសំដែងនូវសម្បត្តិធម៌ និងអសង្ខតធម៌ដ៏ប្រពៃពុំមានវិបរិត ហើយញុំាងសត្វឱ្យញុំាញីកាច់កិននូវសង្សារវដ្តចោល ។

**ម្នា** គឺព្រះអង្គញុំាញីនូវមោហៈនិងភាពរឹងត្អឹង នៃសត្វទាំងឡាយដូចម្តាយរក្សាកូនហើយពពួកទេវតាតែងគោរពបូជា ។

**ស** គឺព្រះអង្គបំពេញបារមីទាំងពួងពេញស្មើហើយ ទ្រង់សុខក្នុងអង្គជាសុខុមល្អិត ហេតុ ដ្បិតធ្វើឱ្យក្ស័យនៃសង្ខារ ។

**ម្តុ** គឺព្រះអង្គឈ្វេងយល់ច្បាស់ នូវសច្ចៈទាំង៤ ហើយញ៉ាំងពពួកសត្វឱ្យដឹងផងជាហេតុនឹងឱ្យបាននូវមគ្គ ។

**ឆ្វោ** គឺព្រះអង្គលាងរាគៈ លាងទោសៈ លាងមោហៈ ជ្រះហើយញ៉ាំងសត្វឱ្យលាងកិលេសបង់ផង ។

**ទិ** គឺព្រះអង្គស្ងាត់ចាកអសទ្ធម្មហើយ ទ្រង់វិចិត្រនូវធម៌ទេសនាតម្កល់ព្រះហឫទ័យក្នុងវិវេកស្ងាត់ចាកកាមគុណ ។

**ជ្វា** គឺព្រះអង្គជាតិជាព្រះពុទ្ធប្រសើរ ហើយទ្រង់ប្រកាសសម្តែងនូវព្រះនិព្វាន ជាទីបំផុតនៃជាតិធម៌ ជរាធម៌ ។

**ច** គឺព្រះអង្គប្រកបនូវបុណ្យសម្ភារប្រកបក្នុងសុខ ព្រមលះបង់នូវបាបធម៌ ហើយញ៉ាំងសត្វឱ្យលះបង់ផង ។

**រ** គឺព្រះអង្គទ្រង់តម្រេកតែក្នុងព្រះនិព្វាន ជាទីរក្សាសត្វដល់ព្រម ។

**ឈរៈ** គឺព្រះអង្គបញ្ចេញស័ព្ទសីហនាទ ជាទីត្រេកអរនៃទេវតាមនុស្ស សត្វ ព្រហ្មតែងបង្គំសព្វកាល ។

**ស** គឺព្រះអង្គទ្រង់វិវេកស្ងាត់ចាកបង់ ហើយឈ្វេងនូវជាតិសត្វជានិច្ចកាល ។

**ម្សៀ** គឺព្រះអង្គប្រសើរក្នុងការសាងសន្សំនូវ ពោធិសំភារទាំង ទេវតា ព្រហ្មមនុស្សក្នុងលោកព្រះអង្គ ប្រសើរដោយបញ្ញា គ្មានបញ្ញាណាស្មើ ។

**ឆ្នោ** គឺព្រះអង្គឈោងស្រង់សត្វឡើងពី នរក សត្វមនុស្សនៅ អោយហាមប្រាមពុំបានឱ្យធ្វើអាក្រក់ ។

**ស្មុ** គឺព្រះអង្គទ្រង់សូរសៀងពីរោះក្រៃក្នុងធម្មភាសន សត្វ ឃើញបានដោយក្រ ទ្រង់ឱ្យឃើញងាយ ។

**គ** គឺព្រះអង្គស្គាល់នូវលោកិយធមិ ទ្រង់លើកព្រះញាណឆ្លុះទៅ ជាប់ផ្លូវ អមតនិព្វាន មកតម្កល់សកលវិញ ។

**តោ** គឺព្រះអង្គត្រេកអរក្នុងទីក្ស័យទុក្ខភ័យ ហើយញ៉ាំងសត្វ ដែលស្រវឹងឱ្យត្រេកអរតាម ជាហេតុធ្វើឱ្យសត្វលោក ស្រោលស្រវឹង ។

**លោ** គឺព្រះអង្គប្រសើរដោយគុណ វិសេសជាងសត្វប្រសើរ ហេតុ តែលះបង់នូវលោភៈ ហើយញ៉ាំងលោកឱ្យលះបង់ ។

**ភ** គឺព្រះអង្គជិនស្រីសម្ដែងនូវមធុរធមិពីរោះប្រពៃ ជាហេតុ ធ្វើឱ្យក្ស័យនូវទុក្ខនៃសត្វទាំងពួង ។

**វិ** គឺព្រះអង្គជិនស្រីប្រកបដោយញាណថ្លា ព្រះទ័យថ្លា ពិសេស ហើយកំចាត់បង់នូវភពទាំង៣ ។

ន្ទ គឺព្រះអង្គទ្រង់ប្រលោមលួងសត្វ ដែលប្រទូសរ៉ាយនឹងគ្នាឱ្យសម្លាប់ ចិត្តប្រទូសបង់ ហេតុអាស្រ័យនិញ្វានពីចម្ងាយ ។

អ គឺព្រះអង្គឋិតក្នុងនិញ្វានជាបំផុតនៃកងទុក្ខ មានជរាទុក្ខជាដើម ហេតុព្រះទ័យឧស្សាហ៏ក្រៃ ញ៉ាំងសត្វឱ្យដកដង្ហើមស្រួល ។

ន្ទ គឺព្រះអង្គញ៉ាំងជនឱ្យបន្ទោបង់រាគៈចិត្តចេញ ហើយញ៉ាំងឱ្យឧស្សាហ៏រៀនយកនូវប្រយោជន៏ដោយពិត ។

ត្ថ គឺព្រះអង្គទ្រង់ញ៉ាំងធមិ ទេសនាឱ្យពិស្ដារដោយកុសលកម្មទាំង ៣ ញ៉ាំងសត្វចរតាមតណ្ហាឱ្យសម្លាប់តណ្ហាបង់ ។

រោ គឺព្រះអង្គញ៉ាំងសត្វខឹងច្រើន ស្អប់ច្រើនមិនឱ្យខឹង មិនឱ្យស្អប់ ហើយញ៉ាំងសត្វឱ្យសម្លាប់ **រាគៈ ទោសៈ មោហៈ** ចេញ ។

ប្ទ គឺព្រះអង្គកើតជាកូនស្ដេចសាក្យរាជ មានប្រាជ្ញាទ្រង់បំពេញបារមីទាំង ១០ ហេតុនឹងជម្រះបាបនៃព្រះអង្គឯង ។

រិ គឺព្រះអង្គសម្លាប់ភព មានរាគៈជាដើម ដោយឫទ្ធិសិក្សារៀនយកនូវឫទ្ធិ ។

ស គឺព្រះអង្គប្រកបដោយសីល សមាធិបវរ ហើយប្រកបដោយញាណដឹងឯង ។

**ឆ** គឺព្រះអង្គទ្រង់ទូន្មានលោក ព្រមទាំងទេវលោក ហេតុនឹងឱ្យបានដល់នូវអមតៈជាទីក្សេមក្សាន្ត ។

**ម្ន** គឺព្រះអង្គមានដួងព្រះហឫទ័យ មកអាស្រ័យនូវព្រះញាណធំ ឧស្សាហ៍ធំ មនុស្សទេវលោកបង្គំបូជា ។

**សា** គឺព្រះអង្គញ៉ាំងសត្វទាំងឡាយក្នុងលោកនេះ រំឭកយកផ្លូវនិព្វាន ជាទីពឹងដូចនាយសារថី ។

**រ** គឺព្រះអង្គទ្រង់ស្រណុកស្រណានក្សាន្តព្រះហឫទ័យ ក្នុងរសធម្មំ ប្រពៃហើយញ៉ាំងសាវ័កឱ្យក្សាន្តទៅផង ។

**ថិ** គឺព្រះអង្គព្រមទាំងសាវ័កដាក់តម្កល់ថ្កល់ព្រះហឫទ័យ ក្នុងឋានដ៏ខ្ជាប់ខ្ជួន ហើយសម្តែងនូវធម៌ខ្ជាប់ខ្ជួន ។

**ស** គឺព្រះអង្គព្រមទាំងរម្ងាប់ព្រះហឫទ័យស្ងប់ឈឹង ហើយសម្តែង នូវធម៌ញ៉ាំងសត្វឱ្យដល់នូវព្រះនិព្វាន ។

**ត្ថា** គឺព្រះអង្គបានដល់ទីនិព្វាន ដោយកម្លាំងព្រះហឫទ័យ ហើយញ៉ាំងសត្វឱ្យតម្កល់នៅក្នុងទីអស់ទុក្ខទាំង ៧ កង ។

**ទេ** គឺព្រះអង្គឱ្យធម៌ប្រសើរ ឱ្យទានប្រសើរ ហេតុតែញ៉ាំងសត្វឱ្យបានសួគ៌ានិព្វាន ។

**វ** គឺព្រះអង្គខ្ជាក់បង់ចោល **រាគៈ ទោសៈ មោហៈ រកអាសវៈ** គ្មានហើយទេវតាព្រហ្មតែងបង្គំបូជា ។

**ម** គឺព្រះអង្គបានមនៅវិញ្ញាណមុតសថ្លា ហើយសំដែងនូវមគ្គធម៌ ជាហេតុញ៉ាំងមនុស្សទេវតាឱ្យលះបង់មិច្ឆាធម៌ ។

**ន** គឺព្រះអង្គសំដែងធម៌ពិត១ ដើម្បីបន្ទោបង់នូវបាប បន្ទោបង់នូវទុក្ខ និង បន្ទោបង់នូវមិច្ឆាពិត១ ។

**ស្វា** គឺព្រះអង្គរំឭកសាវ័កឱ្យភ្ញាក់ស្មារតី និងឱ្យរំឭកធម៌ជាខ្លឹមឱ្យបានសិក្សារៀនយកធម៌ជាខ្លឹម ។

**នំ** គឺព្រះអង្គមហាមុនីទ្រង់សោយសុខ ក្នុងរស់ធម៌ហ្មត់ចត់ប្រពៃហើយញ៉ាំងទេវតាដែលអរឱ្យរីងរឹតតែអរច្រើនឡើង ។

**ពុ** គឺព្រះអង្គប្រកបដោយគុណធម៌ដ៏រីកធំ សាយដូចផ្កាបទុមរីកហើយញ៉ាំងសត្វឱ្យរីកសាយតាមផង ។

**ទ្ធោ** គឺព្រះអង្គមហាវីរៈបុរស ទ្រង់លាងមន្ទិលក្នុងព្រះអង្គស្រេចហើយ ញ៉ាំងសត្វឱ្យលាងនូវកិលេសជាមន្ទិលឱ្យបង់ផង ។

**ភ** គឺព្រះអង្គកន្លងបង់នូវភូមិទាំងពួង ហើយញ៉ាំងសត្វដែលភិតភ័យឱ្យលះបង់ចោលនូវសេចក្តីភិតភ័យ ។

**គ** គឺព្រះអង្គទ្រង់ព្រះញាណឈ្វេងដល់សព្វធម៌ល្អ ហើយញ៉ាំងឱ្យកាន់យកនូវធម៌ដ៏ល្អ ។

**ទា** គឺព្រះអង្គអប់រំហើយឱ្យផ្សាយទៅនូវធម៌ដ៏ប្រពៃ ហេតុនឹងឱ្យរួចពីតណ្ហា ហើយញ៉ាំងបរិស័ទឱ្យអប់រំ ហើយផ្សាយទៅនូវធម៌ ដ៏ល្អផង ។

**តិ** គឺព្រះអង្គមានញាណដ៏មុតទ្រង់ឆ្លងនូវសង្សារចក្រ នូវបាបទាំងឡាយទាំងពួង ហើយញ៉ាំងសត្វទាំងឡាយឱ្យបានតម្កល់ក្នុងត្រើយពោល គឺព្រះនិព្វាន ។

❖ ចប់សេចក្ដីប្រែពីភាសាបាលីក្នុងល្បែងព្រះពុទ្ធគុណទាំង ៥៦ បទ ជាន័យសង្ខេបទំរង់ខ្លីសម្រាប់វត្តប្រតិបត្តិតែប៉ុណ្ណោះ ។

សូមអនុមោទនា

# កាព្យខ្លីៗពី *១ ដល់ *៣២

*** ១. ចំណី ចំណង់ ចង់ ឱ្យ ត្រូវបទ**
**ចំណាយ ត្រូវកត់ ឱ្យ បាន ត្រឹមត្រូវ**
**ចំណែក ជំនួញ ចំណេញ ចូល ទៅ**
**ចំណោះ នាំផ្លូវ ទើបមាន ចំណូល ។**

# អ្នកខ្លៅស្អប់អ្នកប្រាជ្ញ

## ( សុភាសិត)

សព្វថ្ងៃអ្នកខ្លៅស្អប់អ្នកប្រាជ្ញ ពោលពាក្យមិនខ្លាចឮសុសសាយ
ល្ងង់ល្ងិតប្រព្រឹត្តតែអបាយ មិនគិតវែងឆ្ងាយមិនខ្វល់ច្បាប់ ។
អ្នកប្រាជប្រាប់គាត់មិនស្តាប់ឡើយ អ្នកខ្លៅនៅក្រោយទើបគាត់ត្រាប់
ជីវិតនៅរស់ទ្រព្យមានស្រាប់ ដកថយគិតច្បាប់ទើបអ្នកឆ្លាត ។

(ចប់)

សូមអនុមោទនា

* ២. គេថា អ្នកល្ងង់ ស្អប់ គំនិត
អ្នកប្រាជ្ញ នៅ ជិត ក៏ មិនដឹង
ទង្វើ ខ្លួន ធ្វើ ដូច អ្នក ស្រវឹង
តែ ខ្លួន រឹងត្អឹង ថា ធ្វើ បានល្អ ។

* ៣. ទង្វើ បែប ហ្នឹង កុំ ប្រឹង កូន ថ្លាយ
ដក ខ្លួន ឱ្យ ឆ្ងាយ ដោះស្រាយ រិះគិត
រៀន ស្តាប់ សប្បុរស ហើយ និង បណ្ឌិត
ថ្ងៃក្រោយ កូនពិត ជាមាន សំណាង ។

# មន្តព្រះពុទ្ធស័ក្តិសិទ្ធិ

## ( សុភាសិត)

- បើ ចង់ឈ្នះ មនុស្សកាច មនុស្សខឹង
  ត្រូវតែ ខំប្រឹង អត់ធ្មត់ ឱ្យបាន ៗ
- បើ ចង់ឈ្នះ មនុស្សកំណាញ់ សាមាន្យ
  ត្រូវប្រឹង ឱ្យបាន ធ្វើទាន ឱ្យជាប់ ៗ
- បើ ចង់ឈ្នះ មនុស្ស អសុរោះ
  ត្រូវ និយាយ ពីរោះ ហើយ ទន់ភ្លន់ ៗ
- បើ ចង់ឈ្នះ មនុស្សនិយាយ ឡេះឡោះ
  ត្រូវស្តាប់ ទាំងអស់ តែ កុំធ្វើដឹង ៗ

(ចប់) សូមអនុមោទនា

* ៤. សប្បុរសប្រើគំនិត បណ្ឌិតប្រើបញ្ញា
ពិធីករប្រើវោហារ អ្នកសិក្សាប្រើតស៊ូ ។

* ៥. អាចារ្យប្រើក្បួន ពួកពាក់ធ្នួនប្រើល្បិច
ចិនគេប្រើកិច្ច រលិចស្រិចៗគេប្រើឆត្រ ។

# ធម្មគុណ

# ស្វាក្ខាតោ ភគវតា ធម្មោ ធម្មំ

# នមស្សាមិ

ស្វាកខាតោ ភាក់គាក់វាក់តា ធាំមោ

ធាំមាំង នាក់មះសាមិ

(ក្រាបថ្វាយបង្គំ)

# ដង្ហែព្រះធម៌ថ្វាយព្រះពុទ្ធ

## ( បទពាក្យ ៧)

\+ ស្វាក្ខាតោភគវតា ខ្ញុំលើកហត្ថាឱនសិរសី
បង្គំព្រះធម៌ដ៏ថ្លាថៃ ដែលព្រះជិនស្រីសំដែងទុក ។

\+ ព្រះធម៌ពិតទ្រទ្រង់សត្វលោក ធម្មធរ(១) គរគោកឆ្ពោះទៅមុខ
ផ្សព្វផ្សាយធម៌ឱ្យបានពេញស្រុក ទប់ការវាយលុកពីជនទមិឡ ។

\+ ធម្មគុណជួយស្រោចស្រង់សត្វ និងជួយទប់ស្កាត់បែរបង្វិល
នូវសត្វលោកដែលមានមន្ទិល ឬនៅខ្វល់ខ្វាយរកត្រូវ ។

\+ ការរឭកដល់ព្រះធម្មគុណ នាំចម្រើនបុណ្យច្រើនពេកកូវ
ព្រះធម៌ជួយទ្រហើយនាំផ្លូវ ដំណើរឆ្ពោះទៅបរមសុខ ។

---

(១) **ធម្មធរ** = គឺជាអ្នកទ្រទ្រង់ធម៌ អ្នកប្រតិបត្តិត្រឹមត្រូវតាមធម៌ ។

+ ព្រះធម៌កម្របានជួបណាស់ ញាតិញោមគុណម្ចាស់កុំសំកុក
ចូរកុំប្រមាទស្វាធ្យរើសទុក ថាខ្លួនអផ្សុកទុកពេលទំនេរ ។
+ ព្រះធម៌ថ្លៃជាងមាសជាងពេជ្រ អ្នកប្រាជ្ញហាមផ្តាច់កុំវៀចវេរ
កុំគប់មិត្រពាលនាំខូចកេរ្តិ៍ ក្នុងនាមកូនខ្មែរត្រូវតែល្អ ។
+ ព្រះធម៌មានគុណធំពេកណាស់ មានពិតយ៉ាងច្បាស់ដ៏បវរ
ហៃជនប្រុសស្រីគួរសាទរ ដង្ហែព្រះធម៌ថ្វាយព្រះពុទ្ធ ។

(ចប់)

សូមអនុមោទនា

## <u>អធិប្បាយ</u>

គប្បីតាំងចិត្តរឭកដល់ធម្មគុណ

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ**

**ឯហិបស្សិកោ**

**ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

**ប្រែក្នុងធម្មគុណ :** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ។ ព្រះនព្វលោកុត្តរធម៌ មាន៩ ប្រការ គឺ **មគ្គ៤ ផល៤ និព្វាន១** ។ **ជាធម៌**

គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិតដោយ **បច្ចវេក្ខណញ្ញាណ**[១] គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដ៏ទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង ។ **ជាធម៌** ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុង លំដាប់គ្នាមិនបានឃឹតយូរឡើយ ។ **ជាធម៌** គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយក៏គួរហៅបុគ្គលដទៃឱ្យចូលមកមើលបាន ។ **ជាធម៌** គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **ជាធម៌** គឺ អ្នកប្រាជ្ញទាំងឡាយមាន **ឧគ្ឃដិតញ្ញូបុគ្គល**[២] ជាដើមគប្បីដឹង គប្បីឃើញបុគ្គលច្បាស់ក្នុងចិត្តនៃខ្លួន។

## ប្រែអក្ខរមួយៗក្នុងធម្មគុណទាំង ៣៨ លម្អិតបន្តទៀត គឺយកតែ អក្ខរៈ មួយៗមកប្រែខ្លីៗតាមបទដែលចេញមកពីបាលីដែលខ្ញុំបាទបានដកស្រង់ចេញពីសៀវភៅឥតិបិសោរតនៈមាលា ។

---

(១) **បច្ចវេក្ខណញ្ញាណ** = គឺជាប្រាជ្ញាដែលពិចារណាឃើញច្បាស់ ដឹងពិត ឃើញពិតដោយញាណ ។

(២) **ឧគ្ឃដិតញ្ញូបុគ្គល** = គឺជាអ្នកមានប្រាជ្ញាដឹងច្បាស់ ឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

**ស្វា** គឺមានភ័ព្វលំនាំទៅមកដោយល្អ គឺបុគ្គលគប្បីបូជាដោយចិត្តស្អាត គឺព្រះដ៏មានបុណ្យសំដែងទុក ។

**ក្វា** គឺធម៌តែងទំពាស៊ីសព្វសារពើពូជកំណើតទាំងពួង ស៊ីនូវរសធម៌ នៃធម៌ខ្លួនឯង ស៊ីនូវលោកទាំង៣ ។

**តោ** គឺធម៌ញ៉ាំងសត្វទាំងអស់ឱ្យត្រេកអរ ដោយចំណែកផ្សេងៗជាចំណែកៗ ឱ្យត្រេកអរក្នុងសព្វធម៌ដល់ឡើងឯង ។

**ភ** គឺធម៌ល្អបំបាត់បង់នូវបាប ហើយញ៉ាំងសត្វភ័យស្លន់ស្លុតឱ្យស្រស់ស្រួលចិត្តឡើងវិញ ។

**គ** គឺធម៌ដល់ក្នុងទីអស់ទុក្ខជាទីស្រណុកស្រណានចិត្ត ហើយញ៉ាំងសត្វទាំងពួងឱ្យដល់នូវព្រហ្មចរិយ ជាហេតុនាំឱ្យអស់ទុក្ខទៅផង ។

**វ** គឺធម៌ដ៏ថ្លៃថ្លាតែងខ្ជាក់ចោលនូវធម៌ថោកមាន **រាគៈ ទោសៈ មោហៈ មិច្ឆាទិដ្ឋិ** និង **អំពើបាប** ។

**តា** គឺធម៌ថ្លៃក្រៃលែងតែងចម្លងសព្វសត្វពីត្រើយអាយទៅដាក់ត្រើយនាយ ។

**ឆ** គឺធម៌កាលព្រះពុទ្ធបានត្រាស់ ហើយព្រះអង្គទ្រង់សំដែងធម៌និរន្តរ៍ ពុំដាច់ជាហេតុនឹងឱ្យឆ្លងចាកសង្សារ ។

**ម្នោ** គឺធម៌ថ្លៃកំចាត់ធម៌មោហោ ហើយធ្វើសត្វដែលមានចិត្ត មោហោឈ្មោះ មោហោ ឱ្យនៅជាឈ្មោះ ។

**ស** គឺមិនមែនធម៌ឯណានោះ ក្រៅអំពីលោកុត្តរធម៌ទាំង ៩ តែងបន្ទោបង់ នូវងងឹត នូវសោក ហើយញ៉ាំងសត្វឱ្យធ្វើ ប្រយោជន៏ជាកុសល ។

**ន្ទិ** គឺធម៌ក្នុងខ្លួនឯង ហើយកាត់បង់នូវធម៌សង្ស័យ គឺ **រាគៈ** គឺ **ទិដ្ឋិ** ប្រែប្រួលជាធម៌ទាប ។

**ដ្ឋិ** គឺជាលោកុត្តរធម៌តាំងសីល សមាធិខ្ជាប់ក្នុងសន្តានខាង ក្នុងហើយពុំបានរំភើបទៅតាមខ្យល់ពីក្រៅឡើយ ។

**កោ** គឺលោកុត្តរធម៌ដ៏ភ្លឺ ឃើញនូវធម៌ខ្វាក់ គឺ **រាគៈ កិលេស តណ្ហា** ហើយហាក់ដូចសម្រាតធម៌ខ្វាក់ផង ។

**អ** គឺលោកុត្តរធម៌ខ្ពស់ឧត្តមក្រៃលែង ហើយធម៌ឧត្តមតែង សួររកនូវបុណ្យដ៏ខ្ពស់ នូវធម៌ដ៏ខ្ពស់ ។

**ភា** គឺលោកុត្តរធម៌តែងជ្រលក់លាងសន្តានសត្វក្នុងឋាន ដែល អស់ទុក្ខប្រព្រឹត្តធម៌ដែលអស់ទុក្ខ ។

**លិ** គឺលោកុត្តរធម៌គួសចិត្តចំណាំកងទុក្ខទាំងអស់ ពុំមានសល់ ហើយគូសខិតបិដកទាំង ៣ ខាងក្នុងហើយលាប គឺស្តាប់ សួរ ។

**ភោ** លោកុត្តរធមិរកអ្វីឱ្យប្រាកដស្មើគ្មានបុគ្គលតែងបូជា តែងសុំរករសក្រឡេករករស ។

**ង** គឺលោកុត្តរធមិ តែងស្វែងរកពុទ្ធរតនៈ ស្វែងរកទៅលើស្វែងរកសួគ៌ និព្វាន ។

**ហិ** គឺលោកុត្តរធមិដ៏ទាបប្រាកដនូវសុគតិទាប៧ គឺមោហោស្មើដូចសំណាញ់ ។

**ម** គឺលោកុត្តរធមិដ៏ប្រសើរធ្វើបំពេញនូវពោធិសម្ភារ ប្រាជ្ញាមុតថ្លា ចិត្តថ្លា គ្មានប្រាជ្ញាណាស្មើក្នុងកងធមិ ។

**ស្សិ** គឺលោកុត្តរធមិទ្រទ្រង់នូវសីលស្អាតគ្រប់ទ្វារទាំងពួង ហើយដល់សុគតិដល់ភោគសម្បត្តិ ដល់សមាបត្តិ ។

**ភោ** គឺលោកុត្តរធមិជម្រះសន្តានរំលូកជាតិកំណើតរៀង៧ជាតិ ហើយលះបង់នូវសេចក្តីក្រោធ ដឹងនូវធមិវិសេសផ្សេងៗ ។

**ខិ** គឺលោកុត្តរធមិញាំងកិលេសសព្វជំពូកឱ្យឱនទាបចុះ នូវបណ្តាញ គឺទិដ្ឋិឱ្យឱនទាបចុះ ញាំងឫសកុសលឱ្យដុះឡើងខ្ពស់ ។

**ម** គឺលោកុត្តរធមិដ៏ប្រសើរ ឱ្យដឹងសព្វប្រការ នូវធមិទាបខ្ពស់ក្នុងលោករកអ្នកណាដឹងប្រហែលគ្មាន ។

៦ គឺលោកុត្តរធម៌មិនជាប្រយោជន៍ដល់នរជនប្រុសស្រី គឺទេវតា ឥន្ទ្រ ព្រហ្ម តែងបូជាហើយញ៉ាំងជនឱ្យវេរខ្លួនចាកផុតពីកាម ។

៧ គឺលោកុត្តរធម៌មិជាពន្លឺប្រទីបភ្លឺស្វាងថែងចាំងត្រចះ ដល់សព្វសត្វ សព្វទេវតាព្រហ្ម តែងបូជាសព្វកាល ។

៨ គឺលោកុត្តរធម៌មិចំអិនបាប សម្លាប់ក្រោធ ហើយដល់នូវឋានសួគ៌ក៏ដល់ដោយងាយ ។

៩ គឺលោកុត្តរធម៌មិដឹងឋានអ្នកផង ហើយលះបង់នូវបាបដោយកាយ ហើយដល់សិរីសុខសួស្តីភ្លឺស្វាងស្រឡះ ។

១០ គឺលោកុត្តរធម៌មិប្រព្រឹត្តព្រហ្មចរិយ ហើយលះបង់ទង្វើអាក្រក់លាមក ហើយនៅតែលះជាប់តជាតិពុំឱ្យចូលបាន ។

១១ គឺលោកុត្តរធម៌មិត្បាញការកុសល ត្បាញព្យាយាមក្នុងសីលសមាធិ ។

១២ គឺលោកុត្តរធម៌មិពុំមានចងពៀរ នឹងអ្នកដែលមានពៀរ ទោះបីពៀរដល់ ហើយបំបាត់ចេញពុំឱ្យចងពៀរ ។

១៣ គឺលោកុត្តរធម៌មិមានអាយុវែង មានប្រាជ្ញាច្រើន មានខ្លឹមក្នុងខ្លួនច្រើន ។

**ត** គឺលោកុត្តរធម៌រហូតផុតចេញពីទុក្ខ ពីកងកិលេស ដោយការព្យាយាមដុះខាត់ឱ្យញឹកញាប់ ។

**ឡោ** គឺលោកុត្តរធម៌ប្រកាសអស់ពពួកទេវតា ជាសាក្សីពេជ្ញញាណ ហើយប្រសើរប្រាកដដោយសម្បត្តិគឺចម្រើន ។

**វិ** គឺលោកុត្តរធម៌ វៀរចាកទុក្ខគ្រប់ជំពូកពីចម្ងាយ ។

**ញ្ញូ** គឺលោកុត្តរធម៌ បរិបូណ៌ដោយដំណឹង ហើយប្រកបដោយដំណឹង ដល់ព្រមហើយឃើញញាណស្ទែង ។

**ហី** គឺលោកុត្តរធម៌ កិនសម្លាប់ទោស សម្លាប់ភ័យ សម្លាប់មោហោ ក្នុងខ្លួនឱ្យបាត់បង់ ។

**តិ** គឺលោកុត្តរធម៌ឆ្លងរំលងទុក្ខក្នុងវដ្ដៈ ហើយឧត្តមលើសលោកទាំង ៣ ហើយឆ្លងភូមិទាំង៣ អន្លង់ទាំង ៣ ។

ធម៌សម្រាប់ភាវនាសងគុណព្រះធម៌

ស្វា ក្ខា តោ ភគវតា ធម្មោ ( ភាវនា ៣៨ចប់)

# ព្រះអាទិត្យគិតប្រយោជន៍សត្វលោក

## ( សុភាសិត )

\+ ពាលរលត់ទៅដោយបណ្ឌិត ងងឹតរលត់ទៅដោយពន្លឺ
ពេលថ្ងៃព្រះអាទិត្យគិតតែបញ្ចេញពន្លឺ ពេលយប់នោះគឺភារកិច្ចព្រះចន្ទ ។

\+ ព្រះអាទិត្យគិតទៅចេះសម្របខ្លួន ប្តូរវេនមាសស្ងួនជូនដល់ព្រះចន្ទ
បំភ្លឺជូនសត្វពេញទាំងភពផាន់ ប្តូរចាស់ផ្លាស់កាន់ការពារងងឹត ។

\+ ព្រះអាទិត្យគិតប្រយោជន៏សត្វលោកជាធំ ខ្ញុំថ្វាយបង្គំសុំកោតសរសើរ
ព្រះអង្គឧត្តមយើងខ្ញុំសុំស្នើ ទ្រង់ទតពីលើមើលមកភពពិត ។

\+ ព្រិច១រំលេចក្នុងពន្លឺផ្កាយ សព្វសត្វសប្បាយមិនណាយព្រះអាទិត្យ
ព្រះចន្ទចូលមកព្រះអង្គទ្រង់គិត ខ្លាចភពងងឹតឥតមានឱភាស ។

\+ សូមមេដឹកនាំលោកអធ្យាស្រ័យ ប្តូរចាស់ផ្លាស់ថ្មីមេត្តាដល់រាស្ត្រ
តាមច្បាប់ធម្មនុញ្ញទើបមិនវិនាស គោរពតាមរាស្ត្រសុខអង្វែងឆ្នាំ ។

\+ គេថាឆ្លាតពេកទៅជាល្ងង់ ធ្លាក់ខ្លួនជាប់ផុងក្នុងអន្លង់កម្ម
ត្រួតត្រាដឹកនាំអស់ជាច្រើនឆ្នាំ លោកបានផ្សាំដាំពូជទោសៈ ។

\+ ដឹកនាំធ្វើខុសរាស្ត្ររស់ភិតភ័យ ដឹកនាំប្រពៃរាស្ត្ររស់សុខសាន្ត
យកច្បាប់ព្រះពុទ្ធធ្វើជាលំអាន ពេលនោះរាស្ត្របានសុខតាមលំដាប់ ។

\+ អ្នកដែលឆ្លាតពិតគឺគិតដល់រាស្ត្រ  អ្នកដែលរវៀសគឺគិតដល់ច្បាប់
កុំជឿទុកចិត្តក្រុមខ្លួនមួយក្តាប់  អ្នកនោះគេប្រាប់គ្រាន់តែលើកជើង ។

\+ មានទុក្ខមានទោសព្រោះអ្នកតម្កើង  ប្រទេសឆេះភ្លើងដោយសារបណ្ឌិត
បណ្ឌិតត្រូវគិតរាស្ត្រនិងប្រទេស  បណ្ឌិតស្វាក្រិសចេះតែខាងខូច ។

( ចប់ )

សូមអនុមោទនា

ធមិសំរាប់ការនាសងគុណព្រះត្រៃបិដក

ម អ ឧ ( សូត្រ១០៨ចប់ )

**<u>សង្ឃគុណ</u>**

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**សង្ឃំ វន្ទាមិ**

សុប៉ាក់ដិប៉ាន់ណោ  ភាក់គាក់វាក់តោ
សាវ៉ាក់កាក់សាំងឃោ  សាំងឃាំង វ៉ាន់ទាមិ

( ក្រាបថ្វាយបង្គំ )

# ព្រះសង្ឃជាមាសពេជ្រ

## ( បទពាក្យ ៨)

+ សង្ឃប្រណាម[១] ច្បាមយកសង្ឃគុណ វិសេសលើសលន់សង្ឃគារវតា[២]
ឧបាសក និង ឧបាសិកា សង្ឃមានដីកាមេត្តាសូមស្តាប់ ។
+ ត្រូវសម្រួលដល់សង្ឃករណីកិច្ច ហើយសូមកុំភ្លេចនូវពាក្យសង្ឃប្រាប់
ជាសង្ឃបញ្ជា[៣] តាមពុទ្ធតម្រាប់ សង្ឃទូត[៤] យកច្បាប់ធ្វើសង្ឃកម្ម[៥] ។
+ សូមកូនកុំភ្លេចថ្វាយសង្ឃភត្ត លោកចេញពីវត្តបិណ្ឌជាប្រចាំ
ពីរអង្គបីអង្គរៀងរាល់ខែឆ្នាំ នេះកូនត្រូវចាំធ្វើកុំប្រហែស ។
+ កូនអើយកុំភ្លេចសង្ឃានុស្សតិ[៦] ចូរកូនគារវៈស្ទាក់ស្តាប់លោកទេសនី
ទោះបីនៅវត្ត ឬ ក៏នៅផ្ទះ តាមពុទ្ធតម្រាស់ច្បាស់ជាមានភ័ព្វ ។
+ កូនអើយព្រះសង្ឃជាស្រែបុណ្យល្អ សង្ឃដ៏បវរគោរពគួរគាប់
ជាសង្ឃរតនៈ មានច្បាប់ទម្លាប់ វិន័យកាន់ជាប់ជាសង្ឃសាវ័ក ។

---

(១) **សង្ឃប្រណាម** = ការង្គោនកាយវាចាថ្វាយបង្គំចំពោះសង្ឃគុណ ។
(២) **សង្ឃគារវតា** = សេចក្តីគោរពចំពោះសង្ឃ ។
(៣) **សង្ឃបញ្ជា** = ពាក្យបង្គាប់ ឬពាក្យផ្តាំផ្ញើររបស់ព្រះសង្ឃ ។
(៤) **សង្ឃទូត** = បម្រើសង្ឃ ឬ តំណាងសង្ឃ ។
(៥) **សង្ឃកម្ម** = ការងាររបស់សង្ឃដោយប្រជុំគ្នាធ្វើក្នុងសីមា ។
(៦) **សង្ឃានុស្សតិ** = សេចក្តីរព្ទកដល់សង្ឃគុណ ។

+ កូនម៉ែ កូនឪ កូនត្រូវតែឆ្លាត ស្ដាប់ពុទ្ធឱវាទចូរសូធ្យ[៧] គារវៈ
ដាក់បាត្រឧទ្ទិសផលកុំស្មើរស្មាក់ ឆ្ពោះសង្ឃសាវ័កអ្នកបានបុណ្យច្រើន។
+ វត្តប្រតិបត្តិចូរកូនកុំភ្លេច សង្ឃជាមាសពេជ្រឪរំឭកក្រើន
ខ្លាចក្រែងកូនភ្លេចឪសូមដាស់តឿន បើកបរកុំល្មើនក្នុងវត្តឱ្យសោះ។

(ចប់)

សូមអនុមោទនា

## អធិប្បាយ

## សូមតាំងចិត្តរឭកដល់សង្ឃគុណ

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ

យទិទំចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯសភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិនេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

---

(៧) **សូធ្យ** = សូត = សូត្រ = ការថ្លែងអំណរ, បញ្ចេញវាចាថ្លែងសេចក្ដី ។

## ព្រះសង្ឃគុណៈ

ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិ ហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌។ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា (១)។ ព្រះសង្ឃសាវ័កនៃ ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវ ព្រះនិព្វានជាស្ពានក្បៀមបំផុតចាកទុកទាំងពួង ។ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ **សីល សមាធិ បញ្ញា** ។ ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤គូ គឺព្រះសង្ឃ ដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផល ជាគូ ១ អនាគាមិមគ្គ និង អនាគាមិផលជាគូ ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ ។ បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ ១ អរហត្តផល ១ ។ ព្រះសង្ឃទាំងនោះ ជាសាវ័កនៃព្រះដ៏មាន ព្រះភាគលោកគួរ

(១) **មជ្ឈិមប្បដិបទា** (សូមមើលក្នុងសៀវភៅកំណាព្យធម៌ភាគ ៣ ត្រង់ទំព័រ ៨១)

ទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នក មានសីលហើយនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា ។ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា ។ លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា ។ លោកគួរដល់អញ្ជលីកម្មដែលសត្វលោកគប្បីធ្វើ ។ លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺ បុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

## ប្រែសព្ទមួយៗក្នុងសង្ឃគុណនេះ

- **នព្វលោកុត្តរធម៌** គឺធម៌ចម្លងសត្វឱ្យឆ្លងផុតចាកលោក គឺមគ្គ ៤ ផល ៤ និព្វាន ១ ។
- **សាមីចិកម្ម** គឺកិច្ចការត្រឹមត្រូវ( គួរដល់**សីល សមាធិ បញ្ញា** )
- **សោតាបត្តិមគ្គ និង សោតាបត្តិផល** គឺជាឈ្មោះលោកុត្តរធម៌ ១គូ ដែលព្រះអរិយបុគ្គលអ្នកបានសម្រេចថ្នាក់សោតានេះ ។
- **សកទាគាមិមគ្គ និង សកទាគាមិផល** គឺឈ្មោះមគ្គនិងផលជាលោកុត្តរធម៌របស់ អរិយបុគ្គលអ្នកត្រឡប់មកកើតលោកនេះម្តងទៀតជាកំណត់ ។

- **អនាគាមិមគ្គ និង អនាគាមិផល** គឺជាមគ្គ និងផល របស់អរិយបុគ្គលដែលបានសម្រេចផលទី ៣ នៃលោកុត្តរធម៌ ហើយលុះអស់អាយុ អំពីជាតិនេះតែងតែទៅកើតក្នុងសុទ្ធាវាសព្រហ្ម[១] លោកបានសម្រេចអរហត្តផលហើយ បរិនិព្វាន ក្នុងទីនោះ ។
- **អរហត្តមគ្គ និង អរហត្តផល** គឺជាមគ្គ និងផលក្នុង លោកុត្តរធម៌ថ្នាក់ខ្ពស់បំផុតដែលព្រះអរហន្តបានសម្រេច ។ អរហត្តផលគឺជាឈ្មោះ លោកុត្តរធម៌ទី ៤ ឬ លោកុត្តរធម៌ ថ្នាក់ ៨-៤ អរហត្តមគ្គវិញជាឈ្មោះលោកុត្តរធម៌ទី ៤ ឬ លោកុត្តរធម៌ ថ្នាក់ទី ៧ ។

**ប្រែព្រះសង្ឃគុណទាំង១៤បទលម្អិតបន្តទៀត គឺយកតែអក្ខរៈមួយៗ មកប្រែខ្លីតាមបទដែលចេញមកពីបាលី**

**ដែលខ្ញុំបាទបានដកស្រង់ចេញពី សៀវភៅតិបិសោរតនៈមាលា ។**

**សុ** គឺព្រះសង្ឃប្រកបដោយសីលហ្មត់ចត់ សាសនាហ្មត់ចត់ ។

**ប** គឺព្រះសង្ឃប្រកបដោយបដិសម្ភិទាញាណទាំង ៤ ដ៏ប្រសើរ ដោយវិសេសក្នុងលោក ។

**ដិ** គឺព្រះសង្ឃជាតំណាងតែងផ្ចាលផ្ចាញ់ចិត្តដែលស្អុះ ទៅកាន់ លទ្ធិដទៃញ៉ាំងឱ្យឱនចូលក្នុងវង្សនៃព្រះពុទ្ធ ។

**ប** គឺព្រះសង្ឃប្រសើរដោយធម៌ជ្រៅ ប្រាជ្ញាសង្រួមរម្ងាប់ឥន្ទ្រីយ៍ ចោលប្រាថ្នានូវអត្ថធម៌ ។

**ន្នោ** គឺព្រះសង្ឃតែងគិតតែការកុសល មិនខ្វល់ធ្វើការបាបសុភាព តែភ្ជាក់រឭកនូវធម៌ ។

**ភ** គឺព្រះសង្ឃតែងបំបាត់ទោស បំបាត់មោហោ ហើយក្តិចឱ្យក្រិន នូវកងកិលេស ទាំងពួង មានលោភៈ ជាដើម ។

**គ** គឺព្រះសង្ឃដល់លោកិយធម៌ និងដល់នូវលោកុត្តរធម៌ផង ហើយញ៉ាំងកិលេសទាំងពួងឱ្យអស់ទៅ ។

**វ** គឺព្រះសង្ឃពិពណ៌នានូវការកុសល នូវបរិបូរណ៍សីល ដោយពិតត្រង់ពុំបានពណ៌នាដោយលោភៈ ។

**តោ** គឺព្រះសង្ឃញ៉ាំងមនុស្ស និងទេវតាឱ្យត្រេកអរក្នុងរសធម៌ និងញ៉ាំងសត្វដែល ប្រទូសរ៉ាយ និងគ្នាឱ្យអរវិញ ។

**សា** គឺព្រះសង្ឃបិទបាំង ដោយល្អនូវសាសនា សិក្សាសាសនាជាទីក្សាន្តចិត្ត ។

**វ** គឺព្រះអរិយសង្ឃខ្ជាក់នូវ **រាគៈ ទោសៈ មោហៈ ទិដ្ឋិ** និង**បាប** ទាំងពួងឱ្យបង់ដូចជាការស្តោះទឹកមាត់ចោល ។

**ក** គឺព្រះសង្ឃផ្ចង់ហើយធ្វើសមាធិ ធ្វើផលប្រយោជន៍ដល់ខ្លួន និងធ្វើផលប្រយោជន៍ដល់សត្វទាំងពួងដទៃ ។

**ស** គឺព្រះសង្ឃកាលអន្ទោលទៅក្នុងសង្សារ ក៏សង្វាត ព្យាយាមឱ្យរួច ចេញ ពីសង្សារហើយញ៉ាំងសត្វឱ្យរួចពីសង្សារ ។

**ខ្លោ** គឺព្រះសង្ឃធ្វើឱ្យក្បួយទុក្ខដ៏ពន្លឹក ហើយផ្សព្វផ្សាយបិដកទាំង ៣ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ ។

| |
|---|
| ធមិសម្រាប់ភាវនាសងគុណព្រះសង្ឃ<br>សុបដិបន្នោភគវតោ សាវកសង្ឃោ (សូត្រ១៤ចប់) |

# បុត្រខេមរាសច្ចាសុំ

## (សុភាសិត)

- សូមដល់ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ
ទីពឹង ល្អខ្ពង់ ក្នុង ពុទ្ធសាសនា
បិដក នៅមាន ចំរៀន ធម៌អាថ៌
ឱ្យបានសាស្ត្រា អស្ចារ្យ ណាស់បាន ។
- បុត្រខេមរា ប្រាថ្នា សេចក្តីសុខ
ពេលនេះ ទៅមុខ ទុក្ខភ័យ លែងមាន
រួមចិត្ត រួមគិត បរិច្ចាគ ធនធាន
ធ្វើបុណ្យ ធ្វើទាន សូមមាន មង្គល ។

# ធ្វើស្រូវត្រូវពិនិត្យស្រែ

## ( កាព្យរាយ )

+ ស្រូវប្រាំងវស្សា អ្នកស្រែចម្ការ ធ្វើតាមរដូវ
មានដំណើបខ្សាយ ទៅតាមតម្រូវ ស្រែណាជិតផ្លូវ
ឱ្យដាក់ដំណើប ។

+ ស្រែទួលស្រែទាប ស្រែណាទំនាប ដាក់ស្រូវពង្រោះ
ផ្កាខ្ចីបាយឆ្ងាញ់ ស្ទូងវិញកុំព្រោះ ស្រែម៉ែទាំងនោះ
ជាស្រែស្រូវប្រាំង ។

+ ស្រូវត្រូវការជី ព្រះសង្ឃមូលមីរ ត្រូវការវិន័យ
ស្រូវត្រូវការទឹក អាស្រ័យមានដី សង្ឃរតនត្រ័យ
ល្អក្រៃព្រោះសីល ។

+ ឧបាសកឧបាសិកា គាត់តែងប្រាថ្នា បុញ្ញក្ខេត្តស្រែបុណ្យ
ស្រែទាបមានទឹក ស្រូវលាស់ល្អលន់ ស្រែទួលទោះបន់
ក៏ផលបានតិច ។

\+ បើយើងធ្វើស្រូវ ឱ្យប្រាកដត្រូវ សូមមើលនូវស្រែ
ស្រែតូច ឬ ធំ ស្រែឪ ស្រែម៉ែ ស្រែនោះទាល់តែ
ទំនាបស្មើល្អ ។

(ចប់)

សូមអនុមោទនា

* ៦. ផឹក ស្រា ក្លែប ស្រី នាំខ្ចី វិជ្ជា
ស្រើប ស្រាល នាំគ្នា ស្រាប់តែ ស្រាលខ្លួន
អស់ ទ្រព្យសម្បត្តិ ព្រោះ ស្នេហ៍ នឹមនួន
ស្រុតចុះ ធ្លាក់ខ្លួន ស្រេច ហើយ ប៉ា វ៉ា ។

* ៧. ស្រា ស្រី ស្រោច ស្រព កប់ខ្លួន នាំទុក្ខ
ស្រាល ខ្លួន ស្រណុក ទុក ស្រា ចោល ស្រី
បែរ មក រកត្រូវ ផ្លូវ ដ៏ ប្រពៃ
ទាន សីល ល្អក្រៃ ទាំងថ្ងៃ ទាំងយប់ ។

# បុណ្យភ្ជុំបិណ្ឌ

## ( បទពាក្យ ៤)

+ ឧកាសៈខ្ញុំព្រះករុណា សូមលើកហត្ថាឱនសិរសី
បង្គំគុណកែវព្រះរតនត្រៃ នឹងអរហន្តថ្លៃប្រពៃអស្ចារ្យ ។
+ យើងជាកូនខ្មែរត្រូវតែធ្វើបុណ្យ កតញ្ញូដឹងគុណមាតាបិតា
បុណ្យភ្ជុំកាន់បិណ្ឌ(១) គួរឱ្យជ្រះថ្លា ទៅវត្តទៅវ៉ាត្រៀបត្រាតាមផ្លូវ ។
+ ដល់ថ្ងៃ១រោចខែភទ្របទ ទោះបីក្រខ្សត់អាណិតម៉ែឪ
ធ្វើបាយសម្លសម្រាំងត្រឹមត្រូវ ដាក់ស្រោក់យកទៅថ្វាយដល់ព្រះសង្ឃ ។
+ ថ្វាយបង្គំសុំសីលតាំងសទ្ធា ឧទ្ទិសផលាយកអានិសង្ស
ជូនញាតិកាដែលបានស្លាប់បង់ ភ្លាត់ខ្លួនធ្លាក់ផុងក្នុងភូមិអបាយ ។
+ ដូចជាញាតិព្រះបាទពិម្ពិសារ ជាប្រេតខ្មោចផ្សាគួរឱ្យសោកស្តាយ
សោយទុក្ខយូរណាស់ព្រោះរឿងហូបបាយ ត្រូវគិតវែងឆ្ងាយកុំបាយមុនលោក ។
+ បុណ្យភ្ជុំប្រមូលផ្តុំក្រុមគ្រួសារ ស្នៀកពាក់ហ៊ឺហាតម្រោគរគោក ។
ស្លៀកឱ្យត្រូវក្បួននឹងបានជ័យជោគ ម៉ែពុកប្រាប់មកកុំស្លៀកពាលា
+ តាមប្រពៃណីនារីខ្មែរយើង ហូលជ័រល្អថ្កើងត្រូវមានស្ពានា ។
ផាមួងអាវប៉ាក់ជាអ្នកចិត្តជា ត្រូវកាលវេលាក្នុងគ្រាធ្វើបុណ្យ ។

---

(១) **បុណ្យភ្ជុំបិណ្ឌ ឬ បុណ្យកាន់បិណ្ឌ** (សូមមើលក្នុងអត្ថាធិប្បាយ)

\+ ពីថ្ងៃ១រោចដល់ថ្ងៃ១៥ ចូរយើងចងចាំអរិយគុណ
មាតាបិតាលោកមានគុណធ្ងន់ បាយទឹកជូនមុនហើយចាំទៅវត្ត ។
ណាកូនណា !

(ចប់)

សូមអនុមោទនា

## <u>អត្ថាធិប្បាយ</u>

**បុណ្យភ្ជុំបិណ្ឌ និង កាន់បិណ្ឌនេះ** បើតាមបុព្វវីរៈសប្បុរស ដែលជាពុទ្ធសាសនិកជំនាន់ក្រោយពុទ្ធកាល បានប្រារព្ធធ្វើបុណ្យនេះតាំងពីអតីតកាលតរៀងមក ទៅតាមគម្ពីរបេតវត្ថុខ្លះ ទៅតាមគម្ពីរ វិមានវត្ថុខ្លះទៀតទៅតាមគម្ពីរពិទ្យាធរ និងគម្ពីរធម្មបទជាដើម ដែលមានដំណាលពីរឿងប្រេតជាញាតិព្រះបាទពិម្ពិសារ ពីរឿងព្រានស្លាប់ទៅកើតជាប្រេត សៀត ផ្កាប្របែកព្រៃ និង ពីរឿងព្រះមហាមោគ្គល្លាន លោកបានឃើញប្រេតទាំងនោះកំពុងតែសោយទុក្ខដ៏ខ្លាំងក្លា និងឃ្លានអាហារជាទីបំផុតតាមអំពើកម្មរបស់ខ្លួនម្នាក់ៗដែលបានធ្វើហើយ ពួកគេក៏បានផ្តាំមកញាតិសន្តានកូនចៅឱ្យធ្វើបុណ្យបញ្ជូនទៅឱ្យពួកគេជាប្រេតផង ។

អាស្រ័យហេតុនេះទើបនាំគ្នាកំណត់កាន់បិណ្ឌពីថ្ងៃ ១រោច ខែភទ្របទ ដល់ ១៥រោច ជាថ្ងៃភ្ជុំបង្ហើយ ។ នេះជាទំនៀម ទំលាប់ល្អមួយរបស់សប្បុរសខ្មែរយើង ។

បុណ្យភ្ជុំបិណ្ឌនិងកាន់បិណ្ឌនេះ បើនិយាយតាមលំនាំពុទ្ធបរិស័ទ ដែលធ្វើក្នុងសម័យនោះ មិនកំណត់ធ្វើនៅថ្ងៃ១រោច ខែភទ្របទ ទៅទល់ដល់ ថ្ងៃ១៥រោចភ្ជុំបិណ្ឌមានរយៈពេលតែ១៥ថ្ងៃដូច្នេះទេ គឺពុទ្ធបរិស័ទជំនាន់នោះចាប់កាន់បិណ្ឌតាំងពីថ្ងៃចូលវស្សា ទៅ ទល់នឹងថ្ងៃចេញវស្សាទើបឈប់ ។ ហើយពេលកាន់បិណ្ឌនោះ មិនមែនប្រគេនតែចង្ហាន់ និងភេសជ្ជៈ ដូចសព្វថ្ងៃនេះប៉ុណ្ណោះទេ គឺទំនុកបំរុង បច្ច័យ៤មានត្រៃចីវរ សង់ទីសេនាសនៈ ប្រគេនភិក្ខុ សង្ឃដែលគង់ចាំ ព្រះវស្សាជិតស្រុកភូមិរបស់ខ្លួនគ្រប់បីខែ ប៉ុន្តែ ឥឡូវនេះមានវត្ត និងអាស្រមមួយចំនួន ដែលដឹកនាំដោយ លោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** និង ព្រះអង្គមេត្តាបាលោ **ទឹម សឿត** ព្រះអង្គ **សាន សប្បាយ** ជាដើម បានញ៉ាំង សទ្ធាជ្រះថ្លាដល់ពុទ្ធបរិស័ទឱ្យដាក់វេន បិណ្ឌជួយទំនុកបំរុងព្រះសង្ឃ មិនត្រឹមតែ៣ខែពីថ្ងៃចូលវស្សាដល់ចេញវស្សាប៉ុណ្ណោះទេ ថែម ទាំងបានជួយទំនុកបំរុងព្រះសង្ឃរហូត គឺមួយឆ្នាំពេញមួយឆ្នាំតែ ម្តង ត្រង់នេះវាអាស្រ័យទៅលើសទ្ធាជ្រះថ្លារបស់មន្ត្រីរាជការ និង

ពុទ្ធបរិស័ទតែប៉ុណ្ណោះ លោកមិនបង្ខំយើងទេ ។ ក្នុងគម្ពីរធម្មបទ មានរឿងរាវព្រះពុទ្ធ និងភិក្ខុសង្ឃគង់ចាំវស្សា ហើយមានពុទ្ធបរិស័ទទំនុកបំរុងបច្ច័យបួនយ៉ាងច្រើនអស់មួយត្រីមាស ហើយគ្រាន់តែខុសពាក្យវប្បធម៌គ្នាប៉ុណ្ណោះ ព្រោះក្នុងជំនាន់ពុទ្ធកាលគ្មានពាក្យថា **ភាន់បិណ្ឌ ភ្ជុំបិណ្ឌ** ដូចសព្វថ្ងៃទេ មានតែពាក្យថា បវារណាបច្ច័យបួន ឬទំនុកបំរុងបច្ច័យបួន ដូច្នេះវិញ ។

**បុណ្យភ្ជុំបិណ្ឌនេះមានន័យបីយ៉ាងគឺ :**

១- ធ្វើឧទ្ទិសកុសលចំពោះបេតបុគ្គល ឬ ប្រេតបុគ្គលមានមាតាបិតា ញាតិកានៅក្នុងសង្សារវដ្តទាំងអស់ ដែលបានចែកឋានទៅកាន់បរលោក ហើយទោះបីទៅកើតនៅទីណាកើតជាអ្វីក៏ដោយ ។

២- ធ្វើឱ្យបានសេចក្តីសុខចម្រើន មានសិរីសួស្តី ដែលកើតពីផលទាន ដែលជាអំពើល្អរបស់ខ្លួន ។

៣- ធ្វើដើម្បីបង្កើតសាមគ្គីធម៌ របស់សង្គមជាតិ ដែលធ្លាប់មានប្រពៃណីល្អជាយូរលង់មកហើយ តាំងពីសម័យពុទ្ធកាលមកម្ល៉េះ ដូចជាក្នុងរឿងញាតិរបស់ព្រះបាទពិម្ពិសារ ដែលកើតទៅជាប្រេតអស់កាលដ៏យូរអង្វែង តាំងពីព្រះពុទ្ធមុនៗមករហូតដល់ព្រះពុទ្ធព្រះនាម គោតមយើងនេះ ទើបបានទទួល

អាហារដោយការឧទ្ទិសផលរបស់ ព្រះបាទពិម្ពិសារ និងការ អនុមោទនាទានមានព្រះពុទ្ធជាប្រធានក្នុង កាលនោះដោយ (តិរោកុឌ្ឌសូត្រ) ជាដើម ហើយពួកប្រេតនោះបានទទួល ផលហើយក៏បានទៅកើតក្នុងទិព្វវិមានអស់ទៅ ។

## អំពីការពូនភ្នំខ្សាច់

**ស** តើហេតុអ្វីបានជាមានការពូនភ្នំខ្សាច់ នៅពេលបុណ្យ ភ្ជុំបិណ្ឌនៅ តាមវត្តអារាម ?

**ឆ** បាទ នេះជាប្រពៃណី និងទំនៀមទំលាប់របស់សប្បុរសខ្មែរ តាំងពី យូរលង់មកហើយ ។

**ស** តើទំនៀមទំលាប់ពូនភ្នំខ្សាច់របស់ សប្បុរសខ្មែរយើងមាន ន័យ និងសារប្រយោជន៍អ្វីដែរឬទេ ? ។

**ឆ** បាទមានសារសំខាន់ណាស់ **ទី១:** លោកពូនភ្នំខ្សាច់នេះ ឧទ្ទិសចំពោះព្រះសក្យមុនីចេតិយ ឬព្រះចូឡាមុនីចេតិយ ដែលជាអាសនៈ សំរាប់តម្កល់ព្រះបរមសារីរិកធាតុ និង ព្រះចង្កូមកែវ ។ **ទី២:** បុព្វបុរសខ្មែរ ចង់រំឭកយើងរឿយៗ ឱ្យនឹកដល់ព្រះពុទ្ធគុណ ព្រះធម្មគុណ និងព្រះសង្ឃគុណ ជាប់ជានិច្ច ។

**ស** ចុះហេតុអ្វីបានជាគេថាពូនភ្នំខ្សាច់ ដើម្បីផ្តាច់កម្មពៀរទៅវិញ?

**ច** បាទ,ត្រង់នេះមិនទាន់ត្រឹមត្រូវតាមច្បាប់ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងទុកនៅឡើយទេ គឺវាគ្រាន់តែជាការសន្មតរបស់ អាចារ្យ ដែលបានដឹកនាំធ្វើតែប៉ុណ្ណោះ ។

**ស** ចុះហេតុអ្វីបានជាថាមិនត្រូវទៅវិញនោះ ?

**ច** បាទ,ព្រះពុទ្ធអង្គទ្រង់សំដែងថា **កម្មជាគ្រាប់ពូជ** ដូចនេះបើយើងដាំពូជណាវានឹងឱ្យផលទៅតាមពូជនោះ **ឧទាហរណ៍ :** បើយើងដាំ ពូជស្វាយ វានឹងផ្លែមកស្វាយ បើយើងដាំ ពូជដូង វានឹងផ្លែមកដូង មិនអាចដាំពូជដូង ហើយសុំឱ្យផ្លែមកធូរេនបានទេ យ៉ាងណាមិញ អំពើដែលសត្វលោកបានធ្វើហើយនឹង ទទួលផលទៅតាមអំពើ កម្មនោះៗ ។

**ឧទាហរណ៍ :**

- ធ្វើទានគឺដាំពូជសម្បូរទ្រព្យឱ្យផលមក ជាអ្នកមានទ្រព្យច្រើន
- មិនសម្លាប់ជីវិតសត្វ គឺដាំពូជអាយុវែង ឱ្យផលមកជាអ្នកមានអាយុវែង ។
- មិនលួចទ្រព្យអ្នកដទៃ ដាំពូជមាននិងពូជសុខទុកឱ្យផលមកជាអ្នកមានទ្រព្យសម្បត្តិហើយមានសេចក្តីសុខ។

- លួចទ្រព្យអ្នកដទៃ ដាំពូជក្រីក្រទុក ឱ្យផលមកជាអ្នកក្រីក្រលំបាកតោកយ៉ាក ឬ ចោរលួចទ្រព្យដែលខំរកបាន ។
- និយាយកុហក ដាំពូជមិនពិតទុក ឱ្យផលមកជាអ្នកត្រូវគេបោកប្រាស់ កុហក ហើយរាងរៅមិនស្អាត បើខ្ពស់គឺខ្ពស់ពេក បើទាបគឺទាបពេក បើធាត់គឺធាត់ពេក បើស្គមគឺស្គមពេក មិនតែប៉ុណ្ណោះមានក្លិនមាត់មិនល្អទៀតផង ។

ដូច្នេះ សូមពិចារណាមើលដោយខ្លួនឯងចុះ ហើយបើនាំគ្នាយល់ខុស ថាពូនភ្នំខ្សាច់ដើម្បីផ្តាច់កម្មពៀរនោះអញ្ចឹងរឹតតែ បានដៃចំពោះជនដែលប្រព្រឹត្តអំពើអាក្រក់ ដូចជា ចោរលួច ចោរប្លន់ ចោរឆក់ និងអ្នកកាប់សម្លាប់គេ ធ្វើបាបគេជាដើមនោះ ច្បាស់ជាទៅពូនភ្នំខ្សាច់មុនគេ ហើយបន្ទាប់ពីពូនភ្នំខ្សាច់ រួចក៏បន្តប្រព្រឹត្តនូវអំពើអាក្រក់ របស់គេមកលើអ្នកទន់ខ្សោយទៀតជាមិនខានឡើយ ។

ធម៌សម្រាប់ភាវនាសងគុណព្រះអភិធម្ម
សំ វិ ធា បុ ក យ ប ( សូត្រ១០៨ចប់)

# លៃបណ្តុះពូជបុណ្យឱ្យទាន់រដូវ

## ( សុភាសិត )

\- ដល់ពេល បុណ្យភ្ជុំ ធ្វើនំ អន្សម
ព្រមទាំង នំគម នំជាល ថែមទៀត
នំនៀមនំលាប់ ជាប់ត មិនឃ្លាត
ប្រពៃណីជាតិ និង វប្បធម៌ (១) ។

\- ឱ្យខេមរបុត្រ ប្រុសស្រី មាសឳ
វប្បរដូវ (២) ចូលមក ដល់ហើយ
ចូរខំ ខ្នះខ្នែង កុំធ្វើ កន្តើយ
រដូវ ហ្នឹងហើយ បង្កើត ធនធាន ៗ

\- ហៃកូន ប្រុសស្រី លៃបណ្តុះពូជបុណ្យ
គឺការ ដឹងគុណ មាតាបិតា
ប្រពៃណី ពូជនេះ សែនល្អ អស្ចារ្យ
ពូជ ព្រះសាស្តា ចារទុក ឱ្យយើង ៗ

---

(១) **វប្បធម៌** = ការផ្សាំបណ្តុះចំណេះវិជ្ជា និងប្រាជ្ញាស្មារតីឱ្យបានលូតលាស់ចម្រើនដោយវិទ្យាសាស្ត្រ ឬ ដោយសិល្បៈផ្សេងៗជាដើម ។

(២) **វប្បរដូវ** = គឺរដូវសាបព្រោះ ។

- បុណ្យបុកនឹងបុណ្យ កូនអើយ កុំឱ្យបាត់
បាប ត្រូវប្រយ័ត្ន កូនគិត ឱ្យច្បាស់
ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ល្អល្អះ
កូនអើយ រួតរះ សំពះ សុំសីល ៥

(ចប់)

សូមអនុមោទនា

* ៨. ពេល អស់សង្ឃឹម ញញឹម មិនចេញ
កើតទុក្ខ ទោម្នេញ ពេញក្នុង ចិន្តា
អ្នកខ្លះ គិតខ្លី ទៅ ស្ពាន ជ្រោយចង្វា
លោត ចូល ជលសា បញ្ចប់ ជីវិត ។

* ៩. កូនអើយ ត្រូវគិត ជីវិត យើងថ្លៃ
រស់នៅ សព្វថ្ងៃ លៃលក ពិចារណៅ
សេពគប់ សប្បុរស ក្នុង ពុទ្ធសាសនា
ជីវិត ភ្លឺថ្លា វាសនា មាន ភ័ព្វ ។

# បុណ្យមិនទាន់ពេញយំកិច្ចាបន្ថែម

## ( សុភាសិត)

- គេថា សូធ្យធម៌ មិនចេះប្រែ
បានបុណ្យ ខ្លះដែរ តែ មិនពេញ
បើចេះ ប្រែផង ទើប ចំណេញ
រីឯរឹត ទន្ទេញ ព្រោះ បានយល់[១] ។
- បើចេះ សូធ្យធម៌ កុំភ្លេច ធ្វើទាន
ព្រះសង្ឃ នៅមាន ធ្វើទាន បានបុណ្យ
អ្នកក្រ អ្នកខ្សត់ អ្នកមានទុក្ខធ្ងន់
ហើយត្រូវ ដឹងគុណ មាតាបិតា ។
- លោក សូធ្យតិរោក រាល់តែព្រឹក
យំកិច្ចា ប្រួចទឹក ថែមយថា
បញ្ជូន អានិសង្ស ដល់ដូនតា
ជូនតាម ទេវតា ប្រាថ្នា បានសុខ ។

(ចប់)

សូមអនុមោទនា

(១) **យល់** = យល់អត្ថន័យក្នុងព្រះធម៌ ។

# បុណ្យបូជាព្រះចន្ទ

## ( បទពាក្យ ៤)

+ សំពះព្រះខែខ្មែរយើងនិយម មូលមីរជួបជុំផ្គុំគ្នាមុខវាំង
តាមវត្តអារាមមិនដែលភ្លេចភ្លាំង តាមផ្ទះទូទាំងក្នុងផ្ទៃប្រទេស ។
+ បុណ្យបូជាព្រះចន្ទកាន់ឱ្យជាប់ ទៅតាមទម្លាប់កុំបីមានធ្វេស
កូនចៅប្រុសស្រីខំស្ដាប់លោកទេសន៏ និងអ្នកដែលចេះច្បាប់ពុទ្ធតម្រា ។
+ កូនអើយប្រុងប្រៀបរៀបធ្វើឱ្យចំ កុំឱ្យច្រឡំក្រែងខុសសាសនា
សំពះព្រះខែដោយចិត្តជ្រះថ្លា ទន្សាយអស្ចារ្យព្រះពោធិសត្វ ។
+ ព្រះអង្គបំពេញបារមីទាន ជីវិតដែលមាននៅក្នុងព្រៃស្ងាត់
ព្រះឥន្ទលោកជ្រាបក៏ហោះមកស្កាត់ ដោយករុណាចិត្តក្លាយខ្លួនជាព្រាហ្មណ៏ ។
+ ថ្ងៃពេញបូណ៌មីរាត្រីពេញវង់ ព្រាហ្មណ៏ប្រាប់តាមត្រង់ថាចង់ហូបសាច់
ពេលភ្លើងឆេះឡើងពោធិត្រៀមស្រេច ស្ទុះលោតទៅប៉ាច់មិនបង្អង់អី ។
+ ដោយបុណ្យបារមីនៃជីវិតទាន ពេលនោះហេតុមានដ៏អស្ចារ្យក្រៃ
ភ្លើងមិនអាចឆេះរោម១សរសៃ ឥន្ទព្រាហ្មណ៏គាត់ឆ្ងែថ្ងជាសទ្ធា ។
+ គូររូបទន្សាយឱ្យក្លាយជានាម ស្នាដៃឥន្ទព្រាហ្មណ៏ក្នុងវង់ចន្ទ្រា
រឿងនេះជាប់តំណ តជាតិជា ប្រាថ្នាពុទ្ធា រហូតសម្រេច ។

( ចប់ )

## សូមអនុមោទនា

**ស** តើពិធីបុណ្យសំពះព្រះខែអកអំបុកដែលខ្មែរយើង ធ្វើជារៀងរាល់ឆ្នាំនោះត្រឹមត្រូវដែរឬទេ ?

**ច** បាទ, ត្រឹមត្រូវល្អណាស់ **ទី១** គឺយើងធ្វើឡើងដើម្បីរំឭកអំពីទំនៀមទំលាប់ខ្មែរផង ធ្វើឱ្យមានការសាមគ្គីភាពគ្នាផង យល់អធ្យាស្រ័យគ្នាផង និងរក្សាការសហការគ្នាឱ្យបានល្អរវាងខ្មែរ និងខ្មែរទូទាំងភូមិស្រុក ខេត្ត ក្រុង រហូតដល់ពេញផ្ទៃប្រទេសទាំងមូលផង ។ **ទី២** គឺធ្វើពិធីសំពះព្រះខែនិងអកអំបុកនេះឡើង ដើម្បីឧទ្ទិសដល់ពោធិទន្សាយដែលព្រះអង្គបានធ្វើនូវ បារមីទាន(ជីវិតទាន)ឱ្យដល់ឥន្ទព្រាហ្មណ៍បានធ្វើជាចំណី ហើយញ៉ាំងឱ្យយើងជាពុទ្ធបរិស័ទជ្រះថ្លានឹងបារមីទានរបស់ព្រះបរមពោធិសត្វ និងដើម្បីបង្កើនសទ្ធាខ្លួនយើង ឱ្យកាន់តែខ្លាំងក្លាថែមទៀតនៅក្នុងព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ។ **ទី៣** គឺចង់រំលឹកថ្ងៃបរិនិព្វានរបស់អគ្គសាវ័កព្រះសម្មាសម្ពុទ្ធ មានព្រះសារីបុត្តព្រះអង្គបរិនិព្វាននៅថ្ងៃ ១៥កើត ខែ កត្តិក និងព្រះមហាមោគល្លានបរិនិព្វាននៅថ្ងៃ ១៥រោច ខែ កត្តិក ។

# ពុទ្ធមណ្ឌលធម្មទូត

## ( កាព្យថ្មី )

\+ ព្រៃល្បោះព្រៃល្បុះ ខ្ពស់ទាបរាបក្រាស់ ឆ្លោះឆ្លុះតាមបែប
ធម្មជាតិទាំងឡាយ ដុះរាយតាមទួល លលកយំបូល
នៅលើព្រឹក្សា ។

\+ ទួលពកទួលម្កាក់ ទួលខ្ញុំរាក់ទាក់ អ្នកស្រែចម្ការ
ចំកាត់មាត់ញូក ឬក៏អ្នកផ្សារ មន្ត្រីរាជការ
អង្គការក្រៅរដ្ឋ ។

\+ ក្នុង កម្ពុជា ជិតឆ្ងាយនាំគ្នា សទ្ធាប្រាកដ
ព្រមទាំងខ្មែរយើង រស់នៅខាងក្រៅ ចូលរួមសំដៅ
កសាងថ្វាយព្រះ ។

\+ ដើមលុយដើមលាភ ទឹកចិត្តញោមញាតិ ពិតជាថ្លាជ្រះ
កំលោះក្រមុំ ចាស់ទុំយកភត្ត សំដៅមកវត្ត
ពុទ្ធមណ្ឌល ។

\+ ធម្មទូតដ៏ធំ ជាទីមនោរម្យ ដីព្រៃមង្គល
ដើមជ្រៃដើមស្លា ចំប៉ីនិមល ដើមត្នោតឡើងគល់
ឪឡឹកដើមធំ ។

\+ ដើមព្រីងដើមស្ដៅ ល្អះល្អះពេកកូវ ព័ទ្ធដំបូកជុំ
នៅកន្លែងខ្លះ បានសាងរូបព្រហ្ម ដើមស្នាយត្រសុំ
ត្រសាយល្អណាស់ ។

\+ គគីកកោះ រុក្ខជាតិទាំងអស់ មានថ្មីមានចាស់
ដើមព្នៅមានផ្លែ អន្សៃល្អល្អះ ព្រះពោធិត្រចះ
ល្អលន់ពេកនៃ។

\+ រាំងភ្នំផ្កាល្អ ផ្លែវាបវរ គយគន់រំពៃ
មានចំការស្វាយ និងព្រៃឫស្សី វេឡុវ៉ែនថ្លៃ
ប្រពៃពិតណាស់ ។

\+ សួនស្មៅសួនផ្កា សួនដ៏អស្ចារ្យ ព្រះអង្គបានត្រាស់
ដើមស្លាប្រាំបី ដើមជ្រៃ៣២ ព្រះពោធិនៅទី
ពីមុខព្រះអង្គ ។

\+ ដើមឈើច្រើនណាស់ បើចង់ដឹងច្បាស់ សូមឆ្ពោះទៅត្រង់
ចង្ហាន់បិណ្ឌបាត យកថ្វាយព្រះសង្ឃ សាវក័ព្រះអង្គ
គង់ចាំទីនោះ ។

\+ ពុទ្ធស្ថានធំ៧ កំពុងរៀបចំ មានបួនចន្លោះ
(១) ពុទ្ធស្ថានប្រសូតិ (២) ពុទ្ធស្ថានត្រាស់ដឹង ៣) ធម្មចក្រហើយនិង
(៤) បរិនិព្វាន ។

\+ ពុទ្ធស្ថានទាំងបួន រៀបចំតាមក្បួន ប្រវត្តិធ្លាប់មាន
សម័យពុទ្ធកាល ព្រះពុទ្ធទ្រង់ញាណ ទ្រង់ចូលនិព្វាន
តែនៅព្រះធម៌ ។

\+ ព្រះសង្ឃសាវក័ ព្រះអង្គជាអ្នក ប្រមូលកៀងគរ
សប្បុរសទាំងឡាយ ជិតឆ្ងាយឱ្យទាន ជាប្រាក់រាប់លាន
កសាងពុទ្ធស្ថាន ។

\+ ព្រះអង្គ**ទូចសារិទ្ធ** យប់ថ្ងៃមិនគិត ប្រឹងធ្វើឱ្យបាន
ដាំដុះដើមឈើ យកធ្វើជាម្លប់ ផ្លែផ្កាមានគ្រប់
ប្រភេទទាំងអស់ ។

\+ មានស្ទឹងមានស្រះ ជីកថ្វាយដល់ព្រះ ដោយហឫទ័យស្មោះ
មានស្រះមុច្ចលិន្ទ និងស្រះបោក្ខរណី មានទឹកមានត្រី
ល្អក្រៃផ្កាឈូក ។

\+ ពុទ្ធស្ថានសំណង់ ធ្វើដោយផ្ចិតផ្ចង់ តាមពុទ្ធប្រវត្តិ
តាំងពីប្រសូតិ រហូតនិព្វាន ធ្វើឱ្យម្ចាស់ទាន
មានចិត្តត្រេកអរ ។

\+ គួរឱ្យស្ងប់ស្ងៃង ព្រោះជាកន្លែង មហាបវរ
សូម្បីទេវតា ក៏បានសាទរ បាចផ្កាជូនពរ
ឱ្យសុខសួស្តី ។

\+ សព្វសាធុជន បានទទួលបុណ្យ ផុតកម្មលោកីយ៍
នៅមានជីវិត សូមមានសិរី ដល់ជីវិតក្ស័យ
បុណ្យឆ្ពោះទៅសួគ៌ ។

+ ទេវតាឋានលើ រស់ដោយប្រសើរ ជីវិតក៏គួរ
គិតជាឆ្នាំទិព្វ ទៅតាមទង្វើ ផលបុណ្យបានធ្វើ
វិចិត្រជាផល ។

+ សូមចាំជានិច្ច ភាវនាកំភ្លេច ពុទ្ធោអរហំ
ខន្តី សច្ចៈ ហើយកុំតតាំង កិលេសទុក្ខំ
ត្រូវច្បាំងឱ្យឈ្នះ ។

+ ខេមរាទាំងអស់ ទាំងស្រីទាំងប្រុស ទោះបីក្រខ្សត់
ឧកញ៉ាសេដ្ឋី មន្ត្រីជាន់ខ្ពស់ ឬទៅដល់ហួស
ព្រះមហាក្សត្រ ។

+ ខ្មែរក្នុងខ្មែរក្រៅ ខ្មែរសខ្មែរខ្មៅ ធ្វើទានលះកាត់
ចំណាយធនធាន សង់ជាសាលា ជីកស្រះដាំផ្កា
ធ្វើផ្លូវធ្វើកុដិ ។

+ សំណង់ព្រោងព្រាត ដោយសារញ្ញោមញ្ញាតិ ចិត្តបរិសុទ្ធ
រាប់អានសាសនា បិតាសម្ពុទ្ធ សទ្ធាមោះមុត
ទ្រទ្រង់សាសនា ។

បើយើងច្បាំងយកឈ្នះកិលេសខ្លួនឯងបាន គឺប្រសើរជាងដែលយើងច្បាំងឈ្នះ
សត្រូវទាំងអស់នៅក្នុងពិភពលោកនេះទៅទៀតពីព្រោះកិលេសខ្លួនឯង
គឺជា សត្រូវធំហើយគ្រោះថ្នាក់បំផុត នៅក្នុងលោកនេះ ។

ស	តើសមាគមពុទ្ធមណ្ឌលធម្មទូតកម្ពុជា មានទីតាំងនៅឯណា ហើយមានទំហំដីប៉ុន្មានហិតា ?

ច	បាទ, សមាគមពុទ្ធមណ្ឌលធម្មទូតនេះស្ថិតនៅក្នុងឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ហើយមានផ្ទៃដីសរុបទាំងអស់ចំនួន ១០៧ ហិតា ។

ស	តើសមាគមពុទ្ធមណ្ឌលធម្មទូត កម្ពុជាបានកសាងសំណង់ និងហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះនៅលើទីតាំងដីដ៏ធំនោះ?

ច	បាទ, សំណួរនេះយើងចែកចេញជា៦ផ្នែក **ទី១ :** មានបួនកន្លែង គឺ : ជាសំណង់ពុទ្ធស្ថានប្រសូត សំណង់ពុទ្ធស្ថានត្រាស់ដឹង សំណង់ពុទ្ធស្ថានសំដែងធម្មចក្ក និងសំណង់ពុទ្ធស្ថានបរិនិព្វាន **ទី២ :** មានសំណង់ផ្សេងៗទៀតចំនួន ១០កន្លែង គឺ ពុទ្ធស្ថាន ធម្មចេតិយ សាលាធម្មវិន័យ មន្ទីរពេទ្យ សាលាឆាន់ថ្មី និងឃ្លាំង ប្រាសាទអង្គរវត្ត ពុទ្ធស្ថានព្រះអង្គប្រទានពរ ពុទ្ធស្ថានព្រះអង្គ បិណ្ឌបាត កុដិសំរាប់ព្រះសង្ឃ តូបដូនជី តាជីចំនួន ៤៥តូប និងសាលាឆាន់ចាស់ ។ **ទី៣ :** គឺផ្លូវនិងប្រឡាយ មានផ្លូវ វិសាខា មានផ្លូវវេសាលី មានផ្លូវនេរញ្ជរា មានផ្លូវប្រទានពរ

មានផ្លូវនាឡន្ទា មានផ្លូវពោធិគយា មានផ្លូវសារនាថ មានផ្លូវសាវត្ថីនិងប្រឡាយតាមបណ្ដោយផ្លូវនីមួយៗ។ **ទី៤ :** មានស្រះប្រទានពរ មានស្រះមុន្ទលិន្ទ មានស្រះបោក្ខរណី មានស្រះធម្មចក្ក និងស្រះផ្សេងៗជាច្រើនទៀត ។ **ទី៥ :** គឺមានចំការស្វាយ ចំការឬស្សីវេឡុវ៉ន **ទី៦ :** មានខ្លោងទ្វារ និងស្ពានជាច្រើនកន្លែង ព្រមទាំងដាំដើមឈើជាច្រើនប្រភេទទៀតផង ។

**ស** តើសមាគមពុទ្ធមណ្ឌលធម្មទូតកម្ពុជា មានគំរោងកសាងសំណង់អ្វីផ្សេងទៀតទេ ?

**ច** បាទ,បើតាមព្រះអង្គ **ទៀង ឈួន** មានសង្ឃដីការថា : នឹងកសាងសាលាឆាន់ធំ ១ ខ្នងទៀតដែលមានស្រះអមសងខាង និងកសាងព្រះសក្យមុនីចេតិយនៅលើផ្ទៃដី ចំនួន ១០ ហិតាហើយ នេះជាសំណង់ដ៏ធំជាងគេ ។

(ចប់)

សូមអនុមោទនា

# ព្រះធរណីមានគុណ

## ( សុភាសិត)

- ទឹកដី ភ្លើងខ្យល់ ជាផល ធម្មជាតិ
ព្រះគុណម្ចាស់ ញោមញាតិ គួរជ្រះថ្លា
សត្វលោក រស់នៅ ចិញ្ចឹម អាត្មា
ក៏គឺ ដោយសារ ធាតុ ទាំងបួន ។
- យើង រស់នៅ មិនត្រូវ ខ្វះមួយណា
នោះ ក្នុងអាត្មា ក៏ ត្រូវការ ដែរ
មនុស្សក្នុង ពិភព និង កម្ពុ-ខ្មែរ
ដូច្នេះ គួរតែ ជួយថែ សំអាត ។
- ទឹកដី យើងនេះ ក៏ មានគុណ
ព្រោះ ដី កើតមុន ទើប កើតសត្វ
ដីទ្រ សត្វលោក ឱ្យ ប្រតិបត្តិ
កំចាត់ ធម៌ខ្មៅ សំដៅ ធម៌ស ។

- ផែនដី ឈរទ្រ ឱ្យយើង សាងបុណ្យ
សង់ផ្ទះ ធ្វើបង្គន់ ក៏ មិនថា
ធ្វើវត្ត សាងកុដិ សង់ជា សាលា
ក៏គឺ ដោយសារ ព្រះធរណីទ្រ ២

- ចង់ជុះ ខាកស្តោះ លោកមិនស្តី
កំពូល ខន្តិ ដី ទឹក ភ្លើង ខ្យល់
ញុំាំងឱ្យ យើងបាន សន្សំកុសល
យក សមិទ្ធផល ថ្វាយ ព្រះត្រៃរត្ន ២

(ចប់)

សូមអនុមោទនា

ធម៌សម្រាប់ភាវនាសងគុណព្រះសតពោជ្ឈង្គ
ស ត វិ បិ ប ស ឧ (សូត្រ១២ចប់)

# សូមពរពីព្រះពុទ្ធ

## ( បទសារភញ្ញ )

\+ ខ្ញុំសូមឱនកាយ ថ្វាយបង្គំ សាស្តាឧត្តម ព្រះសម្ពុទ្ធ
ត្រាស់ដឹងក្នុងលោក ដល់វិមុត្តិ ព្រះអង្គរួចផុត ក្នុងវដ្តៈ
ព្រះអង្គមេត្តា អនុគ្រោះ ព្រះអង្គសង្គ្រោះ ដល់សព្វសត្វ
សំដែងធម្មចក្ក ប្រោសបញ្ចវៈ អង្គទាំងប្រាំនាក់ ជាបឋម ។

\+ កំណើតព្រះធម៌ និងព្រះសង្ឃ កើតពេលត្រឹមត្រង់ ថ្ងៃតែមួយ
ខ្ញុំជ្រះថ្លាណាស់ អស់ទុក្ខព្រួយ ព្រះអង្គទ្រង់ជួយ ក្នុងលោកា
មានភ័ព្វសំណាង យ៉ាងអនេក ល្អល្អះពន់ពេក ជួបព្រះពុទ្ធ
ឱរសព្រះអង្គ តែមួយគត់ ក៏បានរួចផុត ចាកទុក្ខដែរ ។
សូមពរព្រះអង្គ ជួយប្រោសខ្មែរ អោយភ្ញាក់ខ្លួនកែ ដឹងខុសត្រូវ
ពីមុនធ្វើខុស ដល់ឥឡូវ កាន់យកធម៌នូវ អហឹង្សា
មេត្តាករុណា ជាតិឯងផង កំពុងរងទុក្ខ យ៉ាងខ្លោចផ្សា
បុព្វបុរស ជាដូនតា ព្រមទាំងទេវតា ជួយសង្គ្រោះ ។

( ចប់ )

## សូមអនុមោទនា

ស  តើអ្នកប្រាជ្ញមានប៉ុន្មានពួក ?

ច  ព្រះពុទ្ធទ្រង់សំដែងថា ៖ អ្នកប្រាជ្ញមាន ៤ ពួកគឺ ៖

១- អ្នកប្រាជ្ញព្រោះគិត

២- អ្នកប្រាជ្ញព្រោះស្តាប់

៣- អ្នកប្រាជ្ញព្រោះអាស្រ័យសេចក្តីពិចារណា

៤- អ្នកប្រាជ្ញព្រោះប្រាជ្ញាវាងវៃ

ស  តើមានធម៌ប៉ុន្មានប្រការដែលប្រព្រឹត្តទៅដើម្បីចំរើនបញ្ញា?

ច  ធម៌សំរាប់ប្រព្រឹត្តទៅដើម្បីចំរើនបញ្ញាមាន ៤ ប្រការគឺ ៖

១- ការសេពគប់សប្បុរស

២- ការស្តាប់ធម៌របស់សប្បុរស

៣- យកចិត្តទុកដាក់ដោយឧបាយ

៤- ប្រតិបត្តិធម៌ដ៏សមគួរតាមធម៌

ស  តើព្រហ្មចរិយៈ មានអ្វីជាប្រយោជន៍សំរាប់ពុទ្ធបរិស័ទ និង ព្រះសង្ឃប្រព្រឹត្តក្នុង ព្រះពុទ្ធសាសនា ?

ច  ព្រហ្មចរិយៈមានការកំណត់ដឹងនូវទុក្ខហ្នឹងឯងជាប្រយោជន៍ ។

# រូបយើងសង្ឃឹមមិនបាន

## ( សុភាសិត)

- គួរគិតកុំស្តាយកុំស្រណោះ
  រូបរាងទាំងអស់ជាអនត្តា
  អនិច្ចំ មិនទៀងទូវសង្ខារ
  សង្ឃឹម រូបា នេះ មិនបាន ៗ



- រូបយើងនឹងស្លាប់ទៅជាខ្មោច
  គេដុតឆេះខ្លោចគ្មានខ្លឹមសារ
  កូនចៅចាក់ទឹកហើយធ្រាប់អាចារ្យ
  ទើបធាតុមាតាសល់មួយកញ្ចប់ ៗ

(ចប់)

សូមអនុមោទនា

ធមិសម្រាប់ភាវនាសងគុណម្តាយ
ន ក រំ មា តា បា បំ វិ ន ស្ស តុ
(សូត្រ១២ចប់)

# ផ្កាសិរីមង្គល

## ( កាព្យថ្មី )

\+ នមោនឹកគុណ　ព្រះដ៏មានបុណ្យ　តាំងពីប្រសូត
ព្រះឥន្ទព្រះព្រហ្ម　សុំខ្លួនមកដែរ　គឺមកជួយថែ
រក្សាព្រះអង្គ ។

\+ ដល់ពេលសាងផ្នួស　ប្រព្រឹត្តតឹងហួស　ដោយការលះបង់
ចង្ហាន់ទាំងឡាយ　ទាំងព្រឹកថ្ងៃត្រង់　ខំប្រិតផ្ចិតផ្ចង់
ស្វែងរកតែធម៌ ។

\+ ដល់ពេលត្រាស់ដឹង　ពុទ្ធអង្គខំប្រឹង　ប្រោសសត្តនិករ
មនុស្សនិងទេវតា　ជ្រះថ្លាព្រះអង្គ　ទ្រង់បានស្រោចស្រង់
ដល់យើងគ្រប់គ្នា ។

\+ ពុទ្ធានុភាព　គ្រប់គ្នាមានលាភ　បានធ្វើអ្នកជា
បោះចោលកំណាញ់　ប្រែមានសទ្ធា　ទាត់ចោលអវិជ្ជា
រើសយកបញ្ញា ។

\+ ទសពិធរាជធម៌　ល្អល្អះបវរ　ទាំងមនុស្សទេវតា
ព្រះពុទ្ធគោតម　ដ៏សែនអស្ចារ្យ　ឆព្វណ្ណភ្លឺថ្លា
ព្រោះបារមីទាន ។

+ ព្រះអង្គប្រោសសត្វ ចែកធម៌ជាកាត់ អ្នកនិស្ស័យមាន
ព្រោះបានសន្សំ រាប់សែនលានជាតិ ជួបព្រះអង្គទៀត
សម្រេចមគ្គផល ។

+ ព្រះអង្គបិណ្ឌបាត បានឱ្យឱវាទ អំពីកុសល
បុណ្យនោះច្រើនណាស់ ព្រះអង្គត្រាស់ដឹង ត្រង់នេះសុទ្ធសឹង
ទានបារមីតា ។

+ បានថ្វាយចង្ហាន់ មុញ្ចនៈចិត្តកាន់ ទៅព្រះសាស្តា
ចង្ហាន់ប្រណីត ប្រិតយ៉ាងឧត្តម សុជាតាខំ
សម្រាំងថ្វាយព្រះ ។

+ ទ្រង់ប្រទានពរ ព្រះទ័យថ្លាល្អ ដោយឫទ្ធិតេជះ
សត្វលោកមានភ័ព្វ ជាប់សំណាញ់ញាណ ព្រះអង្គប្រទាន
ពន្លឺប្រាកដ ។

+ ព្រះអង្គនិព្វាន សត្វលោករាប់លាន ទុក្ខសោកកំសត់
អំណើះតទៅ ព្រះភក្ត្រទ្រង់បាត់ ពុទ្ធបរិស័ទ
ខានជួបទៀតហើយ ។

+ ព្រះធម៌នៅមាន បើយើងខំរៀន ជិតព្រះបង្កើយ
ព្រះសង្ឃគង់នៅ យើងត្រូវធ្វើទាន បានធ្វើជាស្ពាន
ទៅជួបព្រះពុទ្ធ ។

+ ទានសីលភាវនា ហើយយើងគ្រប់គ្នា ធ្វើចិត្តបរិសុទ្ធ
ចាប់យកបញ្ញា លះចោលអវិជ្ជា បញ្ចេញសទ្ធា
ទំលាក់ទោសៈ ។

+ មោហៈកុំយក ចិត្តរឮករក ហិរិឱត្តប្បៈ
សម្មាទិដ្ឋិ ទាក់យកជាគ្នា កាយវន្ទនា
បញ្ជ្ញាសាវ៏ក ។

+ ព្រះសង្ឃជាស្រែ បុណ្យជូនឪម៉ែ ដែលជាអំណោយ
យើងជាម្ចាស់ទាន ឧទ្ទិសជូនឱ្យ សោយផលងាកក្រោយ
អោយសុខកូនចៅ ។

+ នេះជាភារកិច្ច កូនអើយកុំភ្លេច តពូជពង្សផៅ
យើងជាខេមរា សាសនាប្រដៅ ប្រកាន់ខ្ជាប់នូវ
កតញ្ញូតា ។

+ ដឹងគុណតបគុណ ប្រសើរលើសលន់ បានបុណ្យអស្ចារ្យ
កុលបុត្របានធ្វើ ទេវតារក្សា ជូនពរបាចផ្កា
សិរីមង្គល ។

(ចប់)

សូមអនុមោទនា

# ម្លប់ព្រះពុទ្ធព្រះធម៌

## ( សុភាសិត)

+ ពពក វសោត់ ដ្បិត ខ្យល់
កើតទុក្ខ អំពល់ ព្រោះ កម្ម ។
+ បក្សី អាស្រ័យ សំបុក
សត្វលោក បានសុខ ព្រោះ បុណ្យ ។
+ ភ្លើងឆេះ ដ្បិត អាស្រ័យ មានអុស
សត្វលោក ធ្វើខុស ដ្បិត អវិជ្ជា ។
+ អ្នក មានសទ្ធា ព្រោះ កុសល
ទៅមក បានដល់ ព្រោះ យាន ។
+ ព្រះចន្ទ ងងឹត ដ្បិត ពពក
សត្វលោក បានរួក ដ្បិត ព្រះធម៌ ។
+ ព្រះពុទ្ធ ជា ពោធិ ដ៏ បវរ
អ្នកមាន អ្នកក្រ ជ្រកបាន ទាំងអស់ ។

(ចប់)

សូមអនុមោទនា

ធម៌សម្រាប់ភាវនាសងគុណឪពុក

មោក វំ បិ តា បា បំ វិ ន ស្ស តុ

(សូត្រ២១ចប់)

ធម៌សម្រាប់ភាវនាសងគុណមហាក្សត្រ

ពុ ក វំ រា ជា បា បំ វិ ន ស្ស តុ

(សូត្រ៦ចប់)

*** ១០. ព្រះរាហុល ទៅ បរិនិព្វាន**
**នៅ សួគ៌វិមាន ឋានតាវតិង្ស**
**ជាពុទ្ធ បរិស័ទ ត្រូវតែ បានដឹង**
**ទាំងនេះ សុទ្ធសឹង ឲ្យ យើង ជ្រះថ្លា ។**

*** ១១. រាហុល ឱរស របស់ ព្រះអង្គ**
**ទៅជួយ ស្រោចស្រង់ ពិភព ទេវតា**
**ឥន្ទ ព្រហ្ម ទេវបុត្រ និង ទេពធីតា**
**រាហុល មេត្តា ករុណា ឋានសួគ៌ ។**

# មាន់រងាវហើយកូន

## ( បទពាក្យ ៧)

+ ថ្ងៃខែឆ្នាំចូរចាំកុំភ្លេច ទៅមុខជានិច្ចឥតមានឈប់
ដូចជាទឹកហូរដែលមិនត្រឡប់ ថ្ងៃយប់ៗមិនយូរឡើយនៃ ។

+ ឆ្នាំនេះឆ្នាំរកអដ្ឋស័ក ខែស្រាពណ៍ប្រត្យក្សយើងមានភ័យ
កញ្ញា តុលា វិច្ឆិកា ក្តី ពេលនោះប្រុសស្រីភិតភ័យហើយ ។

+ រាស្ត្ររួមចិត្តរួមគិតតែមួយ ខេមរារញ្ជួយព្រួយគ្មានស្បើយ
ព្យុះកម្មបោកបក់មិនឈប់ឡើយ ចាំមើលថ្ងៃក្រោយនុ៎ះយ៉ាងណា ។

+ ព្រះអាទិត្យបាំងឆត្រក៏មានដែរ បង្ហាញរាស្ត្រខ្មែរឱ្យជ្រះថ្លា
យើងសង្គ្រោះជាតិជួយដូនតា ត្រូវតែតវ៉ាជួយម្តាយផង ។

+ ក្អែកខ្មៅពាំល្ងារាយគ្រប់ស្រុក ក្អែកសកើតទុក្ខពេកកន្លង
សទៅជាខ្មៅជាច្រើនដង ក្អែកខ្មៅប៉ុនប៉ងយករូបម្តាយ ។

+ ចូរយើងប្រុងប្រៀបរៀបខ្លួនប្រាណ ភាវនាឱ្យបានធម៌ចម្រុង
ចម្រើនរក្សាទេវតាក្នុង ចិត្តឆ្មោះតម្រង់ព្រះមាតុគុណ ។

+ ព្រះពុទ្ធព្រះធម៌ព្រះសង្ឃខាំង ជួយបិតជួយបាំងភ័យអាសន្ន
រោគាព្យាធិនិងទុក្ខធ្ងន់ ខ្ញុំនឹងសាងបុណ្យដឹងគុណមាតា ។

+ ឥតិបិសោភគវា[១] បង្គំវន្ទាព្រះសាស្ដា
រក្សាចិត្តចម្រើនមេត្តា ព្រោះហេតុអស្វារ្យនឹងមកដល់ ។
+ ន ម ព ទ វិ សុ អ[២] ភាវនាគារវៈ នឹងបានផល
សុ ចិ បុ លិ[៣] នឹងបាត់ឆ្ងល់ អ្នកមានកុសលដល់ពេលហើយ ។
+ ឧ ម ៈ បើកបែកជ្រែកទឹកដី កុសលចាស់ថ្មីកុំកន្តើយ
ជ្រោមជ្រែងជួយខ្មែរឱ្យល្វែល្វើយ អ្នកមានបុណ្យអើយរាស្ត្ររងចាំ។

(ចប់)

សូមអនុមោទនា

ធម៌សម្រាប់ភាវនាសងគុណញាតិ
ទ្វា ក រំ ញា តិ កា បា បំ វិ ន ស្ស តុ (សូត្រ៧ចប់)

---

(១) **ឥតិបិសោភគវា** (សូមមើលក្នុងព្រះពុទ្ធគុណត្រង់ទំព័រទី៣)

(២) **វិ សុ អ** = វិន័យ សុត្តន្តបិដក អភិធម្ម

(៣) **សុ ចិ បុ លិ** = ស្ដាប់ គិត សួរ សរសេរ ឬ កត់ត្រា

# ជិតដល់ពេលហើយ

## ( សុភាសិត)

- ពុទ្ធោអរហំ តាំងគោរពគុណព្រះសាស្តា
  បុត្រមាតា ត្រូវបន្ទន់សិរសាឱនសិរសី
  បង្គំ ក្រាបលុត គុណកែវ ទាំងបី
  ព្រះ រតនត្រ័យ ដ៏ ថ្លៃថ្លា មហិមា ។
- ម្លប់ពោធិ បាំងបិទ នោះ ពិត ធម្មា
  អ្នកឈឺ អ្នកជា អ្នកក្រ សុំជ្រក
  អ្នកស្រែ ចម្ការ អ្នកក្រុង ទៅមក
  អ្នកមាន នឹកភ្នក សុំជ្រក ផងដែរ ។
- មេឃខ្មៅ ពពកអ័ព្ទ ចាប់ផ្តើមហើយ
  រាស្ត្រទុក្ខ ឥតស្បើយ ស្តេច ក៏ ឥតល្ហែ
  សារិកា ធ្លូងមាស មុខដូច ព្រះខែ
  អាណិត រាស្ត្រដែរ តែជួយមិនបាន ។

- ផ្ការលាន់ ឯជើង ដល់ពេល ភ្លើងឆេះទឹក
បាត់ដើម កប្បព្រឹក្ស កូននឹកព្រះ ភគវា
ធ្វើបុណ្យ រក្សា សីល ហើយ ភាវនា
ព្រោះ ពេលវេលា កៀកកិត ជិតដល់ហើយ ឲ

( ចប់ )

សូមអនុមោទនា

* ១២. សមុទ្រ ជលសៃ រសប្រៃ ហើយ ជ្រៅ
ពិបាក មុជទៅ ដល់បាត ខ្លាំងណាស់
សន្សំ បារមី ទើប ព្រះ បានត្រាស់
ព្រះធម៌ ល្អស្អះ ជ្រៅជាង សមុទ្រ ។

* ១៣. សមុទ្រ សែនជ្រៅ គង់គេ ទៅដល់
អ្នកប្រើ ល្បិចកល គង់តែ គេដឹង
ព្រះធម៌ នៅមាន ទំរៀន ទំប្រឹង
ទាំងអស់ សុទ្ធសឹង បានពី ព្យាយាម ។

# ប្ដឹងមនុស្សមិនបានការទើបប្ដឹង
# ទេវតាឱ្យជួយវិញ

## ( សុភាសិត)

\- ទេវតាឋានកណ្ដាល និង ទេវតាឋានលើ
សូមទ្រង់ ទតមើល ប្រទេស កម្ពុជាផង
កំពុង មានទុក្ខ សោកសៅ ពេកកន្លង
ដោយពួក ល្បងប្រេតព្រាយ[១] រាយគ្នាធ្វើព្រះ ។

\- មហាអ្នកដូន មហាអ្នកតា ថ្លៃថ្លា ស័ក្ដិសិទ្ធិ
មហាអ្នក សច្ចំ តាំង ឥសី ឧសពិធ
មេឃដី អាណិត ព្រះចន្ទព្រះអាទិត្យ ករុណា
សូមទាន មេត្តា ជួយខេមរា ឱ្យផុតពីទុក្ខ ។

---

(១) **ប្រេតព្រាយ** = គឺអ្នកប្រព្រឹត្តអំពើបាប

**- ព្រះឥន្ទព្រះព្រហ្ម ព្រមទាំង មហារាជទាំងបួន**
**សូមចាត់ចែងក្បួន ទេវតា តាមមក ជួយសង្គ្រោះ**
**ពីមច្ចុរាជ[២] ឃោឃៅ[៣] ពួកក្អែកខ្មៅ[៤] ទាំងនោះ**
**អោយរួចរំដោះ អស់ទុក្ខ បានសុខ ទៅហោង ៗ**

(ចប់)

សូមអនុមោទនា

ធម៌សម្រាប់ភាវនាសងគុណខ្លួនឯង
ចិ ចេ រូ នី (សូត្រ១២ចប់)

ធម៌សម្រាប់ភាវនាសងគុណទសបារមី
ទា សិ នេ ប វិ ខ ស អ មេ ឧ
(សូត្រ១២ចប់)

---

(២) **មច្ចុរាជ** = គឺជាបញ្ចក្ខន្ធ
(៣) **ឃោឃៅ** = គឺជាតួទោសៈនិងសេចក្ដីក្រោធ
(៤) **ក្អែកខ្មៅ** = គឺជាមោហៈមូល ។

# សុគតិសួគ៌ទេវលោក

## ( កាព្យថ្មី )

\+ ឧ ម: ន មោ បង្គំពុទ្ធោ ព្រះធម៌ព្រះសង្ឃ
លំអុតលំឱន ចិត្តបរិសុទ្ធ សទ្ធាមោះមុត
បញ្ញាភ្លឺថ្លា ។

\+ ពេលនេះតទៅ សូមបានយល់ត្រូវ ផ្លូវព្រះសាស្តា
ផ្លូវនាំសត្វលោក ឱ្យរួច ទុក្ខា ឆ្លងដល់ត្រើយម្ខា
បរមសុខនិព្វាន ។

\+ រី ឯ ស្ត្រី ប្រកបធម៌អ្វី ទៅសួគ៌រាប់លាន
អង្គអនុរុទ្ធ បានទូលសួរព្រះ តើត្រូវយកឈ្នះ
លើធម៌យ៉ាងណា ។

\+ ព្រះអង្គតបឆ្លើយ អនុរុទ្ធអើយ ត្រូវចាំទុកថា
មាតុគ្រាម[១] នោះ ប្រព្រឹត្តរក្សា ប្រកបដោយការ
អ្នកមានសទ្ធា ។

---

(១) មាតុគ្រាម = ស្ត្រី

\+ សេចក្ដីខ្មាស់បាប គ្មានក្លិនជាប់ឆ្អាប ខ្លាចបាបគ្រប់គ្រា
មិនក្រោធមិនគំ មិនច្រណែនគេ ហើយមិនគ្នាន់គ្នេរ
រក្សាសីល[១] ពួក ។

\+ ចុះពួកស្ត្រី ប្រកបធម៌អ្វី ទៅកាន់នរក
ព្រះអង្គតបឆ្លើយ ត្រូវចាំឱ្យច្បាស់ ស្ត្រីជាប់ក្រាស់
ដោយអំពើបាប ។

\+ មិនមានសទ្ធា ស្ត្រីគ្រប់គ្នា ព្រោះមិនខ្លាចបាប
មិនបានចេះដឹង ប្រឹងមិនខ្មាស់បាប ខ្ជិលជាប់ដូចកាព្យ
ហើយគ្មានបញ្ញា ។

\+ ស្ត្រីត្រូវគិត ប្រុងប្រៀបរៀបប្រិត នូវគ្រប់កិច្ចការ
សារពើដែលមាន សីលទានកុំភ្លេច ភាវនាជានិច្ច
បដិបត្តិធម៌ ។

\+ យើងទាំងអស់គ្នា ជន កម្ពុជា ជាជនបវរ
កាន់ព្រះសាសនា សម្មាសម្ពុទ្ធ អង្គព្រះវិមុត្តិ
គ្រួសាររុងរឿង ។

---

(១) សីល៥ - សីល៨ - សីល១០ ជាដើម (សីល៥សូមមើលក្នុងសៀវភៅកំណាព្យធម៌ភាគ១ ត្រង់ទំព័រ៣១)

\+ គ្រួសារបានសុខ ពេលនេះទៅមុខ ប្រទេសថ្កុំថ្កើង
សម្បូរសប្បាយ សុខា សុខុម រីករាយជួបជុំ
ក្សេមក្សាន្តទៅហោង ។

(ចប់)

សូមអនុមោទនា

ស តើមាតុគ្រាមប្រកបដោយធម៌ប៉ុន្មានយ៉ាង
លុះពេលស្លាប់ទៅតែងទៅកើត ក្នុងសុគតិសួគ៌ទេវលោក ?

ច (ទី១) មាតុគ្រាមប្រកបដោយធម៌៥យ៉ាងក្រោយពីស្លាប់ទៅតែងទៅកើតក្នុងសុគតិសួគ៌ទេវលោក គឺ :

១- មានសទ្ធា
២- មានសេចក្តីខ្មាស់បាប
៣- មានសេចក្តីខ្លាចបាប
៤- មានបញ្ញា
៥- មិនក្រោធ, មិនកំណាញ់

ច (ទី២)

១- មានបញ្ញា
២- មិនប្រព្រឹត្តក្បត់ប្តី
៣- មានសីល
៤- ជាអ្នកចេះដឹងច្រើន
៥- ជាអ្នកមានស្មារតីតម្កល់ខ្ជាប់មិនកំណាញ់

ស តើមាតុគ្រាមប្រកបដោយធម៌ប៉ុន្មានយ៉ាង លុះពេលស្លាប់ទៅតែងទៅកើតក្នុងនរកនោះ ?

ច មាតុគ្រាមនោះប្រកបដោយធម៌៥យ៉ាងដូចខាងក្រោម លុះស្លាប់ទៅតែងទៅកើតក្នុងឋាន នរក :

១- មិនមានសទ្ធា ២- មិនមានសេចក្ដីខ្លាចបាប

៣- មិនមានសេចក្ដីខ្មាស់បាប ៤- មិនមានបញ្ញា

៥- មិនបានចេះដឹង, ជាអ្នកខ្ជិលច្រអូស, ជាអ្នកភ្លេចស្មារតី

* ១៤. មហា ឧបាសិកា វិសាខា
ធ្វើទាន អស្ចារ្យ ខ្ពង់ខ្ពស់ បំផុត
សេដ្ឋី ធីតា ជ្រះថ្លា ព្រះពុទ្ធ
បង្គំ ក្រាប លុត ថ្វាយ ទាន ព្រះអង្គ ។

* ១៥. ព្រះសង្ឃ សាវ័ក នៃ ព្រះសាស្ដា
នាង វិសាខា ប្រគេន ចង្ហាន់
និង ទេយ្យវត្ថុ ចិត្តស្មោះ មូលគាន់
ព្រះសង្ឃ បានឆាន់ គ្រប់ៗ ព្រះអង្គ ។

* ១៦. ទានវិសាខា គួរឱ្យជ្រះថ្លា អស្ចារ្យពេកណាស់
ប្រគេនព្រះសង្ឃ បានបុណ្យពិតច្បាស់ សូមកូនរួតរះ
ត្រាប់តាមមិនខុស ។

# ល្ងង់ល្ងិតបិទកុសលផ្តល់តែបាប

## ( សុភាសិត )

- ការរៀន ព្រះធម៌ គាត់ចេះ តែភ្លេច
  ការដេរ ប្រទេច គាត់ចេះ តែចាំ ៗ
- ព្រះសង្ឃ ទូន្មាន ឱ្យ ប្រព្រឹត្តស្តាំ
  សតិ គាត់ចាំ ថា ប្រព្រឹត្តឆ្វេង ៗ
- ស្តាប់លោកទេសន៍ គាត់ចេះតែរោយជើង
  ផឹកស៊ី គ្នាយើង ស្មើម៉ាន ក៏បាន ៗ
- ស្តាប់ធម៌ តាមវិទ្យុ គាត់ចេះ តែងុក
  ដល់ពេល លេងអុក ១ថ្ងៃ អត់អី ៗ
- រដូវ ភ្ជុំបិណ្ឌ គាត់ ឥត ទំនេរ
  ផឹកស្រា ស៊ីភ្លែ រាល់ខែ ទើបមាន(១) ។
- ធ្វើបុណ្យ ដាក់ទាន គាត់ មិនចេះទេ
  ច្រៀង ខារ៉ាអូខេ គាត់ ស្ទាត់ណាស់ ៗ

---

(១) **មាន** = គឺមានពេល

- ព្រះសង្ឃ បិណ្ឌបាត គាត់ធ្វើ មិនដឹង
  បៀ អាចោង គាត់ប្រឹង ចំតិតគូថ ៗ
- គេហៅ ទៅវត្ត គាត់ថា ចាំស្អែក
  រឿង កន្ទុយលេខ ចាំស្អែក មិនបាន ៗ
- រកស៊ី ត្រឹមត្រូវ គាត់ ពិបាកណាស់
  រកស៊ី បោកប្រាស់ គាត់គិត ថាស្រួល ៗ
- លក់ចេញ ទិញចូល គាត់ថា នឹងដួល(១)
  ភូតភរ បោកស្រួល គាត់ថា ងាយធ្វើ ៗ
- ធ្វើស្រែ ធ្វើស្រូវ គាត់ទៅ មិនបាន
  ទៅបា ស្ទើម៉ាន គាត់បាន ទាំងអស់ ៗ
- មានបុណ្យ ក្នុងភូមិ គាត់ មិនចូលចិត្ត
  ស្រីស្រា កៀកកិត គាត់ថា អូខេ(២) ។

(ចប់)

សូមអនុមោទនា

---

**(១) ដួល** = គឺរកស៊ីខាតអស់ចុងអស់ដើម

**(២) អូខេ** = OK គឺយល់ព្រម (មិនអីទេ)

ស តើហេតុអ្វីបានជាសត្វ សេះ គោ ក្របី មិនឱ្យតម្លៃមាសពេជ្រ បែរជាឱ្យតម្លៃស្មៅទៅវិញ ?

ច ព្រោះតែអវិជ្ជា (ទើបមិនដឹងថា មាស និងពេជ្រជារបស់មានតម្លៃជាងស្មៅ) ។

ស តើហេតុអ្វីបានជាមនុស្សខ្លះ មិនចូលចិត្តធ្វើបុណ្យ ហើយចូលចិត្តប្រព្រឹត្តតែអំពើបាបទៅវិញ ?

ច ព្រោះតែអវិជ្ជាគ្របដណ្តប់ធ្វើឱ្យល្ងង់ល្ងិត បាំងបិទអស់ពន្លឺជាកុសល ហើយលិចបាត់នូវសទ្ធាគឺផ្តល់តែភាពងងឹតប្រព្រឹត្តតែអំពើបាបគួរឱ្យតក់ស្លុតនិងគួរឱ្យសង្វេកពន់ពេកណាស់ ។

ស តើផ្លូវប្រព្រឹត្តទៅសុគតិសួគ៌ទេវលោក និងផ្លូវប្រព្រឹត្តទៅនរកនោះមួយណាស្រួលធ្វើដំណើរជាង ?

ច បាទ , សំនួរនេះត្រូវចែកចេញជាពីរ គឺ :

(ទី១) ផ្លូវដែលប្រព្រឹត្តទៅកាន់សុគតិសួគ៌ទេវលោក នោះគឺរលោក់មានឆ្លងទឹកឆ្លងភក់មិនស្រួលទេ ដូច្នេះទាល់តែមានសេចក្តីអត់ធន់ហើយព្យាយាមធ្វើដំណើរ ទើបទៅដល់សុគតិសួគ៌ទេវលោកបាន។ (គប្បីជ្រាបថាសប្បុរសជនធ្វើល្អបានដោយងាយ ធ្វើបាបបានដោយក្រ ពោលគឺមិនធ្វើតែម្តង) ។

(**ទី២**) ផ្លូវដែលប្រព្រឹត្តទៅកាន់នរកនោះ គឺរលោងស្រិលរអិលស្រួលណាស់ ហើយងាយធ្វើដំណើរឆាប់ដល់គោលដៅបំផុត ។ (អសប្បុរសជន គឺមនុស្សបាប ធ្វើបាបបានដោយងាយ ធ្វើល្អបានដោយក្រ) ។

*** ១៧. សូម្បី សត្វ គេអាច បង្ហាត់ បាន**
**ចុះកូន គ្រប់ប្រាណ ហាត់បាន ឬ អត់**
**ព្រះធម៌ ទាំងអស់ របស់ ព្រះពុទ្ធ**
**អប់រំ ល្អផុត វិសុទ្ធ អស្ចារ្យ ។**

*** ១៨. ធ្វើចិត្ត ឱ្យល្អ ធម៌ ប្រដៅ បាន**
**ទើប បុត្រ កល្យាណ ឃើញផ្លូវ ទៅមុខ**
**ដឹងគុណ តបគុណ ដល់ ម្ដាយ ឪពុក**
**កូននឹង បានសុខ ផុតទុក្ខ ទាំងពួង ។**

# ដួងព្រលឹងខ្មែរ

## ( កាព្យថ្មី)

+ បុព្វបុរស　មហានគរ　ទឹកដីបវរ
ជាទឹកដីមាស　សែនធំល្វឹងល្វើយ　លិចកើតកោះត្រើយ
រុងរឿងសប្បាយ ។

+ អង្គក្សត្រមានឫទ្ធិ[(១)]　ព្រះអង្គទសពិធ　មិនគិតព្រះកាយ
ការពារទឹកដី　វាយខ្មាំងកំចាយ　ឱ្យវាអន្តរាយ
អស់ពីទឹកដី ។

+ ព្រះអង្គមានប្រាជ្ញ　សត្រូវខ្លបខ្លាច　ដោយឫទ្ធិបារមី
ជយវរ្ម័ន[(២)]　ទី៧នោះនៃ　កិត្តិនាមល្បាញល្បី
និស្ស័យផលបុណ្យ ។

+ សម័យអង្គរ　យើងសែនត្រេកអរ　ហើយមិនភ្លេចគុណ
វរញ្ញក្សត្រ　ករុណាទិគុណ　មានគ្រោះអាសន្ន
ព្រះអង្គជួយរាស្ត្រ ។

---

**(១) ឫទ្ធិ** = សូមមើលក្នុងសៀវភៅកំណាព្យធម៌ភាគ២ ទំព័រ ២០

**(២) ជយវរ្ម័នទី៧** = ជាមហាក្សត្រដ៏អស្ចារ្យបានកសាងអង្គរវត្តថ្វាយព្រះពុទ្ធ និងកសាងវត្តជាច្រើនទូទាំងព្រះនគរ ហើយការពារទឹកដីបានល្អជួយប្រជារាស្ត្រឱ្យមានសេចក្តីសុខចំរើនមានព្រះកិត្តិនាមល្បីល្បាញពេញ ពិភពលោក ។

\+ ព្រះអង្គឈ្លាសវៃ ការពារទឹកដី មិនឱ្យវិនាស
ធ្លាក់ចូលដៃខ្មាំង ដែលច្បាំងចង់បាន សុខចិត្តក្ស័យប្រាណ
មិនឱ្យបាត់បង់ ។
\+ ទសពិធរាជធម៌[(១)] ប្រជាអបអរ ព្រោះក្សត្រត្រឹមត្រង់
មិនតែប៉ុណ្ណោះ ទ្រង់បានសាងសង់ អារាមផ្ចិតផ្ចង់
ថ្វាយដល់ព្រះពុទ្ធ ។
\+ មានវត្តច្រើនណាស់ ព្រះករុណាម្ចាស់ សាងសង់គត់មុត
ទូទាំង នគរ ល្អល្អះបំផុត ចិត្តបរិសុទ្ធ
ជ្រះថ្លាលើគុណ ។
\+ ព្រះរតនៈត្រៃ ទ្រង់មាននិស្ស័យ ខំសាងនូវបុណ្យ
សាងអង្គរវត្ត ពីថ្ម ធ្ងន់ៗ ទាំងប្រជាជន
សង់បានសម្រេច ។

(១) **ទសពិធរាជធម៌** = គឺជារាជធម៌ ១០ប្រការ សំរាប់មហាក្សត្រប្រព្រឹត្តតាមគឺ : **១ ទាន** = ការឱ្យអំណោយ **២ សីល** = ការរក្សាកាយវាចារឱ្យបរិសុទ្ធ **៣ នេក្ខម្ម** = ការចេញចាកកាមគឺចេញបួស **៤ បញ្ញា** = ការដឹងច្បាស់នូវសេចក្ដីពិត **៥ វិរិយ** = សេចក្ដីព្យាយាម **៦ ខន្តិ** = សេចក្ដីអត់ធន់ **៧ សច្ចៈ** = ការកាន់សំដីពិតមិនរើរុះ ឬផ្លាស់ប្ដូរ **៨ អធិដ្ឋាន** = ការធ្វើឱ្យឃើញតាមហេតុពិត ជាក់ស្ដែង **៩ មេត្តា** = ការផ្សាយសេចក្ដីរាប់អានចំពោះសព្វសត្វមិនរើសមុខ **១០ ឧបេក្ខា** = ដំណើរតាំងចិត្តដើយព្រងើយដោយស្មោះស្មើ ។

+ អង្គរអស្ចារ្យ មនុស្សនិងទេវតា គិតថាដូចពេជ្រ
ឧទ្ទិសថ្វាយព្រះ សម្មាសម្ពុទ្ធ អង្គព្រះវិមុត្តិ
ផុតដល់និព្វាន ។

+ ឧមៈ នមោ គ្រាន់តែត្រេកអរ កុសលកើតមាន
ដល់យើងគ្រប់គ្នា មហាសាលទាន បានធ្វើជាយាន
ជិះទៅឋានសួគ៌ ។

+ បើមានបញ្ញា ជួយថែរក្សា ទៅតាមការគួរ
មរតកដូនតា វាសនាមានភ័ព្វ កុសលដក់ជាប់
ភ្នំពេជ្រខេមរា ។

+ ដួងព្រលឹងខ្មែរ នាំគ្នាខំថែ កេរដ៏អស្ចារ្យ
បានទុកឱ្យយើង ជាបុត្រធីតា ដូច្នេះមេត្តា
រក្សាឱ្យបាន ។

+ រក្សា រក្សំ សុខា សុខំ លាភំក្សេមក្សាន្ត
សម្បត្តិវប្បធម៌ ជ្រាបក្នុងសន្តាន ផលបុណ្យជួយប្រទាន
បានទៅសោយសុខ ។

(ចប់)

សូមអនុមោទនា

ធមិសម្រាប់ភាវនាសងគុណព្រះធរណី
ហ្វីករំ (បថវីករំ) សន្និតេ
បាបំវិនស្សតុ (សូត្រ២១ចប់)

ធមិសម្រាប់ភាវនាសងគុណព្រះគង្គារ
គង្គារំ បាបំវិនស្សតុ
(សូត្រ១២ចប់)

* ១៩. ឃើញ សត្វវ៉ា ចេះស្តាប់ បង្គាប់ មនុស្ស
ឃើញ កូន ស្រី ប្រុស មិនស្តាប់ ឪ ម៉ែ
ឃើញ កូន ធ្វើខុស ប្រដៅ មិនកែ
ឃើញ តែសត្វ ឆ្កែ មកក្បែរ គួរសម ។

* ២០. ឆ្កែ ឱ្យ សុីឆ្អឹង ប្រឹង ដឹង គុណម្ចាស់
កូន គិត ឱ្យ ច្បាស់ ទាំងប្រុស ទាំងស្រី
ហូបចុក ស្លៀកពាក់ រហូត ពេញវ័យ
ពុកម៉ែ មានន័យ ចង់ ឱ្យ កូនល្អ ។

# លេខបុកមានប្រយោជន៍

## ( ជាគទាន)

| | | | | |
|---|---|---|---|---|
| ញញឹម | បូកនឹង | រាក់ទាក់ | ស្មើនឹង | អ្នកមានសិរី |
| សំពះ | បូកនឹង | ប្រឹមប្រិយ | ស្មើនឹង | ស្រីបវរកញ្ញា |
| ទន់ភ្លន់ | បូកនឹង | កតញ្ញុតា | ស្មើនឹង | ការដឹងគុណ |
| ចិត្ត | បូកនឹង | បុណ្យ | ស្មើនឹង | ពួកទេវតា |
| សទ្ធា | បូកនឹង | វិរិយះ | ស្មើនឹង | អ្នកមានបញ្ញា |
| ស្លូតបូត | បូកនឹង | ឧស្សាហ៍ | ស្មើនឹង | ទេវតាជួយ |
| ធ្វើទាន | បូកនឹង | មេត្តា | ស្មើនឹង | ទេវតាឱ្យទ្រព្យ |
| មិនលួច | បូកនឹង | ករុណា | ស្មើនឹង | ទេវតាឱ្យសុខ |
| មិនសម្លាប់ | បូកនឹង | ហិរិ | ស្មើនឹង | អ្នកអាយុវែង |
| សច្ចះ | បូកនឹង | ទៀងត្រង់ | ស្មើនឹង | ព្រះអង្គប្រទានពរ |

(ចប់)

សូមអនុមោទនា

# បណ្ដាំបុព្វទេព[១]

## ( បទកាកគតិ)

\+ ឆព្វណ្ណរង្សី[២] ពន្លឺល្អក្រៃ នៃព្រះសម្ពុទ្ធ
វិសេសវិសាល ឆ្លាស់ពណ៌ល្អផុត ព្រះអង្គវិសុទ្ធ
ដូចសុវណ្ណហង្ស[៣] ។

\+ មាតាសោមនស្ស ប្រាប់កូនទាំងអស់ ចូរកុំបោះបង់
ប្រព្រឹត្តសុចរិត ឱ្យបានត្រឹមត្រង់ វិ.សុ.អ.ខ្ចង់[៤]
ព្រះអង្គឈ្នះមារ ។

\+ កូនទាំងអម្បាល គួរស្គាល់អកាល និងកាលវេលា
ដែលគួរប្រព្រឹត្ត ឱ្យបានសមជា កូនខ្មែរគ្រប់គ្នា
ការពារទឹកដី ។

\+ ព្រះពុទ្ធត្រាស់ថា អក្ខធូតា[៥] ទោះប្រុសទោះស្រី
វែងតែលង់ខ្លួន ផ្ដួនដោយទុក្ខភ័យ វិនាសហិនហៃ
ចង្រៃរួមរឹត ។

---

(១) **បុព្វទេព** (សូមមើលក្នុងអធិប្បាយទេវតាទាំង ៥ ពួក)

(២) **ឆព្វរង្សី** (សូមមើលក្នុងអធិប្បាយ)

(៣) (៤) (សូមមើលក្នុងអធិប្បាយ)

(៥) អក្ខធូតា = អ្នកលេងល្បែងស៊ីសង ឬ ល្បែងភ្នាល់ផ្សេងៗ ។

\+ កូនសន្សំបុណ្យ   តាំងចិត្តឱ្យធ្ងន់   ក្រាស់ដោយការគិត
ឱ្យស្គាល់រាក់ជ្រៅ   ក្នុងមួយជីវិត   ជនស្លាប់គំនិត
រមែងរងទុក្ខ ។

\+ វីអកុសល   ជាកម្មតែងផ្ដល់   ចង្រៃរោរុក
ឱ្យដល់អ្នកធ្វើ   រហូតជាប់គុក   ឱ្យម្ដាយឪពុក
អាប់មុខខ្មាស់គេ ។

\+ ផ្ទុយពីកុសល   ដែលតែងតែផ្ដល់   ក្ដីសុខឋិតថេរ
កម្មនេះល្អលន់   មានពីបុព្វេ   ព្រះពុទ្ធទុកកេរ
ម្ដាយប្រាប់ឱ្យធ្វើ ។

\+ កូនជឿផលកម្ម   មានស្មារតីចាំ   ប្រព្រឹត្តអំពើ
បុញ្ញកម្មនឹងបាន   ក្សេមក្សាន្តឥតបើ   អ្នកប្រាជ្ញសរសើរ
ទេវតាលោកត្រេក[1] ។

\+ ឪពុកនិងម្ដាយ   នូវញាតិទាំងឡាយ   សប្បាយពន់ពេក
ព្រោះឮថាកូន   ឮសាយចម្លែក   ម្ដាយអរអនេក
ឯកឥតគណនា ។

\+ កូនម៉ែអង់អាច   មានឫទ្ធិអំណាច   ហើយល្បីខ្ចរខ្ចារ
តែជះជាញ្ជ័យ   ឈ្នះអស់ពួកមារ   គ្រប់ពេលវេលា
ជួយមាតុភូមិ ។

---

(១) **ត្រេក** =  គឺត្រេកអរ

## អធិប្បាយ

- ឆព្វណ្ណរង្សី = គឺពន្លឺទាំង ៦ពណ៌ មាន ខៀវ,លឿង, ក្រហម,ស,ហង្សបាត និង ផ្លេក (ពណ៌ផ្លេកជាពណ៌ពន្លឺពេជ្រ)
- បុញ្ញកម្ម = បុញ្ញ = បុណ្យ = អំពើល្អ ។
- សុវណ្ណហង្ស = ហង្សមាស ។
- វិ.ស.អ = វិន័យ សុត្តន្តបិដក អភិធម្ម = គឺព្រះធម៌ទាំង ៨ម៉ឺន ៤ពាន់ ព្រះធម្មក្ខន្ធ នៅក្នុងព្រះត្រៃបិដកទាំង ១១០ក្បាល ។

**ទេវតាទាំងប្រាំពួកគឺ :**

**១- បុព្វទេព**

**២- សម្មតិទេព**

**៣- ឧបបត្តិកទេព**

**៤- វិសុទ្ធិទេព**

**៥- អន្នោទេព**

## ពន្យល់:

**១~បុព្វទេព** គឺទេវតាដើម ទេវតាមុន គឺជាមាតាបិតារបស់យើង ព្រោះមាតាបិតាមានចិត្តមេត្តាប្រណី

ស្មោះស្មើ និងមានព្រហ្មវិហារធម៌៤ គឺ : **មេត្តា ករុណា មុទិតា** និង **ឧបេក្ខា** ប្រហែលនឹងចិត្ត របស់ ទេវតាដែរ ។

**២-សម្មតិទេព** គឺជាទេវតាដោយសន្មត ឬ ជាមនុស្សដែលគេសន្មតទុកដូចជាទេវតាអញ្ចឹង មានព្រះមហាក្សត្រ និងមហាក្សត្រីយ៍ជាដើម ។

**ឧ :** ដូចជាពាក្យថ្វាយព្រះពរចំពោះព្រះមហាក្សត្រដែលកំពុងគ្រងរាជ្យថា : បពិត្រព្រះសម្មតិទេព សូមទ្រង់មានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ។

**៣-ឧបបត្តិកទេព** ជាទេវតាដែលមានឧបបត្តិកកំណើត ឬ ឧបបត្តិកជាតិ ដែលមានកំណើតឯងៗ ឬ កើតឡើងដោយមិនចាំបាច់មានមាតាបិតាទេ ។

**៤-វិសុទ្ធិទេព** ជាទេវតាដែលមានចិត្តបរិសុទ្ធ ស្អាតវិសេស ហើយប្រកាន់យកតែអំពើដ៏ល្អស្អាតជានិច្ច ។

**៥-អន្លោទេព** ទេវតានៅក្នុងវិមាន នៅក្នុងប្រាសាទ នៅក្នុងឋានសួគ៌ាជាដើម ។

# អត់ធ្មត់ណាកូនណា !

## ( ជាឧទាន)

\+ សម្ដីសំដៅក្ដៅដូចព្រះអាទិត្យ សម្ដែងការពិតដោយឥតសំចៃ
សំដិលទោសៈចំកណ្ដាលថ្ងៃ មោហៈចង្រៃវាមកតាមក្រោយ ។
\+ សម្ងំសម្ងាត់ដូចស្ងាត់យូរហើយ ក្រោធមិនកន្ត្រើយចុះខ្សោយឡើយណា
អនុស័យដេកត្រាំក្នុងវដ្តសង្សារ របើកកុសលាពេលវាដឹងខ្លួន ។

(ចប់)សូមអនុមោទនា

# កុំភ្លេចណាកូនណា !

## ( សុភាសិត)

\+ **សូមកូន ប្រុស ស្រី កុំភ្លេច ធ្វើបុណ្យ**
**វិសេស លើសលន់ កុំភ្លេច ធ្វើទាន**
**ធ្វើអំពើល្អ មិនត្រូវ ខ្ជាស់អៀន**
**ការប្រឹងប្រែងរៀន ទើបមាន សំណាង ។**

(ចប់)សូមអនុមោទនា

# ត្រៃលក្ខណ៍ធម៌

## ( បទពាក្យ ៤)

\+ ធម្មជាតិកំណត់កត់ត្រាជីវិត ត្រៃលក្ខណ៍ធម៌ពិតស្ថិតនៅក្នុងលោក
បច្ច័យមានស្រាប់រីករាយទុក្ខសោក កំណត់ចិត្តយកព្រមល្មមក្នុងធម៌ ។
\+ សច្ចៈធម៌ពិតស្ថិតនៅក្នុងចិត្ត ជីវិត ប្រព្រឹត្តទៅ អាក្រក់ល្អ
សខ្មៅទាបខ្ពស់នោះសុទ្ធតែធម៌ វិមុត្តិបវរ ល្អដល់និព្វាន ។

(ចប់) សូមអនុមោទនា

* ២១. ប្រគេន ចង្ហាន់ ដល់ព្រះសង្ឃ គឺមិនតម្រង់ កូនចៅ
ប្រគេន ទេយ្យទាន ឆ្ពោះទៅ គឺមិនចំពោះ កូនក្មួយ
ឱនកាយ ថ្វាយបង្គំ មិនចំពោះ បុគ្គល ណាមួយ(១)
សារពេជ្ញ បណ្ដូលត្រួយ ពិតជួយ ជំនួយ កុសល ។

* ២២. បរិច្ចាគ នូវទ្រព្យ ប្រគេនចំពោះ អរិយសង្ឃ
បង្អោន ឆ្ពោះត្រង់ តម្រង់ អរិយបុគ្គល
កូនអើយ ត្រូវហើយ ខេមរា ថ្លៃថ្លា និមល
ទើបបាន អភិមង្គល វិបុល បរមសុខ ។

---

(១) **មិនចំពោះបុគ្គលណាមួយ** គឺចំពោះតែព្រះសង្ឃ ។

# គុណទឹកដោះម្ដាយថ្លៃ

## ( សុភាសិត)

- ពុទ្ធោអរហំ តាំងគោរពគុណ ព្រះសាស្ដា
  ខ្ញុំ អោក ប៉ូរ៉ា បន្ទន់កាយា ឱនសិរសី
  បង្គំ ក្រាបលុត គុណកែវ ទាំងបី
  ព្រះរតនៈត្រៃ ថ្លៃជាង មាស ពេជ្រ
- ទឹកត្នោត ទឹកអំពៅ យកទៅ ធ្វើស្ករ
  ចោលទឹក មិនល្អ កូនអើយ បាបធំ[១]
  ទឹកដែល ពូកែ គឺជា ទឹកឃ្មុំ
  ទឹកមាន ទុក្ខធំ គឺជា ទឹកភ្នែក ៗ
- ទឹកត្រី ទឹកសៀង និងទឹក ស៊ីអ៊ីវខាប់
  ទឹកទាំងនេះ សំរាប់ ជ្រលក់ ត្រីសាច់
  ទឹកពុល ទឹកពិស ព្រះពុទ្ធ ហាមផ្ដាច់
  ទឹកក្រអូប សម្រាំងស្រេច នោះគឺ ទឹកអប់ ៗ

---

(១) ចោលទឹកមិនល្អទៅលើអ្នកធ្វើដំណើរតាមផ្លូវនៅពេលបុណ្យចូលឆ្នាំគឺមានបាប ។

- ទឹកអូរ ទឹកស្ទឹង ទឹកបឹង និង ទន្លេ
ទឹកធំ ជាងគេ គឺ ទឹកសមុទ្រ
ទឹកដែល គេលក់ ជា ទឹកបរិសុទ្ធ
ទឹកល្អ រហូតផុត គឺ ទឹកចិត្ត វិមុត្តិ ។
- ទឹកភ្លៀង ទឹកជ្រោះ ទឹកមានគ្រោះ គឺ ទឹកជន់
ទឹកបាប ទឹកបុណ្យ ទឹកនោះ គឺ ទឹកចិត្ត
ទឹកឡើង ទឹកស្រក ទឹកមាន វិបរិត
ទឹកដែល គួរគិត ប្រយ័ត្ននោះ គឺ ទឹកស្រា ។
- ទឹកឈូ ទឹកជ្រោះ ទឹកនោះ ហៅ ទឹកធ្លាក់
ទឹកជ្រាំ លោកអ្នក អាចយក ធ្វើជី
ទឹក មន្ត ដាក់ ផ្កា បរិស័ទ មូលមីរ
ទឹកគុណ ពេញទី គឺ ទឹកដោះម្ដាយ ។
- ទឹកដោះម្ដាយ ថ្លៃក្រៃ ឥតឧបមា
កូន ក្នុង លោកា ប្រាថ្នា ទឹកនេះ
ទឹកអើយ មានគុណ ទឹកបុណ្យ ច្រើនម្លេះ
កូនអើយ កុំឆ្វេស ចចេស និរគុណ[១] ។

(១) **និរគុណ** = ដែលរមើលគុណគេ ។

- ទឹកដោះម៉ែ ប្រែក្លាយ ទៅជា ឈាម
កូនចៅ អន្ដាម ទាំងយប់ ទាំងថ្ងៃ
គុណបុណ្យ អ្នកម្ដាយ មិនអាច កាត់ថ្លៃ
កូន ក្នុងលោកីយ៍ អាស្រ័យ ដោះម៉ែ ៗ

(ចប់)

សូមអនុមោទនា

**ស** តើទឹកអ្វីដែលមានតម្លៃជាងគេសំរាប់មនុស្ស និងសត្វទូទៅនៅក្នុងលោកនេះ ?

**ច** ទឹកដែលមានតម្លៃជាងគេសំរាប់មនុស្ស និងសត្វគឺទឹកដោះម្ដាយ ។

**ស** តើទឹកអ្វីដែលមានគ្រោះថ្នាក់ជាងគេ ?

**ច** ទឹកដែលមានគ្រោះថ្នាក់ជាងគេគឺ **ទឹកចិត្តអាក្រក់** ។

**ស** តើទឹកអ្វីដែលល្អបំផុតនោះ ?

**ច** ទឹកដែលល្អបំផុតនោះគឺ **ទឹកចិត្តវិមុត្តិ** ។

**ស** តើទឹកអ្វីដែលព្រះពុទ្ធទ្រង់ហាមមិនឱ្យប្រើនោះ ?

**ច** ទឹកដែលព្រះពុទ្ធទ្រង់ហាមនោះ គឺទឹកពិស ទឹកពុល និងទឹកស្រវឹង ។

# ជំនួញក្នុងព្រះពុទ្ធសាសនា

## ( បទពាក្យ ៨)

\+ ពាក្យថានីហរណ៍[១] អាហរណ៍[២] ការងារស្រោលធូន់ទិញលក់ប្រចាំ
នាំចេញផលិតផលកសិកម្ម នាំចូលជីថ្នាំហើយនិងគ្រឿងចក្រ ។
\+ នាំចេញផលិតផលកៅស៊ូក្រែប នាំចូលគ្រប់បែបថ្នាំលេបថ្នាំចាក់
នាំចេញស្រូវអង្ករជាប្រត្យក្ស[៣] នាំចូលអាត្រាក់សម្រាប់ភ្ជួរដី ។
\+ រោងចក្រនាំចេញសំលៀកបំពាក់ កម្មករសែននាក់ទាំងប្រុសទាំងស្រី
ប្រាក់ខែតិចតួចធ្វើការយប់ថ្ងៃ ដល់ខែដល់ថ្ងៃផ្ទះជួលទឹកភ្លើង ។
\+ រីឯពុទ្ធបរិស័ទនិងព្រះសង្ឃ ជំនួញត្រឹមត្រង់ចំណេញចូលយើង
នាំចេញមោហៈ[៤] ទោសៈ[៥] ខុសរឿង នាំចូលចិត្តសឿងគោរពដឹងគុណ ។
\+ នាំចេញនូវអំពើបាបទាំងឡាយ នាំចូលឱ្យកាយនូវអំពើបុណ្យ
នាំចេញនូវអកុសលទាំងអស់ នាំចូលសប្បុរសនិងទស្សនៈ ។
\+ នាំចេញនូវរាគៈនិងទុច្ចរិត នាំចូលធម៌ពិតហិរិឱត្តប្បៈ
ត្រូវតែនាំចេញសេចក្ដីកំណាញ់ នាំចូលមកវិញសីលល្អផូរផង់ ។

---

(១) **នីហរណ៍** = ការដឹកនាំចេញ , ជំនួញនាំចេញទៅក្រៅប្រទេស
(២) **អាហរណ៍** = ការដឹកនាំចូល , ជំនួញនាំចូលពីក្រៅប្រទេស
(៣) **ប្រត្យក្ស** = ជាក់ច្បាស់ , ប្រាកដមែន
(៤) **មោហៈ** = សេចក្ដីវង្វេង , សេចក្ដីល្ងង់
(៥) **ទោសៈ** = ការប្រទូស្ត , កំហឹង , កំហុស

| | |
|---|---|
| + នាំចេញមុសា សុរាមេរ័យ | នាំចូលរាល់ថ្ងៃសេចក្ដីទៀងត្រង់ |
| នាំចេញអទិន្នាទានិងកាមេ | នាំចូលរាល់ខែថែនូវសទ្ធា ។ |
| + នាំចេញនូវបាណាតិបាតា | នាំចូលបញ្ញានិងមហាធម្មា |
| យើងត្រូវនាំចេញនូវទុក្ខកង្វល់ | នាំចូលមង្គលផ្ដល់ទានឱ្យជាប់ ។ |
| + នាំចេញការព្យាបាទនិងគំនុំ | នាំចូលជួបជុំមេត្តាគួរគាប់ |
| នាំចេញច្រណែនឈ្នានីសប្បុរស្សា | នាំចូលករុណាមុទិតាជាក់ ។ |
| + ត្រូវនាំចេញនូវឧត្បាតចង្រៃ | នាំចូលល្អក្រៃប្រពៃចាគៈ |
| នាំចេញរឹងត្អឹងចចេសមានះ | នាំចូលយកឈ្នះកិលេសខ្លួនឯង ។ |

(ចប់)

សូមអនុមោទនា

(៦) **ទិដ្ឋិ** = សេចក្ដីប្រកាន់តាមការយល់ឃើញ ។

(៧) **ទសពិធ ឬ ទសពិធរាជធម៌** = រាជធម៌ ១០យ៉ាង ឬ ១០ ប្រការ ។ (មើលក្នុងទំព័រ ៧៦)

(៨) **ហិរិ** = ការខ្មាស់បាប , ខ្មាស់ទុច្ចរិត , ខ្មាស់អំពើអាក្រក់ ។

(៩) **ឱត្តប្បៈ** = ការខ្លាចបាប , ខ្លាចអំពើអាក្រក់ ។

(១០) **សីល** = ការរក្សាកាយវាចាឱ្យបរិសុទ្ធប្រពៃ ។

(១១) **សមាធិ** = ដំណើរតាំងស៊ប់មាំនៃចិត្ត, ដំណើរស្ដុងចិត្តស៊ុប ក្នុងអង្គឈាន ។

(១២) **សុរា-មេរ័យ** = សូមមើលក្នុងសៀវភៅកំណាព្យធម៌ភាគ ១ ទំព័រទី ៣១ ។

(១៣) **សទ្ធា** = សេចក្តីជឿបុណ្យ ជឿបាប ជឿកម្ម ជឿផល ។

(១៤) ឧត្បាត = ហេតុឬភាពអាក្រក់ដែល បណ្តាលកើតឡើងខុសពីធម្មតា ។

(១៥) **ឫស្យា** = ព្រៃផ្សៃយង់ឃ្នង ។

(១៦) **ចាគះ** = ការចំណាយធនធានដើម្បីជាសាធារណៈប្រយោជន៍ ការលះបង់ទ្រព្យឱ្យជាទាន ។

(១៧) **មានះ** = សេចក្តីប្រកាន់ខ្លួន , សេចក្តីរឹងត្អឹង ។

(១៨) **កិលេស** = សេចក្តីសៅហ្មងចិត្ត ។

**✳ ២៣. ចេះធ្វើ ជំនួញ នឹងបាន ចំណេញ**
**នាំចូល លក់ចេញ ទៅតាម ទីផ្សារ**
**ឯ ពុទ្ធបរិស័ទ គោរព សាសនា**
**នាំចូល មេត្តា ប្រហារ នូវ បាប ។**

(សូមអនុមោទនា)

# អាក្រក់ជួរជាតិ

## ( សុភាសិត )

- សត្វកុក មានពណ៌ ស កម្រមានខ្មៅ

  មនុស្សអាក្រក់ជាប់ដៅសារជាតិ តិរច្ឆាន

- មានភ្លៀង ចូលផ្ទះ ផ្អាកជូតបោស

  មនុស្សមានទោស កុំយកខ្លួនបៀត ៗ

- ជិះសេះ ស ល្អកុំ ជិះសេះ ខ្មៅ

  មនុស្សល្ងង់ខ្លៅ ជាសត្រូវ ខ្លួនឯង ៗ

- ជិះយានយន្ត លឿនជាង ជិះដើរ

  មនុស្សផិតប្តី អប្រិយ ត ពូជ ៗ

- ជិះទូក ប្រសើរជាង ជិះក្បូន

  មនុស្សស៊ីកូន អាក្រក់ ជួរជាតិ ៗ

(ចប់)

សូមអនុមោទនា ក្នុងការវៀរចាកអំពើអាក្រក់

# ជួយម្ដាយផង

## ( បទសារភញ្ញ )

\+ ទាំងក្នុងទាំងក្រៅ សូមរួមចិត្ត សាមគ្គីឱ្យស្និត កុំរង្គោះ
បែកបាក់ឱ្យសោះ ជាតិមានគ្រោះ ព្រោះសត្រូវនោះ ល្បិចខូចណាស់
ដូច្នេះត្រូវតែ ខំកែខៃ តស៊ូរាល់ថ្ងៃ រំដោះជាតិ
ពីពួកអប្រិយ ក្បត់ដូនតា ធ្វើឱ្យខេមរា ធ្លាក់ចុះសូន្យ ។

\+ សង្គ្រោះសង្គ្រោះ ម៉ែណាស្ងួន កូនមាសនឹមនួន ជួយម្ដាយផង
គេធ្វើបាបម្ដាយ ជាច្រើនដង ម្ដាយឈឺកន្លង ស្ទើមិនកើត
ព្រះចន្ទពេញវង់ ភ្លឺរាត្រី កូនត្រូវពួតដៃ ប្រយុទ្ធខ្លាំង
យកឈ្នះឱ្យបាន កល្យាណស្ងួន ម៉ែជូនពរកូន បានឈ្នះពិត ។

\+ ឱព្រះអាទិត្យ រះឡើងហើយ សព្វជនាអើយ ត្រូវកែគិត
រួមជាកម្លាំង អ្នកសុចរិត ដូនតាសណ្ឋិត កូនខ្មែរយើង
ដេញពួកក្បាលខូច លួចកេរម្ដាយ ឱ្យវាទៅឆ្ងាយ កុំឱ្យនៅ
លក់ខ្មោចលក់ខ្មី ច្រើនពេកកូវ ដល់ពេលដែលត្រូវ កំចាត់[១] ហើយ ។

ណាកូនណា !

(ចប់) សូមអនុមោទនា

---

(១) **កំចាត់ =** គឺកំចាត់ លោភៈ ទោសៈ មោហៈ ទិដ្ឋិ, វិចិកិច្ឆា

# បុណ្យសាងព្រះផ្នួស

## ( បទសារភញ្ញ )

\+ ថ្ងៃពុធសាងផ្នួស បួសជាសង្ឃ នៅចំណុចត្រង់ ពុទ្ធមណ្ឌល
ព្រះសង្ឃភ្នំពេញ ដ៏និមល ពិធីមង្គល ក្នុងសាសនា
សម្មាសម្ពុទ្ធ ដ៏អស្ចារ្យ ព្រះសង្ឃត្រៀបត្រា បព្វជ្ជា
សង្ឃពុទ្ធមណ្ឌល រួមចូលគ្នា ព្រមទាំងញាតិញោម ទីជិតឆ្ងាយ
\+ ថ្ងៃ១៥កើត ខ្នើតខែស្រាពណ៍ ខ្ញុំបង្គំក្រាប លាអបាយ
ពេលនេះតទៅ បុណ្យនាំកាយ ឱ្យចាកចេញឆ្ងាយ អវិជ្ជា
សូមបានរួចផុត ក្នុងវដ្តៈ បានជាសាវ៏ក ព្រះទ្រង់ញាណ
សិអារមេត្រីយ៍ នៅក្នុងគ្រា ព្រះអង្គបានត្រាស់ ជាព្រះពុទ្ធ
\+ ខ្ញុំសូមជូនពរ អ្នកទាំងអស់ ដែលជាសប្បុរស ឱ្យរួចផុត
ចាកនូវទុក្ខទោស គ្រោះអាសន្ន ដោយអំណាចបុណ្យ សាងព្រះផ្នួស
បានសុខសិរី និងលាភយស សូមមង្គលនោះ ប្រាកដដល់
ផលឱ្យឆាប់ៗ គ្រប់អាត្មា មានភ័ព្វវាសនា ស្ថានមិនដល់ ។

( ចប់ ) សូមអនុមោទនា

ធមិសម្រាប់ភាវនាសងគុណព្រះអគ្គី
អ គ្គី បា បំ វិ ន ស្ស តុ ( សូត្រ៦ចប់ )

# បណ្តាំពុកម៉ែ

## ( បទកាកគតិ )

\+ ម៉ែពុកបារម្ភ ក្រែងកូនមិនខំ ដូចពាក្យប្តេជ្ញា
ហេតុនេះចូរកូន ស្ងួនគ្រប់អាត្មា កុំបានតែថា
ថាហើយត្រូវធ្វើ ។

\+ ពុកម៉ែញញឹម ដោយក្តីសង្ឃឹម នូវពាក្យខាងលើ
ម៉ែចាំមើលកូន ចាត់ចែងទង្វើ ដូចគេសរសើរ
ឬមួយយ៉ាងណា ។

\+ កូនមាសកូនពេជ្រ ចូរកូនកុំភ្លេច សច្ចះវាចា
ខន្តិអត់ធ្មត់ ឈ្នះចិត្តឫស្យា មេត្តាករុណា
សំខាន់ណាស់កូន ។

\+ ខ្សែទន់គឺស្វិត កាលណាចងរឹត ពិតជាប់ដូចក្បួន
ទោះបីខំរើ ដល់ជីវិតសូន្យ ខ្សែកូនចងនោះ
គឺសាមគ្គី( គ្នា) ។

( ចប់) សូមអនុមោទនា

ធមិសម្រាប់ភាវនាច្រូចទឹក
ចិ បិ សេ គិ ន បិ លិ ខិ ម អ ឧ ឥ ស្វា សុ

# អាចកុសលធម៌

## ( បទកាកគតិ )

+ អាងសីលអាងទាន អាងនេះគឺមាន អាងក្នុងសទ្ធា
អាងលើកុសល អាងក្នុងធម្មា អាងដេញអវិជ្ជា
អាងប្រព្រឹត្តត្រូវ ។

+ អាងឪអាងម៉ែ អាងបានថ្នមថៃ អាងល្អពេកកូវ
អាងធ្វើកូនល្អ អាងធម៌តម្រូវ អាងអំពើនូវ
អាងបុញ្ញកម្ម ។

+ អាងនូវសុចរិត អាងការប្រព្រឹត្ត ធ្វើល្អប្រចាំ
អាងខាងវិរិយៈ អាងរាល់ខែឆ្នាំ អាងពូជដែលផ្សាំ
ដាំពូជព្រះពុទ្ធ ។

+ អាងដាក់មោហៈ អាងធាក់ទោសៈ អាងចិត្តវិមុត្តិ
អាងចោលលោភៈ អាងចិត្តបរិសុទ្ធ អាងធម៌មោះមុត
អាងផ្តាច់រាគៈ ។

+ អាងព្រះត្រៃរត្ន័ អាងផលទៀងទាត់ អាងបានគារវៈ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃរតនៈ បុញ្ញក្ខេត្តពិតជាក់
សូមថ្វាយបង្គំ ។

+ អាងខាងភាវនា អាងបាននាំគ្នា អាងសាងសុខុម
អាងលះកិលេស អាងព្រះបរម អាងព្រោះខ្លួនខ្ញុំ
កាត់ផ្ដាច់តណ្ហា ។

+ អាងខាងសន្សំ អាងកុសលផ្ដុំ អាងមានបញ្ញា
អាងលះការក្រោធ អាងផុតសង្សារ អាងដ៏អស្ចារ្យ
គឺព្រះនិព្វាន ។

( ចប់ )

សូមអនុមោទនា

**✱ អ្នកអាងកុសលធម៌**

**គឺជាការអាងខាងប្រព្រឹត្តត្រូវតាមឱវាទព្រះពុទ្ធដែល ត្រាស់សំដែងទុកដោយល្អ គឺជាអ្នកមានភ័ព្វ ។**

**✱ ២៤. កើតមក ធ្វើល្អ ក្រនឹង បាន ធ្វើ**
**វាជា ទង្វើ នាំ មក ក្ដីសុខ**
**អំពើ អាក្រក់ នាំទៅ រកទុក្ខ**
**ធ្លាក់ខ្លួន ជាប់គុក សុខរត់ បាត់អស់ ។**

# អាងអកុសលធម៌

## ( បទកាកគតិ )

| | | | |
|---|---|---|---|
| + | អាងខ្លួនធ្វើធំ | អាងចាប់បង្ខំ | អាងខាងទាត់ធាក់ |
| | អាងខាងសំឡុត | អាងដាក់ច្រវ៉ាក់ | អាងចាប់អាងចាក់ |
| | | អាងសម្លាប់ចោល ។ | |
| + | អាងបាញ់ប្រហារ | អាងពូកបាតផ្សារ | អាងចាប់គេថ្កោល |
| | អាងយកដាក់ទោស | អាងដេញអាងដោល | អាងដូចគោខោល |
| | | អាងពូកអាងបក្ស ។ | |
| + | អាងស័ក្តិអាងយស | អាងបង្កគ្រោះ | អាងបង្កថ្នាក់ |
| | អាងវាយដំគេ | អាងបុណ្យអាងស័ក្តិ | អាងគុកច្រវ៉ាក់ |
| | | ដាក់អ្នកក្រីក្រ ។ | |
| + | អាងដាក់គ្រាប់បែក | អាងឈ្លោះប្រកែក | អាងសង្កត់ក |
| | អាងយកជីវាស្រ្ត | អាងខាងមិនល្អ | អាងកាងបន្ត |
| | | ធ្ងន់ធ្ងរហើយយើង ។ | |
| + | អាងចាប់ជីវិត | អាងខាងទុច្ចរិត | អាងប្រឌិតឡើង |
| | អាងយកកំហុស | អាងនោះមិនថ្កើង | អាងរិះរករឿង |
| | | បន្ទំលួចគេ ។ | |

\+ អាងស្រាអាងស្រី អាងខ្លួនកុង្សីយ៍ អាងមិនត្រូវទេ
អាងតែអំណាច កោងកាចគ្មាន់គ្នេរ អាងពីបុព្វេ
អាងខ្លោចព្រោះខ្លៅ ។

\+ អាងលុយអាងកាក់ អាងមាសអាងប្រាក់ អាងខុសជាប់ដៅ
អាងទិញទឹកចិត្ត អាងគិតថាត្រូវ អាងចាស់សក់ស្កូវ
ធ្វើនូវលាមក ។

\+ អាងដាក់បន្ទា អាងបិទផ្លូវផ្សារ អាងក្រុមអាងពួក
អាងខាងបំផ្លាញ អាងស្រែកអាងលក់ អាងដុតភ្លើងភ្នក់
ឱ្យរាស្ត្រក្តៅចិត្ត ។

\+ អាងបំផ្លាញព្រៃ អាងលក់ទឹកដី អាងឱ្យមិនគិត
អាងចិត្តទុរយស អាងខាងវិបរិត អាងអកុសលចិត្ត
ប្រព្រឹត្តពាលា ។

(ចប់)

សូមអនុមោទនា ក្នុងការវៀរចាកអាងខាងអកុសលធម៌

**ស** តើអ្នកអាងខាងប្រព្រឹត្តអកុសលធម៌មានភ័ព្វដែរឬទេ ?

**ឆ** បាទ, ចំពោះអ្នកដែលអាងខាងការប្រព្រឹត្តអកុសលធម៌ គឺគ្មានភព្វ័ទេ គឺអភព្វ័ណាស់ព្រោះអ្នកខ្លះកើតទាន់ព្រះពុទ្ធ

ព្រះធម៌ ព្រះសង្ឃដែរតែដោយសារអវិជ្ជា ហើយទៅប្រព្រឹត្ត តែអកុសល ។ **ឧទាហរណ៍ :** ដូចជាបច្ចុប្បន្ននេះ នៅមាន ព្រះធម៌ ព្រះសង្ឃ មិនតែប៉ុណ្ណោះមានអ្នកប្រាជ្ញ គឺលោក គ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាម្ចាស់ដ៏អស្ចារ្យមកជួយ បង្ហាត់បង្រៀន ហើយអ្នកខ្លះនៅតែមើលមិនឃើញមើល មិនដឹងថា លោកជាអ្នកណាមានគុណធម៌សម្រេចមគ្គផល កំរិតណាក៏មិនដឹងត្រង់នេះ ហើយហៅថា អភ័ព្វ ។

*** ២៥. យុវជន ជោគជ័យ ត្រូវ ពឹងលើ ខ្លួនឯង**
**ចាស់ទុំ កោតក្រែង គាត់ ថ្លែង សរសើរ**
**មនុស្ស ប្រុស ជោគជ័យ ថ្ងៃឱ្យ គ្រាន់បើ**
**សាង គ្រួសារ ប្រសើរ ជោគជ័យ ស្ត្រី ។**

*** ២៦. ជោគជ័យ មនុស្សចាស់ ច្បាស់ ខាង ធ្វើបុណ្យ**
**បោះចោល លោភលន់ ស្រវាំ សីល ទាន**
**ច្រណែន ខឹង ស្អប់ សូមកុំ ឱ្យមាន**
**យកសីល ជាស្ពាន យកទាន ជាស្បៀង ។**

# ទេពអប្សរនៅឆកាមា

## ( បទកាកគតិ)

\+ ខ្ញុំសូមវន្ទា ព្រះភគវា សម្មាសម្ពុទ្ធ
អង្គអរហន្ត ដ៏វិសេសសុទ្ធ ទ្រង់ព្រះវិមុត្តិ[១]
ត្រាស់ទុកព្រះធម៌ ។

\+ ខ្ញុំសែនជ្រះថ្លា ដល់ពួកទេវតា ទេវៈបវរ
ព្រះទ័យស្លូតបូត ព្រះកាយភ្លឺល្អ ពិតទេពអប្សរ
នៅឆកាមា ។

\+ ឈ្មោកសមានឫទ្ធិ ពុទ្ធិ ចរិត[២] ទេវៈចរិយា
មានទេវធម៌[៣] ប្រាកដអស្ចារ្យ [៤]ទេពី ធីតា
នៅឋានសួគ៌ា ។

\+ ទេវៈទូត[៥] ខ្ញុំ សុភាពរម្យទម ជួយគេគ្រប់គ្នា
សូធ្យធម៌ព្រះពុទ្ធ យកមកផ្ចាញ់មារ ឥតិ ទេវា
ក្នុងគ្រាមានទុក្ខ ។

---

(១)**វិមុត្តិ** = គឺការរួចផុតស្រឡះចាកកងទុក្ខបានដល់ព្រះនិព្វាន ។
(២)**ពុទ្ធិចរិត** = អ្នកមានចរិតក្រាស់ទៅដោយការយល់ដឹង មានបញ្ញាស្រាប់មកពីកំណើត ។
(៣)**ទេវធម៌** = គឺធម៌របស់ទេវតា ។
(៤) **ទេពី** = គឺជាភរិយាធំរបស់ព្រះសម្មតិទេព ។
(៥)**ទេវៈទូត** = គឺទេវតាអ្នកទទួលខ្លួនបម្រើសម្រេចកិច្ចការអ្វីមួយ ។

\+ សុខា សុខំ អក្ខរា យន្តំ ពលំវាយបុក

កុសលកើតមាន នាំមកក្តីសុខ គ្រប់ខេត្តគ្រប់ស្រុក

ទូទាំង រដ្ឋា ។

\+ ខន្តិ សច្ចះ មានមោទនះ ដល់ទេពកញ្ញា

ហិរិ ឧត្តប្បៈ[១] មុញ្ចនះចេតនា[២] ទេពា[៣] កិរិយា

ផលានិសង្ស ។

\+ ឧមះមូលមិត្រ ចូលមកឱ្យជិត ធីតាជួយស្រង់

តេជះព្រះធមិ ដ៏ល្អផ្លូវផង់ ជួយអ្នកត្រឹមត្រង់

ឱ្យភ័ព្វវាសនា ។

(ចប់)

សូមអនុមោទនា

---

(១) **ហិរិ ឧត្តប្បៈ** = ការខ្មាសបាបខ្លើមបាប ។

(២) **មុញ្ចនចេតនា** = ការគោរពបុណ្យកុសលរបស់ខ្លួនដែលកំពុងធ្វើ ។

(៣) **ទេពា** = ទេព = ទេព្តា ឬ ទេវតា ។

# ពរទេវតារក្សាឆ្នាំថ្មី

## ( បទកាកគតិ )

\+ ខ្ញុំសូមគារវៈ ព្រះពុទ្ធរតនៈ ធម្មរតនំ
ព្រះសង្ឃសាវ័ក សូមបានសុខំ សូមមានពលំ
បញ្ញាវាងវៃ ។

\+ ធីតាមានឫទ្ធិ ព្រះទ័យសុចរិត ពិតជាមានន័យ
តស៊ូខ្លាំងណាស់ មិនថាយប់ថ្ងៃ សាងយកថ្វីដៃ
ទុកជូនខេមរា ។

\+ កម្ពុ នគរ មានសំណាងល្អ បានទេពធីតា
មកជួយដង្ហែ ថ្វាយព្រះសាសនា តាមពុទ្ធដីកា
គ្រប់ប្រាំពាន់ឆ្នាំ ។

\+ សុវណ្ណភូមិយើង នឹងបានរុងរឿង ចូរយើងចងចាំ
ទាំងប្រុសទាំងស្រី ធីតាបានផ្តាំ ហាមសាងបាបកម្ម
ចាំទុកកុំភ្លេច ។

\+ សាងអំពើល្អ ធីតាជូនពរ តាមជួយជានិច្ច
ឱ្យអ្នកសុខសាន្ត បាននូវមាសពេជ្រ ស្រិតស្រោងឱ្យស្រេច
លាភជ័យហូរចូល ។

\+ ទេពី ធីតា ឈ្មោកក្រពុំផ្កា សល្អដូចហ្វូល
សូមកោតសរសើរ សារពេជ្របណ្ឌូល ទេវៈត្រកូល
មហាកុសល ។
\+ តេជះខ្ញុំសាង ពិតមានសំណាង មកជួបបានស្គាល់
ធីតារាងតូច ចិត្តអស់កង្វល់ ទេពឈ្មោកនិមល
តូចល្អិតចិត្តល្អ ។
(ចប់)

សូមអនុមោទនា

* ២៧. ក្មេងលិច ទីក្រុង លង់ ឡាន ម៉ូតូ
គួរឱ្យ អាសូរ ម៉ូតូ រលត់
ទឹកហូរ ចូលផ្ទះ គួរឱ្យ រន្ធត់
លិចគួរ តក់ស្លុត គឺលិច ចិត្តបុណ្យ ។
* ២៨. ដំបូល រហែក ក្មេងលេច ចូលផ្ទះ
រឹងត្អឹង មានះ លេចចូល ចិត្តបាប
អបាយមុខ គួរតែ គេច ក្រាប
ក្លិនស្អុះ ស្អុយឆ្អាប ដកខ្លួន ឱ្យឆ្ងាយ ។
កុំភ្លេចណាកូនណា!

# ព្យញ្ជនៈពពួក

## ( កាព្យថ្មី )

\+ ក សិនបានកើត ក ជាកំណើត ក កើតផែនដី
ក កើតជាមនុស្ស ក កើតកុះករ ក សាងឱ្យល្អ
ក នោះគេអរ ។

\+ ក កតញ្ញូ ក នេះព្រះគ្រូ ក មានអំណរ
ក បានដឹងគុណ ក មានសំណាង ក ខ្លួនស្អិតស្អាង
ក កើតមានភ័ព្វ ។

\+ ខ ខិត ខ ខំ ខ ខាររួមផ្សំ ខ ខួរ ឱ្យគាប់
ខ ខាប់ប្រជា ខ ខេត្តទាំងអស់ ខ ខំដោយស្មោះ
ខ ខែងខេមរា ។

\+ ខ ខុស ខ ខូច ខ ខិលផ្លែកផ្លូច ខ ខុសតម្រា
ខ ខ្លះជៀសវាង ខ ខុសខ្លួនខ្លៅ ខ ខ្លោចជាប់ដៅ
ខ ខាតនាំខ្វល់ ។

\+ គ ក្បៀរគយគន់ គ គីឈើធ្ងន់ គ ដាំយកផល
គ ដាក់ក្នុងវត្ត គ នោះមានបី គ រតនៈត្រៃ
គ ថ្វាយជាម្លប់ ។

\+ ឃ ឃាត់ឃោសនា ឃ ឃើញវាចា ឃ ឃាត់ទាំងយប់
ឃ អើយឃ្លាតច្បាប់ ឃ ឃុំយុវជន ឃ ឈ្លៀងឃ្លាតបុណ្យ
ឃ ធ្ងន់ខ្លួនហើយ ។

\+ ង ងើល ងងប់ ង ងើលឥតឈប់ ង ងឹតទាំងថ្ងៃ
ង ងប់នឹងបាប ង ងាយនឹងធ្វើ ង ងោកទង្វើ
ង ងុយភ្លេចបុណ្យ ។

\+ ច ចារចាប់ចង ច ចែងច្បាប់ច្បង ច ចែកជាគុណ
ច ចាស់ចារទុក ច ចាសបាទទាន ច គួរឱ្យរៀន
ច ចាប់ចុចយក ។

\+ ឆ កាមាសួគ៌ ឆ វិវណ្ណគួរ ឆ ល្អនឹកភ្នក
ឆ ទានសាលា ឆ ធ្វើជម្រក ឆ ដាបានមក
ឆ ឆាប់ឱ្យផល ។

\+ ជ ដែកជីកធម៌ ជ ជក់បានល្អ ជ ជាប់បានដល់
ជ តា ជនទាថ ជ ជាតិជាខ្មែរ ជ ន នីពូកែ
ថែ កម្ពុជា ។

\+ ឈ ឈានបំពាន ឈ ឈប់ឈ្លានពាន ឈ ឈាមដូចគ្នា
ឈ ឈមទៅច្បាប់ ឈ ចាប់ដៃគ្នា ឈ ឈោងជានា
ឈ ឈ្មោះល្បីល្បាញ ។

+ ញ ញើមជានិច្ច ញ ញែមកុំភ្លេច ញ ញាំងសើចស្វាញ
ញ ញ័រមានស្នេហ៍ ញ ញាតិក្នុងប្រាណ ញ ញាត់ឱ្យបាន
ញ ញើតលែងហ៊ាន ។

+ ដ ដកដង្ហើម ដ ដក់ចិត្តថ្លើម ដ ដល់និព្វាន
ដ ដងដឹងគុណ ដ ដកទុក្ខភ័យ ដ ដាក់ទង់ជ័យ
ល្អក្រៃព្រះធម៌ ។

+ ឋ ឋានបានសុខ ឋ ឋានរៀបទុក ឋ ឋានបវរ
ឋ ឋានទេវតា ឋ ឋានព្រោះបុណ្យ ឋ ឋានដឹងគុណ
មាតាបិតា ។

+ ឌ ឌិនដូចមាស ឌ ឌាពេញពាស ឌ ឌុនជ្រះថ្លា
ឌ ឌឹដាក់គ្នា ឌឹ ដងមេត្តា ឌុក ដាន់នោះណា
មេត្តាបោះចោល ។

+ ឍ ល្អវុឌ្ឍិ[១] ឍ មានហិរិ ឍ ដូចឍោមរា[២]
ឍ ឍោល[៣] ទូងដាស់ ឍ ជាឍោលិន[៤] ឍ បានកាន់បិណ្ឌ
ឍ លាភវុឌ្ឍិ[៥] ។

---

(១) **លាភវុឌ្ឍិ** = សេចក្ដីចម្រើនដោយលាភ
(២) **ឍោមរា** = ក្ងាន ឬ ហង្ស
(៣) **ឍោល** = ស្គរធំ
(៤) **ឍោលិន** = អ្នកកាន់ខែល
(៥) **វុឌ្ឍិ** = សេចក្ដីចម្រើន , ការដុះដាល

\+ ណ ណាត់ហ្មត់ចត់ ណ ណាយប្រាកដ ណ ណា បញ្ចក្ខន្ធ
ណ ណាស់ឃើញទោស ណ នុ៎ះឃើញធម៌ ណ ណាយពិតល្អ
ណ លាលោកនេះ ។

\+ ត តថាគត ត ព្រះវិមុត្តិ ត តោងត្រិះរិះ
ត កតញ្ញូ ត ត្រង់បានត្រាស់ ត តម្កើងច្បាស់
ត តបធម៌[១] ។

\+ ថ ថតគុណព្រះ ថ ថយសំពះ ថ ថង់ត្រង់ល្អ
ថ ផលយាត្រា ថ ថាមពលមាន ថ ថាសជាស្ថាន
ថ ថិរាយុ[២] ។

\+ ទ ទឹម ទទាក់ ទ ទុក្ខជាអ្នក ទ ទាញនូវសត្វ
ទទួលផលបាប ទ ទាក់ឱ្យទៅ ទ ទណ្ឌជ្រោះជ្រៅ
ទ ទេគ្មានបុណ្យ ។

\+ ធរមានធរណី ធម្មធរ សំភី ដោយការអត់ធន់
ផ្សព្វផ្សាយព្រះធម៌ បង្កើនសទ្ធា បវរធម្មា
ប្រសើរលើសលន់ ។

---

(១) **តបធម៌** = ធម៌សំរាប់ប្រព្រឹត្តដើម្បីដុតបំផ្លាញគ្រឿងសៅហ្មង ។

(២) **ថិរាយុ** = ដែលមានអាយុយឺនយូរ

+ ន អ្នកនិមិត្ត[១] ន នាំកាយពិត ន នាមដឹងគុណ
ន នាងនាថសុខ ន នាំឋានសួគ៌ ន នាឋានគួរ
ន នៃអ្នកបុណ្យ ។

+ ប បត់បែនបាន ប បង់បោយប្រាណ ប បង្ខំធ្ងន់
ប បង្គាប់ប្រាប់ ប បង្ក្រាបបាប ប បំបាត់ឆ្អាប
ក្នុង បុគ្គលខ្លួន ។

+ ផ ផាត់ ផ ផាយ ផ ផាត់ឱ្យឆ្ងាយ ផ ផលគំគួន
ផ ផស្សះភ្នែក ផ ផរុសវាទ[២] ផ នាំឱ្យឃ្លាត
ផាត់ឆ្ងាយពីខ្ញុំ ។

+ ព ពក ពពាយ ព ពណ្ណរាយ[៣] ព ព័ទ្ធកងជុំ
ព ពណ៌ឆព្វណ្ណ ព ពណ៌បារមី ព ព្រះជិនស្រី
ពណ៌មានប្រាំមួយ ។

+ ភ ភក្រ្តមានភ័ព្វ ភ ភណ្ឌ[៤] បានគាប់ ភ ភត្តជំនួយ
ភ **ភ គ ឞ** ភ ភស្សាហារ ភ ភោគសាស្តា
ភត្តាមានបុណ្យ ។

---

(១) **និមិត្ត** = ដើមហេតុ , លក្ខណៈ , គោល , ចារឹក , គ្រឿងសម្គាល់

(២) **ផរុសវាទ** = សម្តីអាក្រក់ ឬ ពាក្យទ្រគោះបោះបោក

(៣) **ពណ្ណរាយ** = ដែលមានពន្លឺភ្លឺត្រចះល្អប្រពៃ

(៤) **ភណ្ឌ** = ទ្រព្យ , របស់ , ដើមទុន , គ្រឿងប្រដាប់ប្រើប្រាស់

\+ ម កម្ពុជា ម មូលនាំគ្នា ម ម្ដាយមានគុណ
ម មគ្គទាក់ចិត្ត ម មយវិន[១] ម គតិគ្រាន់
ម មានសម្បត្តិ ។

\+ យ យប់យថ្ងៃ យ យកនិស្ស័យ យ តាមបញ្ញត្តិ
យ ដូចមាតា យ ក្រិតចិត្តស្មោះ យ កេរទាំអស់
យកទុកឱ្យបាន ។

\+ រ រាល់រូបកាយ រស់រាន់ជួយម្ដាយ រាប់ឱ្យថ្កើងថ្កាន
រដ្ឋ យើងមានទុក្ខ រាជាខ្លោចផ្សា កូនអើយមេត្តា
រួសរាន់រំដោះ ។

\+ ល លក្ខណា ល លាម[២] ដូចផ្កា ល លិត[៣] ចិត្តស្មោះ
ល លឹម[៤] ភ្នែករក ល លាក់ក្នុងចិត្ត លួងឱ្យអាណិត
ចិត្តប្រតិពទ្ធ ។

\+ វ ពង្ស វង្សា វ វង្សខេមរា វ វត្តវិឡូនះ
វ វណ្ណមាសពេជ្រ វ វាំងវត្តវ៉ា វ វាលរក្សា
ព្រះសាសនាយើង ។

---

(១) **មយវិន ឬ មយវន្ត** = អ្នកមានចិត្តទូលាយ , អ្នកចែកទ្រព្យឱ្យគេ ។

(២) **លលាម** = ស្រស់ល្អ. ឆើតឆាយ. រុងរឿង ។

(៣) **លលិត** = ដែលគួរឱ្យស្រលាញ់. គួរឱ្យចាប់ចិត្ត ។

(៤) **លលឹម** = ពព្រឹម ភ្នែកពព្រឹម ។

+ ស អើយស័ក្តិសិទ្ធិ សក្កៈមានឫទ្ធិ ស ល្អរុងរឿង
ស សមទេវរាជ សំរាប់ទេព្តា ស បុណ្យផលា
សម្រេចរួចហើយ ។

+ ហ ហេងហៀវហួរ ហ ហេតុសម្បួរ ហ ហាលដល់ត្រើយ
ហ ហេមពាន្ត ហ ហើបហើយហោះ ហ ហើរឥតខ្ចោះ
ព្រោះនោះទេវតា ។

+ ឡ ឡាឡប់ឡែ ឡិមឡុមតែឡែ ឡឡិឡឡក់
ឡប់ឡិនហិនហោច ឡិបឡុបចៅឡិន ឡកឡឺយនេះប៉ិន
ដូចឡប់សតិ ។

+ អ គុណអនេក[១] អ ល្អពន់ពេក អមានហិរិ[២]
អ អឺអ៊ូម្លេះ អ អញ្ជូអនត្តា[៣] អអត់ដឹងថា
ថ្ងៃណានឹងស្លាប់ ។

(ចប់)

សូមអនុមោទនា

(១) **អនេក** = គឺច្រើនដែលរាប់ពុំបាន , ប្រមាណពុំអស់
(២) **ហិរិ** = សេចក្តីខ្មាស់បាប ។
(៣) **អនត្តា** = មិនមែន , ពុំមែន , ឥត

**ស** តើអ្វីដែលមានទម្ងន់ធ្ងន់ជាងគេនៅក្នុងលោកនេះ ?

**ច** គឺ ទម្ងន់អំពើបាប ។

**ឧ** : របស់អ្វីក៏ដោយនៅលើលោកនេះក៏ផែនដីទ្រទ្រង់ដែរ គឺលើកលែងតែទម្ងន់អំពើបាប ១គត់ ដែលផែនដីមិនអាចទ្រទ្រង់បានដូចជា ទម្ងន់អំពើបាបរបស់នាងចិញ្ចា , ទេវទត្ត ។ល ។

**ស** តើពុទ្ធបរិស័ទត្រូវឃើញភ័យអ្វីខ្លះដែលជាផ្លូវនាំឱ្យមានទុក្ខ ?

**ច** ពុទ្ធបរិស័ទត្រូវឃើញភ័យក្នុងសេចក្ដីខ្ជិលច្រអូស ១ ឃើញភ័យក្នុងវិវាទ ១ ឃើញភ័យក្នុងសេចក្ដីប្រមាទ ១ ។

**ស** តើត្រូវឃើញអ្វីទៅវិញ ដែលជាផ្លូវនាំឱ្យមានសេចក្ដីសុខក្សេមក្សាន្តនោះ?

**ច** **ទី១** ត្រូវឃើញនូវសេចក្ដីព្យាយាមថា ជាផ្លូវនាំឱ្យមានសេចក្ដីសុខក្សេមក្សាន្ត ។

**ទី២** ត្រូវឃើញការមិនមានវិវាទថា ជាផ្លូវនាំឱ្យមានសេចក្ដីសុខក្សេមក្សាន្ត ។

**ទី៣** ត្រូវឃើញការមិនប្រមាទថា ជាផ្លូវនាំឱ្យមានសេចក្ដីសុខក្សេមក្សាន្ត ។

**ស** តើអានិសង្សរបស់អ្នកមាន **សីល** មានប៉ុន្មានយ៉ាង ?

ច  អានិសង្សរបស់អ្នកមាន **សីល** មាន ៥ យ៉ាងគឺ :

**ទី១** ដល់ព្រមដោយភោគសម្បត្តិ ។

**ទី២** មានកិត្តិគុណ កិត្តិសព្ទល្បីខ្ចរខ្ចាយទៅឆ្ងាយ ។

**ទី៣** មានសេចក្តីក្លៀវក្លាក្នុងកណ្តាលបរិស័ទ ។

**ទី៤** នឹងមិនវង្វេងនៅពេលជិតស្លាប់ ។

**ទី៥** ស្លាប់ហើយនឹងទៅកើតនៅសុគតិសួគ៌ទេវលោក ។

* ២៩. កសិករ ធ្វើស្រែ ប្រាំង និង វស្សា
មន្ត្រី រាជការ ធ្វើ កិច្ចការ រដ្ឋ
ការងារ គ្រប់ផ្លូវ ត្រូវឱ្យ ប្រាកដ
ព្យាយាម កំណត់ បែបបទ តាម ច្បាប់ ។

* ៣០. ច្បាប់ អន្តរជាតិ និង កម្ពុជា
ត្រូវតែ នាំគ្នា គោរព ឱ្យ ល្អ
មាគ៌ា ត្រឹមត្រូវ សុចរិត ស្មោះសរ
ដូចខ្មែរ អង្គរ ល្បីពេញ លោកា ។

# សម្លាប់បានបុណ្យ
## ( បទកាកគតិ)

+ សិទ្ធីលាភា ខ្ញុំសូមវន្ទា ព្រះរតនៈត្រៃ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃល្អក្រៃ សុំភ្ជាប់និស្ស័យ
រហូតនិព្វាន ។

+ សម្លាប់ទោសៈ ព្រមទាំងមោហៈ និងការបៀតបៀន
សម្លាប់ទិដ្ឋិ ក្នុងខ្លួនដែលមាន រាប់រយរាប់លាន
សម្លាប់ឱ្យអស់ ។

+ សម្លាប់រាគៈ និងមោហោជាក់ នៅពួនក្បៀនកោះ
ព្យាយាមសម្លាប់ ដោយចិត្តត្រង់ស្មោះ កិលេសទាំងអស់
ឱ្យសូន្យពីខ្លួន ។

+ សម្លាប់វិចិកិច្ឆា នៅក្នុងអាត្មា សេសសល់បីបួន
សម្លាប់មានះ រឹងត្អឹងជូរជួន លោភៈពាក់ដួន
រកក្បួនសម្លាប់ ។

+ សម្លាប់មុសា រួមទាំងតណ្ហា ចោលជាប្រញាប់
ភវាសវៈ(១) សម្លាប់ចាក់ចាប់ កាត់ចោលឱ្យឆាប់
ដេកត្រាំក្នុងភព ។

---

(១) ***ភវាសវៈ*** = ធម៌ជាគ្រឿងត្រាំគឺភព ។

\+ សម្លាប់អកុសល ជាបាបអំពល់ ងងឹតដូចយប់
អវិជ្ជាសវៈ[២] ទាក់ក្ដាសេពគប់ ល្ងង់ល្ងិតឥតឈប់
ជាប់ភពមិនដឹង ។

\+ សម្លាប់យប់ថ្ងៃ ឱ្យវាក្សិណក្ស័យ បាបធម៌អស់ហ្នឹង
សម្លាប់ផ្ដាច់ពូជ លោភៈធូរតឹង ព្យាបាទសុទ្ធសឹង
សម្លាប់បានបុណ្យ ។

(ចប់)

សូមអនុមោទនា

**ស** ចុះហេតុអ្វីបានជាថាសម្លាប់បានបុណ្យទៅវិញ ?

**ច** បាទ, សម្លាប់បានបុណ្យ គឺសម្លាប់អំពើបាបត្រង់ចំណុចនេះ ចង់សំដៅទៅលើព្រះអរិយបុគ្គល លោកបានសម្លាប់ចោលអស់នូវ លោភៈ ទោសៈ មោហៈ ទិដ្ឋិ វិចិកិច្ឆា និងអកុសលធម៌នៅក្នុងខ្លួនទាំងអស់ដែលជាឫសគល់ និងជាពូជសំរាប់ចាក់ដោតចុះជាប់ក្នុងភព ឬ ដុះឡើងនៅក្នុងភពឱ្យស្លាប់បង់ដោយមិនអាចបន្តអន្ទោលទៅ នៅក្នុងសង្សារវដ្ដទៀតឡើយពោល គឺព្រះអង្គបានដល់នូវវិមុត្តិ គឺព្រះនិព្វាន ។

(២) ***អវិជ្ជាសវៈ*** = ធម៌ជាគ្រឿងត្រាំ គឺ អវិជ្ជា ។

# ធ្វើទានមានទ្រព្យធន

## ( បទពាក្យ ៧)

\+ បើជីវិតរស់នៅកុំខ្លាចហត់ តស៊ូអំណត់ប្រាកដនូវធមិ
ព្យាយាមដុសខាត់ចិត្តទើបបានល្អ ដូចរែងអង្ករើសយកតែដើម ។
\+ បើជីវិតរស់នៅកុំខ្វល់ក្រ តាំងចិត្តត្រេកអរស្មោះសរចាប់ផ្ដើម
បញ្ចោញសទ្ធាយកជាដង្ហើម ដូចទឹកសន្សើមជួយដល់រុក្ខជាតិ ។
\+ ជីវិតនៅរស់ត្រូវប្រឹងឱ្យខ្លាំង កុំថ្នមកម្លាំងកុំចិត្តចង្អៀត
មានតិចធ្វើតិចកុំភ្លេចឃ្លៀងឃ្លាត ធ្វើទានត្រូវឆ្លៀតកុំភ្លេចឱ្យសោះ ។

(ចប់) សូមអនុមោទនា

*** ៣១. ស្ងួនផ្កា ជាសម្រស់ របស់ គេហដ្ឋាន
សុខក្សេមក្សាន្ត ជាសម្រស់ របស់ ឋានសួគ៌
សម្រស់ របស់ នារី បព្វជិត មិនគួរ
កាមវិតក្ក រកពួរ ចងទាញ ឱ្យឆ្ងាយ ។**

*** ៣២. ដើមត្នោត ជាសម្រស់ របស់ កម្ពុជា
កើត ចាស់ ជរា ជាសម្រស់ របស់ វត្ថុៈ
សម្រស់ ព្រះពុទ្ធ សាសនា មាន មហាសារកៈ
ល្អជាង មាស ប្រាក់ គឺ និព្វាន ព្រះសាស្ដា ។**

# ធម៌សំរាប់ភាវនាតាមឆ្នាំកំណើត[(១)]

## ១_ឆ្នាំជូត :

ឧម នមោ ពោធិសត្តោ ព្រះដីមេលោ សម្មា ទេវរាជា សុនន្ទសារថី ទេវធីតាសិទ្ធី កា សត្តរាជា បធាទីយោ សារថី ស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះ កាលព្រះសុនន្ទសារថីយកព្រះដីមេយ៍ ទៅកប់ក្នុងដី នាងទេពធីតាឱ្យព្រះគាថានេះទៅ ភាវនារួចបានទៅសោយរាជវិញហោង ។

## ២_ឆ្នាំឆ្លូវ :

សិទ្ធិតោ លោកេ ឧត្តធី វត្តធី ឧត្តមោ សិទ្ធី អនេកជាតិ សង្សារំ ឧត្តបាទី ឧត្តមោ តទ្វោតរំ នថោ អថោ មស្មិ សិទ្ធី លោកេ ឧត្តធី ឧត្តមោ ស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះ កាលទេវតាឱ្យព្រះសិទ្ធត្ថភាវនា៧ ចប់ រាល់ថ្ងៃផ្តាច់វដ្តសង្សារហោង ។

## ៣_ឆ្នាំខាល :

ឧម នមោ សិទ្ធី វិធុរោ ទេវតា សិទ្ធី មហាបញ្ញោ ចករោ សិទ្ធី ភូតានំ សិទ្ធី ស្វាហះ ។

---

(១) សូមលោកអ្នកជ្រើសរើសយកមកភាវនាតាមអាធ្យាស្រ័យនូវកម្មដ្ឋានមានអារម្មណ៍ ៤០ ។

**បញ្ជាក់** : ព្រះគាថានេះ កាលព្រះឥន្ទឱ្យព្រះវិធូរៈភាវនា កាលបាណេកយក្ខ ចងនៅកន្ទុយសេះឱ្យស្ទូត្រ ៧ចប់ រួចពីកន្ទុយសេះវិញហោង ។

**៤_ឆ្នាំថោះ** :

ឧម នមោ សិទ្ធី មាតុលី អរញ្ញោ ទេវត្តោសិទ្ធី បជាសិទ្ធី សក្កោ ទេវរាជា យមោ រាជាស្វាហៈ ។

**បញ្ជាក់** : ព្រះគាថានេះកាលព្រះឥន្ទឱ្យព្រះនិម្មរាជ ភាវនា ១ ថ្ងៃ ៧ចប់ បានសោយរាជជាស្តេចរួចហើយ ព្រះឥន្ទឱ្យព្រះមាតុលីចុះមកនាំព្រះនិម្មរាជឡើង ទៅឋានសួគ៌ហោង ។

**៥_ឆ្នាំរោង** :

ឧម នមោ សិទ្ធី ចន្ទកុមារោ តេជោ ឥតិបិសោ

ពោធិសត្តោ សិទ្ធី ឥតិស្វាហៈ ។

**បញ្ជាក់** : ព្រះគាថានេះទេវតាឱ្យចន្ទកុមារ ភាវនាកាលកង្ហាលព្រាហ្មយកទៅបូជាភ្លើង គង់ភាវនាគាថានេះរួចពីភ្លើងវិញហោង ។

**៦_ឆ្នាំម្សាញ់ :**

ឧម នមោ ពោធិសត្តោ សិទ្ធី ជិនកោរាជា សិទ្ធី
មនីខលា ទេវតា មហាសមុទ្រ ចតុទ្ធិ សិទ្ធី មេខលា
សោ អគ្គិ ស្វាហះ

**បញ្ជាក់ :** ព្រះគាថានេះ ទេវតាឱ្យព្រះជិនកភាវនាកាលហែល
ទឹកសមុទ្រ ហើយបានទៅសោយរាជវិញហោង ។

**៧_ឆ្នាំមមី :**

ឧម នមោ សិទ្ធី មុនី ពោធិសត្តោ មហាតេជោ នារទ
ព្រាហ្មណោ ឥតិបិសោ សិទ្ធី ឥតិស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះកាលទេវតាឱ្យព្រះនារទ ព្រាហ្មណ៍
ភាវនា ១ថ្ងៃ ៧ចប់ ផ្ចាញ់អន្យតិរ្ថីយ៍ ព្រះអង្គបាន
ឈ្នះទមិឡរួចហើយបានលុះដល់អរហត្តមគ្គហោង ។

**៨_ឆ្នាំមមែ :**

ឧម នមោ សិទ្ធី តេជោ សិទ្ធីតេជោ សិទ្ធីវុឌ្ឍី
សិទ្ធីយា ឆត្ត ទណ្ឌកុមារោ បណ្ឌិយ សិទ្ធី វេលាហ
រាជា ទេវតា ព្រាហ្មណោ សិទ្ធី ស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះ កាលព្រះឥន្ទឱ្យឆ័ត្រទណ្ឌភាវនាពួក
សត្រូវក៏ចុះចាញ់ដោយអំណាចព្រះគាថានេះហោង ។

**៩_ឆ្នាំរកា :**

ឱម នមោ សិទ្ធី តេជោ សិរីសិទ្ធីយោ មហាសថ៌ កុមារោចន្ទ សិទ្ធី ទេវតារាជា ទេវតា ព្រាហ្មនោម សិទ្ធី ស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះ កាលព្រះឥន្ទឱ្យព្រះមហោសថភាវនា ១ថ្ងៃ ៧ចប់ ដើម្បីផ្ចាញ់អាចារ្យវត្តព្រាហ្មណ៍ ហើយអាចារ្យវត្ត ព្រាហ្មនោះចាញ់ ព្រះមហោសថ រួចព្រះអង្គយកកែវទិព្វបានហោង ។

**១០_ឆ្នាំរកា :**

ឱម នមោ ពោធិសិទ្ធី វេសន្តរោ ពោធិសត្តោ ឥតិសម្ពោធិយ រាជា ឥតិមទិយោ ឥតិជាលី កុមារោ ឥតិកណ្ហា កុមារ ជូជកោ ឥតិស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះ កាលទេវតាឱ្យព្រះវេស្សន្តរភាវនា កាលនៅក្នុងព្រៃ ១ថ្ងៃ ៧ចប់ ទុក្ខភ័យអន្តរាយទាំងពួងក៏បាត់អស់ ហើយបានមកសោយរាជក្នុងព្រះនគរវិញហោង ។

**១១~ឆ្នាំច :**

ឧម នមោ ពោធិសត្តោ សុវណ្ណសាមោ សិទ្ធីទេវធីតា ធារិកា សិទ្ធី ទុក្ខា រាជា មិត្តសទ្ធា នត្ថិ ស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះកាលព្រះឥន្ទឱ្យសុវណ្ណសាមភាវនា ១ ថ្ងៃ ៧ចប់ ទុក្ខភ័យផងទាំងពួង ក៏វិនាសបាត់អស់ ហើយបានសុខដូចប្រាថ្នាហោង ។

**១២~ឆ្នាំកុរ :**

ឧម នមោ សិទ្ធីតេជោ ភូរិទត្តោ ចន្ទវិសគ្គោ អចយន្តោ សិទ្ធី ស្វាហះ ។

**បញ្ជាក់ :** ព្រះគាថានេះ កាលទេវតាឱ្យភូរិទត្តភាវនាកាលដែលម្ដាយគាត់ចាប់ដាក់ទ្រុងឱ្យភាវនា ១ថ្ងៃ ៧ចប់ ហើយបានរួចពីទ្រុងវិញហោង ។

(ចប់)

សូមអនុមោទនា

## ១~ ព្រះគាថាប្រមូលទ្រព្យដ៏ស័ក្តិសិទ្ធិ

- ឱម: ចូល មហាចូល ឱម: ប្រមូលមហាប្រមូល សិរីមាស សុប្រាក់ មង្គលពេជ្រ មហារតនៈ ពលៈ សិទ្ធីលាភ ឥហិមមៈ។

(សូត្រ៣ចប់)

## ២~ ព្រះគាថាហៅលាភស័ក្តិសិទ្ធិ

- សិរីប្រាក់ សុប្រាក់ ន ម ព ទ លាភ ភំ ភំ ស្វាហយៈ ។

(សូត្រ៧ចប់)

## ៣~ ព្រះគាថានាំសម្បត្តិចូលដោយត្រជាក់

- ឱម នមោ មហាលាភោ មហាលាភំ មហាធនំ មហាសុខំ សិទ្ធីភោគំ មហារតនំ យទិទំ អត្ថិ ស្វាហៈ ។

(សូត្រ៣ចប់)

## ៤~ ព្រះគាថាសីវលីកំពូលលាភ

- ឱម នមោ សីវលីចក្ក មហាថេរោ តេជោ មហាសុខោ ពោធិសត្តោ សិទ្ធីមហាលាភ ធនំ វឌ្ឍកោ ឧត្តមោ ស្វាហៈ ។

(សូត្រ៧ចប់)

## ៥~ ព្រះគាថានាំលាភស័ក្តិសិទ្ធិ

- សិទ្ធី មហាភោគំ សិទ្ធីវណ្ណំ សិរីលាភំ ឥតិផលៈ វណ្ណំ សព្វសុខំ ភវន្តុមេ ។

(សូត្រ៧ចប់)

## ៦. ព្រះគាថាមហាលាភ

- សិទ្ធិមហាយសំ សិទ្ធីមហាលាភំ សិទ្ធិមហាភោគំ សិទ្ធិមហាសុខំ សីវលីចក្កមហាថេរោ ពុទ្ធំ ធម្មំ សង្ឃំ ត្រៃរតនៈធាយំ សុខោ តក្កោ អយំ នូវណា សារិកា នំ នំ កបោហោហិ ។

(សូត្រ៧ចប់)

## ៧. ព្រះគាថាសុំសុខបានលាភយស

- សព្វពុទ្ធានុភាវេនៈគុណំ មហាសិទ្ធិយសំ សព្វធម្មានុភាវេនៈគុណំ មហាសិទ្ធីភោគំ សព្វសង្ឃានុភាវេនៈគុណំមហាសិទ្ធិលាភំ សព្វទេពានុភាវេនៈគុណំ មហាសិទ្ធិសុខំ ឥតិ ផលៈវណ្ណំ សព្វសុខំ ភវន្តុមេ ។

(សូត្រ៣ចប់)

## ៨. ព្រះគាថាឆ្លងកំសត់ក្រោកជមាន

- ពុទ្ធោអរហំ មហិទ្ធិឫទ្ធិ តេជះ មេឃដី និងសមុទ្រ សូមជួយខ្ញុំ ឱ្យឆ្លងផុតពីភាពក្រខ្សត់ និងអត់ឃ្លាន បានក្លាយជាអ្នកមាន ទ្រព្យសម្បត្តិស្តុកស្តម្ភ ត្រដឹមត្រដែតត្រសៃតទៅហោង ។

(សូត្រ៣ចប់)

# បណ្ដាំខ្មែរឃាសក លោក ប៉ូរ៉ា

**ទី១** សូមសូធ្យរំលឹកគុណព្រះរតនៈត្រៃជាមុនសិន។ សូមលោកអ្នកសូធ្យព្រះគាថាទាំងនេះ ជារៀងរាល់ព្រឹក មុននឹងចេញទៅធ្វើការងារ ឬ រកទទួលទានផ្សេងៗនោះរួច ហើយត្រូវបូជាប្រាក់ដាក់ទៅក្នុងផ្ដិល ដែលនៅចំពីមុខ អាសនៈ ឬ ហ៊ឹងព្រះនៅក្នុងផ្ទះជារៀងរាល់ថ្ងៃទៅតាម សទ្ធារបស់ខ្លួនហើយបានរយៈពេល ៧ថ្ងៃ ត្រូវយកប្រាក់ នោះទៅទិញចង្ហាន់ថ្វាយព្រះសង្ឃ ។

**ទី២** ហាមសេពគ្រឿងស្រវឹង ឬទឹកស្រវឹង ។

**ទី៣** កាន់សីលប្រាំ ។

**ទី៤** ហាមធ្វើអំពើអាក្រក់ និង អបាយមុខ ។

**ទី៥** ធ្វើអំពើល្អ ។

**( ត្រូវធ្វើដូចនេះរហូត និងចម្រើនល្អតលាស់មានលាភហូរចូល ដោយត្រជាក់ត្រជុំសុខសប្បាយទៅហោង )។**

សៀវភៅកំណាព្យធម៌ចាប់ពី ភាគ១ ដល់ ភាគ៨ សរុបមានរហូតដល់ទៅ ២៦២អត្ថបទ និងកាព្យខ្លីៗចំនួន ២៩០ ដែលនិពន្ធ និងរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ **អោក បូរ៉ា** មានមាតិកាកំណាព្យតាមលំដាប់លំដោយដូចខាងក្រោមៈ

## មាតិកា កំណាព្យធម៌ភាគ ១


| ល.រ | ឈ្មោះកំណាព្យ | មេបទ | ទំព័រ |
|---|---|---|---|
| ១ | ឆពណ្ណរង្សីព្រះពុទ្ធសាសនា | កាកគតិ | ៣ |
| ២ | ធម្មយាន | ពាក្យ ៨ | ៧ |
| ៣ | ទោសរបស់បញ្ចក្ខន្ធ | ពាក្យ ៨ | ៩ |
| ៤ | សោរច្ចៈខន្តី | កាកគតិ | ១២ |
| ៥ | ក្រ ១៥ យ៉ាង | ពាក្យ ៨ | ១៥ |
| ៦ | កុសលផលបុណ្យ | កាកគតិ | ១៧ |
| ៧ | គុណមាតា បិតា | កាកគតិ | ២១ |
| ៨ | គុណគ្រូ | កាកគតិ | ២៥ |
| ៩ | បញ្ចសីល | កាកគតិ | ២៩ |
| ១០ | ធម្មសាកច្ឆា | ពាក្យ ៧ | ៣៧ |
| ១១ | អនន្តរិយកម្ម | ព្រហ្មគីតិ | ៣៩ |
| ១២ | កម្មជាគ្រាប់ពូជ | កាកគតិ | ៤១ |

| | | | |
|---|---|---|---|
| ១៣ | ទាន | កាកគតិ | ៤៩ |
| ១៤ | ពុទ្ធស្ថានគារវតា | កាកគតិ | ៥៥ |
| ១៥ | ព្រះគន្ធកុដិ | កាកគតិ | ៥៨ |
| ១៦ | ឃើញភ័យ | កាកគតិ | ៦៣ |
| ១៧ | ចំណង ៨ ប្រការរបស់ស្ត្រី | កាកគតិ | ៦៨ |
| ១៨ | បុញ្ញកិរិយា ១០ យ៉ាង | កាកគតិ | ៧២ |
| ១៩ | បណ្ដាំម៉ែយើង | ពាក្យ ៧ | ៨០ |
| ២០ | សម្មាវាចា | កាកគតិ | ៨៣ |
| ២១ | របរសុចរិត ពិតជាប្រពៃ | កាកគតិ | ៨៨ |
| ២២ | បានផុតទុក្ខ | កាកគតិ | ៩៣ |
| ២៣ | បុណ្យធម្មទាន | កាកគតិ | ៩៧ |
| ២៤ | វាលបី អន្លង់កម្មបួន | កាកគតិ | ១០១ |
| ២៥ | មានរូបមានទុក្ខ | កាកគតិ | ១០៧ |
| ២៦ | ផ្លូវហាមឃាត់ | ពាក្យ ៧ | ១១១ |
| ២៧ | កាំភ្លើងសិរីទ្ធិ | កាកគតិ | ១១៣ |
| ២៨ | ទីពីរល្អដាច់ | កាកគតិ | ១១៨ |
| ២៩ | ឧបោសថសីល | កាកគតិ | ១២៤ |
| ៣០ | ពុទ្ធបណ្ដាំ | កាកគតិ | ១៣៤ |

| | | | |
|---|---|---|---|
| ៣១ | ពាក្យសុំអភ័យទោស | កាកគតិ | ១៣៧ |


# មាតិកា កំណាព្យធម៌ភាគ ២


| ល.រ | ឈ្មោះកំណាព្យ | មេបទ | ទំព័រ |
|---|---|---|---|
| ១ | ពុទ្ធប្រវត្តិ | ពាក្យ ៧ | ១ |
| ២ | កាព្យខ្លីៗពី ✱១ ដល់ ✱៣៥) | កាព្យរាយ | ៤-១០៦ |
| ៣ | គោលព្រះពុទ្ធសាសនា | កាកគតិ | ៨ |
| ៤ | បូជនីយបុគ្គល | ពាក្យ ៨ | ១៣ |
| ៥ | ប្រយ័ត្ន | ពាក្យរាយ | ២៤ |
| ៦ | ប្រលងប្រណាំងផ្ទុយគ្នា | កាកគតិ | ២៧ |
| ៧ | ទ្រុងអវិជ្ជា | កាកគតិ | ៣១ |
| ៨ | ស្ថានសួគ៌ ៦ ជាន់ | ព្រហ្មគីតិ | ៣៦ |
| ៩ | ទ្វីបទាំង ៤ | ព្រហ្មគីតិ | ៤២ |
| ១០ | ឋានព្រហ្ម | ព្រហ្មគីតិ | ៤៧ |
| ១១ | មានដូចជាមិនមាន | កាព្យរាយ | ៥៦ |
| ១២ | ភ្លើងស្តុប | កាកគតិ | ៥៩ |
| ១៣ | ពាក្យទូន្មានគ្មានទេជេរ | កាកគតិ | ៦១ |
| ១៤ | បត្តានុមោទនាមយៈ | ពាក្យ ៨ | ៦៧ |
| ១៥ | កំណាញ់ត្រូវតម្រា | ពាក្យ ៧ | ៧៤ |

| | | | |
|---|---|---|---|
| ១៦ | ខកពេលព្រោះការរង់ចាំ | កាកគតិ | ៧៧ |
| ១៧ | ស្រវឹងច្រើនបែប | កាកគតិ | ៨៣ |
| ១៨ | ខ្មាំងសត្រូវប្រកបដោយគ្រោះថ្នាក់ | កាកគតិ | ៨៧ |
| ១៩ | សំណាបយោងដីកំពូលស្ត្រីឧត្តរា | កាកគតិ | ៩៣ |
| ២០ | យក និង ដូច | ពាក្យរាយ | ៩៦ |
| ២១ | តួនាទី ១២ករណីកិច្ច | ព្រហ្មគីតិ | ៩៨ |


## មាតិកា កំណាព្យធម៌ភាគ ៣


| ល.រ | ឈ្មោះកំណាព្យ | មេបទ | ទំព័រ |
|---|---|---|---|
| ១ | ដំណើរព្រះពុទ្ធសាសនានៅកម្ពុជា | កាកគតិ | ១ |
| ២ | កាព្យខ្លីៗពី ✱១ ដល់ ✱៤៩ | កាព្យរាយ | ១៨-១៣៤ |
| ៣ | ការជ្រះថ្លាចំពោះព្រះសក្យមុនីចេតិយ | កាកគតិ | ១៩ |
| ៤ | ឱ្យសូមអង្វរ | កាព្យរាយ | ៣៤ |
| ៥ | តើលោកអ្នកអាយុប៉ុន្មានហើយ | កាព្យរាយ | ៣៦ |
| ៦ | កុំគិតតែឯងក្រែងវាខុស | ឧទានកថា | ៤១ |
| ៧ | ឃើញខុសព្រោះអវិជ្ជា | ឧទានកថា | ៤៤ |
| ៨ | ខ្ញុំជ្រះថ្លាគុណព្រះពុទ្ធ | កាកគតិ | ៤៧ |
| ៩ | ព្រហ្មវិហារធម៌មាតាបិតា | ពាក្យ ៨ | ៥៤ |
| ១០ | ទំនួញកូនកំសត់ | កាព្យរាយ | ៦០ |

| | | | |
|---|---|---|---|
| ១១ | សប្បុរសរៀមច្បង | កាកគតិ | ៦១ |
| ១២ | ឪពុកសួររកកូនវិញ | ពាក្យ ៨ | ៦២ |
| ១៣ | អបាយមុខជាគុកដាក់ខ្លួនឯង | ពាក្យ ៧ | ៦៣ |
| ១៤ | វឌ្ឍនធម៌ | កាកគតិ | ៦៧ |
| ១៥ | អរិយទ្រព្យ | កាកគតិ | ៧១ |
| ១៦ | ស្គាល់ច្បាស់ព្រះជួយ | កាកគតិ | ៧៣ |
| ១៧ | ផ្លូវទៅនិព្វាន | ព្រហ្មគីតិ | ៧៧ |
| ១៨ | សេចក្តីសុខរបស់គ្រហស្ថ | កាកគតិ | ៨៦ |
| ១៩ | សុខបង្កប់ក្តីទុក្ខ | កាកគតិ | ៨៨ |
| ២០ | ព្យុះចិត្តកកិតរន្ទះមីស៊ីល | កាព្យរាយ | ៩១ |
| ២១ | តាខ្ញុំមិនច្រឡំគេ | កាព្យរាយ | ៩៣ |
| ២២ | មិនមែនអត់ហេតុ | សុភាសិត | ៩៥ |
| ២៣ | អាចារ្យ | កាកគតិ | ៩៨ |
| ២៤ | សក្យវង្ស និងកោលិយវង្ស | កាកគតិ | ១០៤ |
| ២៥ | ឡានក្រុងក្រឡាប់ស្លាប់ច្រើន | កាព្យរាយ | ១០៨ |
| ២៦ | កាន់តែ | សុភាសិត | ១១០ |
| ២៧ | សត្រូវ | សុភាសិត | ១១៤ |
| ២៨ | ការរលឹកនឹកឃើញគុណ | កាកគតិ | ១១៦ |

| | | | |
|---|---|---|---|
| ២៩ | បើ...កុំ ! | ឧទានកថា | ១២១ |
| ៣០ | មិនឆ្អែត | សុភាសិត | ១២២ |
| ៣១ | កុំណាកូនណា ! | ឧទានកថា | ១២៣ |
| ៣២ | ថ្ងៃ ១៥កើត និង១៥រោច ខែកត្តិក | កាកគតិ | ១២៥ |
| ៣៣ | ចំណើទាស់ | សុភាសិត | ១២៩ |


**<u>បញ្ជាក់៖</u>**

**សៀវភៅ កំណាព្យធម៌ភាគ ៤នេះ ត្រូវបានកែសម្រួលពាក្យពេចន៍ខ្លះៗឡើងវិញ ហើយបោះពុម្ពជាលើកទី ៣ នៅថ្ងៃ ១៥កើត ខែ ពិសាខ ព.ស ២៥៦០ ត្រូវនឹងថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ ចំនួន ២.០០០ ក្បាល សម្រាប់ធ្វើជាធម្មទាន ។**

**ដោយខ្ញុំព្រះករុណាខ្ញុំបាន**

**អោក ប៉ូរ៉ា**

## ធម៌សម្រាប់ភាវនាសងគុណព្រះពុទ្ធ

## ឥ តិ បិ សោ ភ គ វា

(សូត្រ៥៦ ចប់)

## ថ្នាំបំបាត់ឈឺដង្កង់

សូមយកកក្កូរស្រូវទុំទៅស្ងោផឹកជាហោង ។

## ធម៌សម្រាប់ភាវនាសងគុណព្រះសូត្រ

## ធី ម សំ អំ ខុ

(សូត្រ១០៨ចប់)

## ធម៌សម្រាប់ភាវនាសងគុណព្រះវិន័យ

## អា បា ម ចុ ប

(សូត្រ១០៨ចប់)

# ធម៌សម្រាប់ភាវនាសងគុណព្រះនព្វលោកុត្តរធម៌

## អ ស វិ សុ លោ អ បុ ស ពុ ភ

(សូត្រ១០៨ចប់)

# ធម៌សម្រាប់ភាវនាសងគុណគ្រូអាចារ្យ

## យ ភ រំ គ រុ ឃា បំ វិ ន ស្យ តុ

(សូត្រ១០ចប់)

# ធម៌សម្រាប់ភាវនាសងគុណព្រះពាយ

## វ តា ឃា បំ វិ ន ស្យ តុ

(សូត្រ១២ចប់)

**ថ្នាំបំបាត់មុននិងមុខជាំ**

សូមកាត់យកប្រទាលកន្ទុយក្រពើបុកហើយ
ពូតយកទឹកមកលាបលើផ្ទៃមុខជារឿយៗជាហោង

(ចប់)

សូមអនុមោទនា

# នាមសប្បុរសជនដែលមានសទ្ធាចូលប្រាក់ដើម្បី
# បោះពុម្ពសៀវភៅកំណាព្យធម៌ភាគ ៤
# សម្រាប់ធ្វើជាធម្មទាន លើកទី ៣

| ល.រ | ឈ្មោះសប្បុរសជន | ចំនួនទឹកប្រាក់ |
|---|---|---|
| ១ | ឧបាសិកា **សួន គន្ធា** និង<br>ឧបាសិកា **ញ៉ុក ច្រឹក** | 1.300$ |
| ២ | ឯកឧត្តម **យ៉េត ចរិយា** និងលោកជំទាវ<br>**ឡុង មុនីចិន្តា** ព្រមទាំងបុត្រ | 500$ |
| ៣ | ឧបាសិកា **ភាំង ស្រៀង** (ម្តាយ) | 25$ |
| ៤ | ឧបាសិកា **សុខ្ខ ម៉ុត** (ម្តាយក្មេក) | 25$ |
| ៥ | កញ្ញា **ព្រឿង សីហៈសុភ័គ** | 25$ |
| ៦ | កញ្ញា **ព្រឿង សីហៈសុគន្ធ** | 25$ |
| ៧ | កញ្ញា **ព្រឿង សីហៈសុពណ៌** | 25$ |
| ៨ | កញ្ញា **ព្រឿង សីហៈបញ្ញទេវី** | 25$ |
| ៩ | កញ្ញា **ព្រឿង ពិដោរស្នេហ៍រាជិនី** | 25$ |
| ១០ | កញ្ញា **ព្រឿង សីហៈទេពរំដួល** | 25$ |

| | | |
|---|---|---|
| ១១ | កូនប្រុស **ព្រឿង សីហៈចក្រចក្រា** | 25$ |
| ១២ | អ្នកស្រី **ណិប ចិន្តា** និងស្វាមី ព្រមទាំងបុត្រ | 25$ |
| ១៣ | អ្នកស្រី **ណិប ផល្លា** និងស្វាមី ព្រមទាំងបុត្រ | 25$ |
| ១៤ | លោកម្ចាស់ **ណិប ផល្លី** | 25$ |
| ១៥ | កញ្ញា **ណិប ចន្ទី (ពៅឋានសួគ៌)** | 25$ |
| ១៦ | លោក **ទ្រឹន ឡុង** និងអ្នកស្រី **គាំង ដានី** ព្រមទាំងបុត្រ | 25$ |
| ១៧ | លោក **កែវ សាវ៉ាង** និងភរិយា ព្រមទាំងបុត្រ | 20$ |
| ១៨ | អ្នកស្រី **អោក បុណ្ណ** ព្រមទាំងបុត្រ | 20$ |
| ១៩ | អ្នកស្រី **អោក ឃីណា** ព្រមទាំងបុត្រ | 20$ |
| ២០ | ឧបាសក **យិច ឈីន** និង ឧបាសិកា **តែ សុមាលី (ប៊ួយ)** ព្រមទាំងកូនចៅ | 50.000 R |
| ២១ | អ្នកស្រី **ព្រាំ លក្ខណា** និងស្វាមី ព្រមទាំងបុត្រ | 10$ |
| ២២ | អ្នកស្រី **ព្រាំ សុខហេង** ព្រមទាំងបុត្រ | 10$ |
| ២៣ | កញ្ញា **ព្រាំ សុធារា** | 10$ |